នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | ៖ | ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ៥៦) |
| **ដាក់ជូន** | ៖ | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | ៖ | ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ |
| **ភាគីដាក់ឯកសារ** | ៖ | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | ៖ | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 21-Jan-2019, 12:40
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ សម្ងាត់
ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ៖ សម្ងាត់/Confidential
ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖
ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ៖
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖
ហត្ថលេខា៖

---

**បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ**
**ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359)**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោក Nicholas KOUMJIAN

**ចម្លងជូន:**

**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**

**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
លោក Olivier BEAUVALLET
ចៅក្រម ន័យ ថុល
លោក Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**សហមេធាវី អោ អាន**
លោក មុំ លុជ្ស
លោក Richard ROGERS
លោក Göran SLUITER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
**ទាំងអស់ក្នុងសំណុំរឿង០០៤/២**

## មាតិកា

II. ប្រវត្តិនីតិវិធី ..... 7

III. ច្បាប់ជាធរមាន ..... 7

**ក**. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ..... 7

**ខ**. បទដ្ឋាននៃការពិនិត្យឡើងវិញលើការសម្រេចពីយុត្តាធិការបុគ្គល ..... 7

**គ**. លក្ខខណ្ឌតម្រូវសម្រាប់ការសន្និដ្ឋាននានាទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង និង ការទទួលខុសត្រូវព្រហ្មទណ្ឌដែលអាចមានរបស់ជនសង្ស័យ ..... 9

**ឃ**. បទដ្ឋានសម្រាប់ការកំណត់ជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហម ..... 10

**ង**. បទដ្ឋាននៃភ័ស្តុតាងសម្រាប់ការបញ្ជូនរឿងទៅជំនុំជម្រះ ..... 11

IV. សេចក្តីសន្និដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ..... 11

**ក**. កំហុសអង្គច្បាប់នៃការខកខានមិនបានធ្វើការសន្និដ្ឋានទៅលើឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើង និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្មទាំងនោះ ..... 12

១. ការគ្មានការសន្និដ្ឋានអំពីថាតើ ឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តឡើង ឬទេ និងថាតើ អោ អាន ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មណាមួយឬទេ ..... 12

២. ការគ្មានការសន្និដ្ឋានអង្គច្បាប់ដែលផ្អែកលើការសន្និដ្ឋានផ្នែកអង្គហេតុរបស់ ដីកាសម្រេចលើកលែងចោទប្រកាន់ ..... 14

**ខ**. ការកំហុសអង្គច្បាប់ និងអង្គហេតុដោយការផ្តល់ទម្ងន់ច្រើនទៅលើការបង្ខិតបង្ខំ ការគាបសង្កត់ និងបញ្ជាថ្នាក់លើ ..... 23

១. ដីកាសម្រេចលើកលែងចោទប្រកាន់ផ្តល់ទម្ងន់ច្រើនហួសទៅលើបញ្ជាថ្នាក់លើការគាបសង្កត់ និងការបង្ខិតបង្ខំ ក្នុងការវិភាគអំពីយុត្តាធិការបុគ្គល ..... 23

២. អោ អាន ប្រព្រឹត្តឧក្រិដ្ឋកម្មដោយស្ម័គ្រចិត្ត និងយ៉ាងសកម្មដោយគ្មានការបង្ខិតបង្ខំ ..... 28

៣. លក្ខខណ្ឌតម្រូវគ្មានមូលដ្ឋានដែលថា ការចូលរួមប្រព្រឹត្តរបស់ អោ អាន ក្នុងឧក្រិដ្ឋកម្មហួសឆ្ងាយពីសិទ្ធិអំណាចផ្លូវការរបស់គាត់ ..... 32

៤. ការប្រព្រឹត្តិចំពោះបទបញ្ជា ការបង្ខិតបង្ខំ និងការគាបសង្កត់របស់ថ្នាក់លើខុសគ្នាតាមទំនើងចិត្ត នៅក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០៤/២ ..... 33

**គ**. កំហុសផ្នែកច្បាប់ដែលសម្រេចថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់" ..... 36

១. ការសម្រេចថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់" គឺផ្ទុយទៅនឹងសេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងដោយប្រធានក្រុមចរចារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងពេលនៃកិច្ចចរចា ដូច្នេះ គឺជាការខកខានក្នុងការគោរពចំពោះចេតនាយ៉ាងច្បាស់របស់រាជរដ្ឋាភិបាលកម្ពុជា នៅពេលច្បាប់ អ.វ.ត.ក ត្រូវបានបង្កើត ........ 37

២. ការសម្រេចថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់" មិនស៊ីសង្វាក់គ្នាជាមួយនឹងការយល់យ៉ាងច្បាស់អំពីយុត្តាធិការបុគ្គល និងចេតនារបស់ អ.ស.ប នៅក្នុងពេលចរចាទេ ........ 39

៣. ការសម្រេចថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់" ផ្ទុយនឹងការសម្រេចរបស់ ស.ច.ស.ជ ខ្លួនឯងនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ និងដីកាដំណោះស្រាយនៃសំណុំរឿង ០០៤/១ ........ 40

៤. ការសម្រេចថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់" ផ្ទុយនឹងអត្ថន័យធម្មតានៃច្បាប់ និងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ........ 41

៥. ការសម្រេចថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់" គឺជាការរំលោភលើនិយាម សិទ្ធិមនុស្សអន្តរជាតិ និងការការពារដែលបានផ្តល់ដោយរដ្ឋធម្មនុញ្ញកម្ពុជា ........ 42

**ឃ**. កំហុសអង្គហេតុ ទាក់ទងនឹងការវាយតម្លៃលើភាពជឿទុកចិត្តបាននៃភ័ស្តុតាង ........ 43

១. ភ័ស្តុតាងរបស់ ប្រាក់ យុត ត្រូវបានបញ្ជាក់ និងអាចជឿទុកចិត្តបាន ........ 43

២. អានុភាពនៃគោលនយោបាយនានារបស់កម្ពុជាប្រជាធិបតេយ្យ និងការកន្លងផុតទៅនៃពេលវេលាទៅលើភ័ស្តុតាងរបស់សាក្សី ត្រូវតែមានការវាយតម្លៃទៅតាមករណីនីមួយៗ ........ 45

**ង**. ការសន្និដ្ឋានខុសចំពោះអង្គហេតុ ជាមួយនឹងការប៉ះពាល់ច្បាស់លាស់មួយទៅលើបញ្ហាយុត្តាធិការបុគ្គល ........ 47

១. មានភ័ស្តុតាងលើសលប់ដែលបញ្ជាក់ថា អោ អាន បានបញ្ជាឲ្យមានការចាប់ខ្លួន និងសម្លាប់មនុស្សជាច្រើននាក់ ........ 48

២. មានភស្តុតាងរឹងមាំដែលថា អោ អាន បានទៅដល់ភូមិភាគកណ្តាល នៅដើមឆ្នាំ១៩៧៧ និងបានធ្វើជាលេខាតំបន់៤១ អស់រយៈពេលជិតពីរឆ្នាំ ........ 58

៣. ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ភាគច្រើន ឬ ទាំងអស់ ត្រូវបានប្រព្រឹត្តឡើងដោយមានការចូលរួមរបស់ អោ អាន នៅក្នុងអំឡុងពេលដែលគាត់បានធ្វើជាលេខាតំបន់៤១ ........ 66

៤. ផ្ទុយគ្នាទៅនឹងអ្វីដែលដីកាសម្រេចលើកលែងចោទប្រកាន់បង្ហាញ ភស្តុតាងបង្ហាញថា កែ ពក និង អោ អាន បានធ្វើសេចក្តីសម្រេចនានា ដោយមានការសហការគ្នា និងជាសមូហភាព ........ 72

ឆ. កំហុសអង្គច្បាប់ស្តីពីការខកខានមិនបានពិចារណាឲ្យបានគ្រប់គ្រាន់ពីផលប៉ះពាល់នៃអ្នកដឹកនាំរបស់ អោ អាន ដែលបានកំណត់ ក្នុងយុទ្ធនាការប្រល័យពូជសាសន៍ថ្នាក់តំបន់ ចំពោះការវាយតម្លៃថាតើ អោ អាន ស្ថិតនៅក្នុងចំណោមជនទាំងឡាយដែល “ទទួលខុសត្រូវខ្ពស់បំផុត” ឬទេ ....... 76

V. សេចក្តីសន្និដ្ឋានទាក់ទងនឹងដីកាដំណោះស្រាយដែលផ្ទុយគ្នា....... 81

VI. សេចក្តីសន្និដ្ឋាន ....... 85

VII. សំណើអំពីដំណោះស្រាយ ....... 87

# I. សេចក្តីផ្តើម

1. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("សចសអ") បានចេញដីកាដំណោះស្រាយ ("បញ្ជូនរឿងទៅជំនុំជម្រះ") ដែលបានចោទប្រកាន់ អោ អាន ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ និងបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ[1]។ នៅក្នុងថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតជាតិ ("សចសជ") បានចេញដីកាដំណោះស្រាយ ("ដីកាសម្រេចលើកលែងចោទប្រកាន់") ដែលលើកលែងរាល់ការចោទប្រកាន់ទាំងអស់ប្រឆាំងនឹង អោ អាន ដោយឈរលើមូលដ្ឋានថា អោ អាន មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[2]។ បណ្តឹងឧទ្ធរណ៍នេះជំទាស់ទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់។

2. ដីកាសម្រេចលើកលែងចោទប្រកាន់ផ្អែកលើការសន្និដ្ឋានថា អោ អាន មិនស្ថិតក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម។ ខណៈដែលការកំណត់អំពីថាតើបុគ្គលម្នាក់ស្ថិតនៅក្នុងប្រភេទជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យឬទេនោះ ស្ថិតនៅក្នុងឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ("សចស") ការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ ផ្អែកលើកំហុសអង្គហេតុ និងអង្គច្បាប់ ដែលធ្វើឲ្យការសន្និដ្ឋាននោះគ្មានសុពលភាពទេ។ ដូចដែលបានរៀបរាប់លម្អិតខាងក្រោម សំអាងហេតុរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ មានកំហុសជាច្រើនដែលរួមមាន (១) ខកខានមិនបានធ្វើការសន្និដ្ឋានណាមួយថាតើ ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានធ្វើឡើងដែរឬទេ និងថាតើ អោ អាន មានការទទួលខុសត្រូវណាមួយចំពោះឧក្រិដ្ឋកម្មទាំងនោះដែរឬទេ (កំហុសអង្គច្បាប់)។ (២) ការផ្តល់ស្ថានទម្ងន់មិនត្រឹមត្រូវក្នុងការវាយតម្លៃរបស់ខ្លួនអំពីយុត្តាធិការបុគ្គល ចំពោះពេលខ្លះការសន្និដ្ឋានមិនត្រឹមត្រូវ ឬមិនពេញលេញទាក់ទងនឹងកម្រិតដែល អោ អាន បានធ្វើតាមបញ្ជាថ្នាក់លើ និង/ឬ ប្រព្រឹត្តអំពើក្រោមការបង្ខិតបង្ខំ ឬការគំរាមកំហែង (កំហុសអង្គហេតុ និងអង្គច្បាប់)។ (៣) ការបកស្រាយច្បាប់ អ.វ.ត.ក ខុស ដោយសន្និដ្ឋានថា ប្រភេទនៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"

---

[1] ឯកសារ **D360** ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ EN 01580615-21។

[2] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ("ដីកាសម្រេចលើកលែងចោទប្រកាន់") កថាខណ្ឌ ៥៥៤-៥៥៥។

ចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អាចសំដៅតែទៅលើ កាំង ហ្កេកអ៊ាវ ("ឌុច") (កំហុសអង្គច្បាប់)។ (៤) ការវាយតម្លៃខុសអំពីភាពអាចជឿជាក់បាននៃភស្តុតាងក្នុងសំណុំរឿង (កំហុសអង្គហេតុ)។ (៥) ការសន្និដ្ឋានផ្នែកអង្គហេតុមួយចំនួនដែលមិនសមហេតុផល ដែលមានផលប៉ះពាល់ធ្ងន់ធ្ងរលើការកំណត់យុត្តាធិការបុគ្គល និង (៦) ការខកខានមិនបានពិចារណាឱ្យបានដិតដល់អំពីផលប៉ះពាល់សំខាន់នៃឆន្ទៈរបស់ អោ អាន និងការចូលរួមសំខាន់ៗក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ជាកត្តាមួយដែលគួរត្រូវបានពិចារណាក្នុងការវាយតម្លៃថាតើ អោ អាន ស្ថិតនៅក្នុងប្រភេទយុត្តាធិការជាជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យឬទេ។

3. ដាច់ដោយឡែកពីគ្នា ឬរួមគ្នា កំហុសអង្គច្បាប់ និងអង្គហេតុទាំងអស់នេះនៅក្នុងសំអាងហេតុនៃដីកាសម្រេចលើកលែងចោទប្រកាន់ តម្រូវឱ្យអង្គបុរេជំនុំជម្រះ ("អបជ") បដិសេធចោលសេចក្ដីសម្រេចនោះ។ ដោយសារថា ទោះបីជាការសន្និដ្ឋានផ្នែកអង្គហេតុមួយចំនួននៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ បានបង្ហាញទៅតាមលក្ខខណ្ឌតម្រូវថា អោ អាន បានប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួន ដើម្បីជួយដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មទ្រង់ទ្រាយធំនៅក្នុងតំបន់ដែលគាត់គ្រប់គ្រង ដោយរួមទាំង ការបញ្ជាឱ្យសម្លាប់មនុស្សរាប់ពាន់នាក់ដោយមានចេតនាប្រល័យពូជសាសន៍ ដែលជាការសន្និដ្ឋានសមហេតុផលតែមួយគត់ដែលថា អោ អាន ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដោយសារតែគាត់ស្ថិតក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ។

4. ពេលនេះ សហព្រះរាជអាជ្ញាអន្តរជាតិ ("សពអ") ប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់នេះ អនុលោមតាមវិធាន ៦៧(៥) និង ៧៤(២) នៃវិធានផ្ទៃក្នុង[3] និងស្នើសុំដោយក្ដីគោរពឱ្យអង្គបុរេជំនុំជម្រះសម្រេចថា អោ អាន ស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម ហេតុដូច្នេះ ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់

[3] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វ.៩) ដែលត្រូវបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង" ឬ "វិធាន")។

អ.វ.ត.ក។ សពអ ស្នើសុំទៀតឲ្យ អបជ បង្គាប់ថា រឿងក្ដីប្រឆាំងនឹង អោ អាន បន្តទៅជំនុំជម្រះដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ សចសអ។[4]

## II. ប្រវត្តិនីតិវិធី

5. ប្រវត្តិនីតិវិធីដែលពាក់ព័ន្ធមានរៀបរាប់ក្នុងឧបសម្ព័ន្ធ I។

## III. ច្បាប់ជាធរមាន

### ក. ភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍

6. វិធាន ៧៤(២) នៃវិធានផ្ទៃក្នុងចែងថា សហព្រះរាជអាជ្ញា "អាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីការបស់សហចៅក្រមស៊ើបអង្កេត" និងវិធាន ៦៧(៥) ចែងថា ដីកាដំណោះស្រាយ "បើកផ្លូវប្ដឹងឧទ្ធរណ៍ដូចមានចែងក្នុងវិធាន ៧៤"។

### ខ. បទដ្ឋាននៃការពិនិត្យឡើងវិញលើការសម្រេចពីយុត្តាធិការបុគ្គល

7. បើទោះជា សចស អាចអនុវត្តឆន្ទានុសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគាត់ក្នុងការសម្រេចថាតើ ជនត្រូវចោទម្នាក់ស្ថិតនៅក្នុងប្រភេទជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងរបប

---

[4] សំណើសុំដំណោះស្រាយនេះធ្វើឡើងបន្ទាប់ពីមានស្ថានភាពថ្មីមួយនៅពេលមានដីកាដំណោះស្រាយពីរផ្ទុយគ្នា ដោយមួយជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងមួយទៀតជាដីកាលើកលែងចោទប្រកាន់ នៅក្នុងរឿងក្ដីតែមួយ ដែលត្រូវតែយកមកពិចារណារួមគ្នា។ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ពីលទ្ធភាពនៃការប្ដឹងឧទ្ធរណ៍ខ្វែង និងទំនាក់ទំនងទៅនឹងដីកាដំណោះស្រាយទាំងនេះ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនដែលផ្ដល់ឲ្យភាគីនូវពេលវេលា និងចំនួនទំព័របន្ថែម ដើម្បីរៀបចំបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងនេះ។ *សូមមើល* ឯកសារ **D360/7** សេចក្ដីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្ដឹងឧទ្ធរណ៍របស់ អោ អាន លើដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("សេចក្ដីសម្រេចស្ដីពីសំណើសុំបន្ថែម") កថាខណ្ឌ៣។ សំណើសុំដំណោះស្រាយនេះបានផ្អែកលើការសន្មតថា បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានអនុញ្ញាតឡើយ។ នៅក្នុងស្ថានភាពដែលជាករណីមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព វិធាន ៧៧(១៣)(ខ) កំណត់ថា អ.ប.ជ ត្រូវប្ដឹងទៅអង្គជំនុំជម្រះសាលាដំបូងផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ។

ខ្មែរក្រហមឬទេនោះ ឆន្ទានុសិទ្ធិនេះមិនមែនគ្មានដែនកំណត់នោះទេ និង "មិនអនុញ្ញាតឲ្យបំពេញតាមអំពើចិត្តទេ"[5] អបជ អាចពិនិត្យលើសេចក្ដីសម្រេចរបស់ សចសជ ទាក់ទងនឹងបញ្ហានេះ [6]។

8. លើសពីនេះទៀត ច្បាប់អន្តរជាតិបានកំណត់ច្បាស់ថា សេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិដែលផ្អែកលើសំអាងហេតុផ្នែកច្បាប់ ឬការសន្និដ្ឋានផ្នែកអង្គហេតុដែលមានកំហុស មិនអាចមានសុពលភាពនោះទេ[7]។ ដូចទៅនឹងអ្វីដែល អបជ បានសម្រេចជាឯកច្ឆ័ន្ទនាពេលថ្មីៗនេះថា៖

[5] សំណុំរឿង០០៤/១-**D308/3/1/20** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ("សេចក្ដីពិចារណារបស់ អបជ លើដីកាដំណោះស្រាយក្នុងរឿងក្ដី អ៊ុំ ចែម") កថាខណ្ឌ ២០ (សម្រេចជាឯកច្ឆ័ន្ទ)។

[6] សំណុំរឿង០០៤/១-**D308/3/1/20** សេចក្ដីពិចារណារបស់ អបជ លើដីកាដំណោះស្រាយក្នុងរឿងក្ដី អ៊ុំ ចែម កថាខណ្ឌ២០ (សម្រេចជាឯកច្ឆ័ន្ទ)។

[7] *Slobodan Milošević ទល់នឹង រដ្ឋអាជ្ញា* IT 02-54-AR73.7 សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បន្ទំនៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការចាត់តាំងស្មាក្ដី ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៤ កថាខណ្ឌ១០ *ត្រូវបានដកស្រង់ក្នុង* សំណុំរឿង០០២-ឯកសារ **D164/3/6** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំភ័ស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ២៥។ *រដ្ឋអាជ្ញា ទល់នឹង Slobodan Milošević*, IT-99-37-AR73, IT-01-50-AR73, IT-01-51-AR73 សំអាងហេតុសម្រាប់សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បន្ទំរបស់អយ្យការជំទាស់នឹងដីកាបដិសេធ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២ កថាខណ្ឌ៥-៦។ *រដ្ឋអាជ្ញា ទល់នឹង Šešelj*, IT-03-67-AR73.5 សេក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បន្ទំរបស់ Vojislav Šešelj ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីទម្រង់នៃការដាក់បង្ហាញ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ១៤។ *រដ្ឋអាជ្ញា ទល់នឹង Halilović*, IT-01-48-AR73.2 សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បន្ទំទាក់ទងនឹងការអនុញ្ញាតទទួលយកកំណត់ត្រាសួរចម្លើយរបស់ជនជាប់ចោទពីអង្គចៅក្រម ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៥ កថាខណ្ឌ ៥, ៦៤។ *រដ្ឋអាជ្ញា ទល់នឹង Karemera និងគូកន* ICTR-98-44-AR73 សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បន្ទំរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ III ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៣ ដែលបានបដិសេធអនុញ្ញាតដាក់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានកែប្រែ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៣ កថាខណ្ឌ ៥។ *Uwinkindi ទល់នឹង រដ្ឋអាជ្ញា* ICTR-01-75-AR72(C) សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ មេធាវីការពារក្ដីប្រឆាំនឹងសេចក្ដីសម្រេចបដិសេធញត្តិដែលចោទប្រកាន់អំពីវិការៈនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១ កថាខណ្ឌ ៦។ *រដ្ឋអាជ្ញា ទល់នឹង Katanga & Ngudjolo Chui*, ICC-01/04-01/07 សាលក្រមលើបណ្ដឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹង "សេចក្ដីសម្រេចលើសំណើលេខ ១២០០ របស់រដ្ឋអាជ្ញាសុំការហាមឃាត់ និងវិធានការតឹងប្រឆាំងនឹង Mathieu Ngudjolo ទាក់ទងនឹងការទំនាក់ទំនងទាំងខាងក្នុង និងខាងក្រៅមន្ទីឃុំឃាំង" ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌ ១, ៤១-៤៣។

សេចក្តីសម្រេចមួយអាចត្រូវបានបដិសេធចោល ក្នុងករណីដែលសេចក្តីសម្រេចនោះ (១) ផ្អែកលើការបកស្រាយច្បាប់ជាមូលដ្ឋានមិនបានត្រឹមត្រូវ (*គឺ* កំហុសអង្គច្បាប់) ដែលនាំឲ្យសេចក្តីសម្រេចនោះគ្មានសុពលភាព (២) ផ្អែកលើការសន្និដ្ឋានលើអង្គហេតុមិនត្រឹមត្រូវច្បាស់ក្រឡែត (*គឺ* កំហុសអង្គហេតុ) ដែលបណ្តាលឲ្យមានភាពអយុត្តិធម៌ និង/ឬ (៣) មានភាពអយុត្តិធម៌ ឬមិនសមហេតុសមផល ដែលជាការបំពានលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត និងបង្ខំឲ្យធ្វើការសន្និដ្ឋាន ដោយពួកគាត់មិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឲ្យបានប្រយ័ត្នប្រយែង។ អាចនិយាយម្យ៉ាងទៀតថា ត្រូវបង្ហាញឲ្យឃើញថា សហចៅក្រមស៊ើបអង្កេត មានកំហុស ឬមានការបំពារបំពាន ដែលមានអានុភាពទៅលើការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន។[8]

9. អបជ យល់ឃើញថា យុត្តិសាស្ត្រអន្តរជាតិបានកំណត់ថា ចំពោះបណ្តឹងឧទ្ធរណ៍ "ការភ័ន្តច្រឡំអង្គច្បាប់ដែលបានលើកឡើង ត្រូវបានពិនិត្យ *ជាថ្មី* ដើម្បីសម្រេចថាតើ សេចក្តីសម្រេចផ្លូវច្បាប់មានលក្ខណៈត្រឹមត្រូវដែរឬទេ និងការភ័ន្តច្រឡំអង្គហេតុត្រូវបានពិនិត្យមើល ស្របតាមបទដ្ឋានស្តីពីភាពសមស្រប ដើម្បីសម្រេចថា តើ ពុំមានអ្នកវិនិច្ឆ័យសេចក្តីអង្គហេតុដែលសមស្របបានធ្វើសំអាងផ្អែកអង្គហេតុដែលបានលើកឡើងដែរឬទេ"[9]។

## គ. លក្ខខណ្ឌតម្រូវសម្រាប់ការសន្និដ្ឋាននានាទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង និងការទទួលខុសត្រូវព្រហ្មទណ្ឌដែលអាចមានរបស់ជនសង្ស័យ

10. នៅក្នុងដីកាដំណោះស្រាយណាក៏ដោយ សចស ត្រូវ "ធ្វើការសម្រេចចុងក្រោយពាក់ព័ន្ធនឹងការកំណត់លក្ខណៈផ្លូវច្បាប់នៃអំពើនានាដែលបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា និងសម្រេចលើបញ្ហាថាតើ អំពើទាំងនោះចាត់ទុកថាជាបទឧក្រិដ្ឋនានាដែលស្ថិតនៅក្នុងយុត្តាធិការរបស់

[8] សំណុំរឿង០០៤/១-**D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយក្នុងរឿងក្តី អ៊ឹម ចែម កថាខណ្ឌ ២១ (សម្រេចជាឯកច្ឆ័ន្ទ)។

[9] សំណុំរឿង០០២-**D427/1/30** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ("សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ") កថាខណ្ឌ១១៣។

អ.វ.ត.ក ដែរឬទេ”[10]។ ការសន្និដ្ឋានទាំងអស់នេះបានតម្រូវឲ្យ អបជ បានសម្រេចជាឯកច្ឆ័ន្ទថា ដើម្បីអនុវត្តឲ្យបានត្រឹមត្រូវនូវអំណាចរបស់ខ្លួនក្នុងការពិនិត្យលើសេចក្តីសម្រេចនានាលើយុត្តាធិការបុគ្គល អង្គជំនុំជម្រះ “ប្រាកដជាអាចពិនិត្យមើលលើសេចក្តីសន្និដ្ឋាននានាដែលនាំឲ្យមានការសម្រេចបែបនេះ រួមទាំងសេចក្តីសន្និដ្ឋានទាំងឡាយណាពាក់ព័ន្ធនឹងអត្ថិភាពនៃបទល្មើស ឬភវនីយភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ [ជនសង្ស័យ]”[11]។ កាតព្វកិច្ចត្រូវធ្វើការរកឃើញចាំបាច់នេះ អនុវត្តតាមលក្ខខណ្ឌតម្រូវនៃវិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្រពាក់ព័ន្ធដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងលើកលែងចោទប្រកាន់ត្រូវតែមានសំអាងហេតុ[12]។

## ឃ. បទដ្ឋានសម្រាប់ការកំណត់ជនទាំងឡាយដែល “ទទួលខុសត្រូវខ្ពស់បំផុត” ចំពោះឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហម

11. ការកំណត់ជនទាំងឡាយដែល “ទទួលខុសត្រូវខ្ពស់បំផុត” ចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក តម្រូវឲ្យមានការវាយតម្លៃទាំងទៅលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលត្រូវបាន

---

[10] សំណុំរឿង០០២-**D427/3/15** សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ៧៩។ *សូមមើលផងដែរ* សំណុំរឿង០០៤/១-**D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយក្នុងរឿងក្តី អ៊ឹម ចែម កថាខណ្ឌ៣២១-៣៤០។ រាល់ដីកាដំណោះស្រាយដែលបានចេញកន្លងមកនៅ អ.វ.ត.ក លើកលែងតែសម្រាប់ដីកាសម្រេចលើកលែងចោទប្រកាន់ មានការសន្និដ្ឋានទាំងនេះ។ សូម្បីតែដីកាដំណោះស្រាយសំណុំរឿង០០៤/១ ដែលរកមិនឃើញមានយុត្តាធិការបុគ្គលលើ អ៊ឹម ចែម បានរកឃើញអំពីឧក្រិដ្ឋកម្មដែលត្រូវបានបង្ហាញភស្តុតាង និងការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មទាំងនោះ។ ការសន្និដ្ឋានទាំងនេះគឺជាចំណុចសំខាន់នៃការវិភាគរបស់ សចស លើបញ្ហាយុត្តាធិការបុគ្គលទាក់ទងនឹង អ៊ឹម ចែម។ *សូមមើល* សំណុំរឿង០០៤/១-**D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ២៨១-៣២៥ ជើងទំព័រ ៧៣៥។ សពអ កត់សម្គាល់ថា រូបគាត់មិនទាន់មានឱកាសពិនិត្យមើលដីកាដំណោះស្រាយរបស់ សចសជ ក្នុងសំណុំរឿង ០០៣ នៅឡើយទេ ដោយសារតែកំពុងធ្វើការបកប្រែជាភាសាអង់គ្លេសនៅឡើយ ហើយហេតុនេះមិនបានដឹងថាតើវាមានសេចក្តីសន្និដ្ឋានអង្គច្បាប់ទាក់ទងនឹងឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវ ដែរឬទេ។

[11] សំណុំរឿង០០៤/១-**D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយក្នុងរឿងក្តី អ៊ឹម ចែម កថាខណ្ឌ ២៦ (សម្រេចជាឯកច្ឆ័ន្ទ) (គូសបញ្ជាក់បន្ថែម)។

[12] សំណុំរឿង០០១-**D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ (“សំណុំរឿង០០១ សាលដីកា អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំង ដីកាដំណោះស្រាយ”) កថាខណ្ឌ ៣៧-៣៨។ វិធាន ៦៧(៤)។

ចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ[13]។ ការវាយតម្លៃនេះត្រូវតែធ្វើឡើង "ផ្អែកទាំងស្រុងលើមូលដ្ឋាននៃរឿងក្តីនីមួយៗ" និងដូចដែល សចស បានទទួលស្គាល់នាពេលថ្មីៗនេះថា "វាពុំមានប្រយោជន៍អ្វីត្រូវអះអាងក្នុងន័យប្រវត្តិសាស្ត្រ និងនយោបាយដែលថា ការចរចាជុំវិញការបង្កើត អ.វ.ត.ក នាំឲ្យមានការយល់ឃើញតាមផ្លូវច្បាប់រួមថា មានតែបុគ្គល (មានឈ្មោះ) មួយចំនួនប៉ុណ្ណោះដែលត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ"[14]។

## ខ. បទដ្ឋាននៃភ័ស្តុតាងសម្រាប់ការបញ្ជូនរឿងទៅជំនុំជម្រះ

12. តាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង ត្រូវតែមាន "ភ័ស្តុតាងគ្រប់គ្រាន់ [...] នៃការចោទប្រកាន់" ដើម្បីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹងជនត្រូវចោទ។ សចស និង អបជ បានបញ្ជាក់ថា ត្រូវមាន "ភវនីយភាព" នៃពិរុទ្ធភាព ដែលលើសពី "គ្រាន់តែជាលទ្ធភាពកើតមាន" ប៉ុន្តែតិចជាងបទដ្ឋានស្តីពី "*វិមតិសង្ស័យ*" ដែលប្រើនៅពេលជំនុំជម្រះ[15]។ លើសពីនេះទៀត "ភ័ស្តុតាងនៅក្នុងសំណុំរឿងត្រូវមានលក្ខណៈរឹងមាំ និងស៊ីសង្វាក់គ្រប់គ្រាន់ ដើម្បីឲ្យមានតម្លៃជាភ័ស្តុតាងបន្ទាល់"[16]។

## IV. សេចក្តីសន្និដ្ឋាននៃបណ្តឹងឧទ្ធរណ៍

13. សចសជ មានកំហុសអង្គច្បាប់ និងអង្គហេតុ ក្នុងការយល់ឃើញថា អោ អាន មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។ កំហុសនេះផ្អែកលើកត្តាមួយចំនួន ដែលបានពិភាក្សាខាងក្រោម។

---

[13] សំណុំរឿង០០១-**E188** សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ២២ ("សាលក្រម *ឌុច*")។ *សូមមើលផងដែរ* សំណុំរឿង០០៤/១-**D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយក្នុងរឿងក្តី អ៊ឹម ចែម កថាខណ្ឌ ៣២១។ ឯកសារ ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៤ [បានទទួលស្គាល់ការណ៍នេះថាជាបទដ្ឋានដែលអាចអនុវត្តបាន]។

[14] សំណុំរឿង០០៤/១-**D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣៧-៣៨។

[15] សំណុំរឿង០០២-ឯកសារ-**D427** ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៣២៣។ សំណុំរឿង០០៤/១-**D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយក្នុងរឿងក្តី អ៊ឹម ចែម កថាខណ្ឌ ៦០-៦២។

[16] សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៣។

## ក. កំហុសអង្គច្បាប់នៃការខកខានមិនបានធ្វើការសន្និដ្ឋាននៅលើឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើង និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្មទាំងនោះ

### ១. ការគ្មានការសន្និដ្ឋានអំពីថាតើ ឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តឡើង ឬទេ និងថាតើ អោ អាន ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មណាមួយឬទេ

14. ការវាយតម្លៃអំពីអ្នកដែល “ទទួលខុសត្រូវខ្ពស់បំផុត” ចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក តម្រូវឲ្យមានការវាយតម្លៃទាំងស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ[17]។ ចៅក្រមជាតិ និងអន្តរជាតិនៃ អបជ បានសម្រេចជាឯកច្ឆ័ន្ទថា ដើម្បីអនុវត្តឲ្យបានត្រឹមត្រូវនូវមុខងារនៃការពិនិត្យមើលបណ្តឹងឧទ្ធរណ៍របស់ខ្លួន ទាក់ទងនឹងបញ្ហាយុត្តាធិការបុគ្គល ពួកគាត់ “ប្រាកដជាអាចពិនិត្យមើលលើសេចក្តីសន្និដ្ឋាននានាដែលនាំឲ្យមានការសម្រេចបែបនេះ រួមទាំងសេចក្តីសន្និដ្ឋានទាំងឡាយណាពាក់ព័ន្ធនឹងអត្ថិភាពនៃបទល្មើស ឬភាវនីយភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ [ជនសង្ស័យ]”[18]។ វិធាន ៦៧ នៃវិធានផ្ទៃក្នុងក៏តម្រូវផងដែរថា សចស សម្រេចលើរាល់អង្គហេតុដែលបានដាក់ជូនទៅពួកគាត់ ហេតុដូច្នេះការសន្និដ្ឋានទាំងនោះតម្រូវឲ្យមានសេចក្តីសម្រេចមានសំអាងហេតុ[19]។ ទោះបីជាយ៉ាងនេះក្តី ដីកាសម្រេចលើកលែងចោទប្រកាន់លើកឡើងយ៉ាងច្បាស់ថា ចំណុចនេះ “មិនមានភាពចាំបាច់ក្នុងការចាត់បទល្មើសទៅតាមអង្គហេតុ និងសរសេរបញ្ចូលនូវទម្រង់នៃការទទួលខុសត្រូវនោះទេ”[20]។ វិធីសាស្ត្រនេះ នាំឲ្យដីកាសម្រេចលើកលែងចោទប្រកាន់មិនមានសំអាងហេតុ និងមិនមានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់។

---

[17] សំណុំរឿង០០១-**E188** *សាលក្រម ឌុច,* កថាខណ្ឌ ២២។ *សូមមើលផងដែរ* សំណុំរឿង០០៤/១-**D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយក្នុងរឿងក្តី អ៊ឹម ចែម កថាខណ្ឌ ៣២១។ ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៤ [បានទទួលស្គាល់ចំណុចនេះថាជាបទដ្ឋានដែលត្រូវអនុវត្ត]។

[18] សំណុំរឿង០០៤/១-**D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយក្នុងរឿងក្តី អ៊ឹម ចែម កថាខណ្ឌ ២៦ (គូសបញ្ជាក់បន្ថែម)។

[19] សំណុំរឿង០០១-**D99/3/42** សំណុំរឿង០០១ សាលដីកា អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំង ដីកាដំណោះស្រាយ”) កថាខណ្ឌ ៣៧-៣៨។ វិធាន ៦៧(៤)។

[20] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២។

15. កំហុសនេះមិនមែនតូចទេ ហើយក៏មិនត្រូវបានកែតម្រូវដោយការពិភាក្សារបស់ដីកាសម្រេចលើកលែងចោទប្រកាន់ ដែលមានលក្ខណៈទូទៅ (មិនពេញលេញ) អំពីភស្តុតាងមួយផ្នែកក្នុងសំណុំរឿងនោះដែរ។ ឧទាហរណ៍ ដីកាសម្រេចលើកលែងចោទប្រកាន់ បានសន្និដ្ឋានថា របបកម្ពុជាប្រជាធិបតេយ្យមានគោលនយោបាយមជ្ឈិមបក្សក្នុងការកម្ទេចប្រជាជនចាមរបស់ខ្លួន[21] ថា អោ អាន ចេញបញ្ជាឲ្យថ្នាក់ក្រោមរបស់គាត់សម្លាប់ជនជាតិចាមទាំងអស់ក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់គាត់[22] និងថា ជនជាតិចាមជាច្រើនត្រូវបានសម្លាប់ដែលជាការឆ្លើយតបទៅនឹងបញ្ហាទាំងនេះ រួមបញ្ចូលទាំងជនជាតិចាមស្ទើតែទាំងអស់នៅក្នុងស្រុកកំពង់សៀម និងកងមាស[23]។ ទោះជាយ៉ាងណាក៏ដោយ ដីកានេះ *មិន* មានសេចក្ដីសន្និដ្ឋានផ្លូវច្បាប់ណាមួយចំពោះថាតើអង្គហេតុទាំងនេះបង្កើតបានជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងប្រសិនបើដូច្នោះមែន ថាតើភស្តុតាងបង្ហាញថា អោ អាន ទំនងជាទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនេះដែរឬទេ។ ការសន្និដ្ឋានទាំងនេះពិតជាមានផលប៉ះពាល់យ៉ាងខ្លាំងលើយុត្តាធិការបុគ្គល ដោយសារថា ប្រសិនបើ សចសជ បានសន្និដ្ឋានថា អោ អាន ទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលចំពោះអំពើប្រល័យពូជសាសន៍នោះ ត្រូវមានការពន្យល់ដោយមានសំអាងហេតុ និងលម្អិតអំពីមូលហេតុដែល ទោះបីជាមានសេចក្ដីសន្និដ្ឋាននេះក៏ដោយ អោ អាន មិនស្ថិតនៅក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យឡើយ។ ផ្ទុយមកវិញ ប្រសិនបើ សចសជ យល់ឃើញថា អង្គហេតុទាំងអស់នេះមិនបានបង្ហាញថា អំពើប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តឡើង ឬមិនបានបង្ហាញថា អោ អាន ទទួលខុសត្រូវនោះ ក៏ត្រូវមានការពន្យល់ដោយមានសំអាងហេតុ និងលម្អិត ចំពោះមូលហេតុដែលនាំឲ្យបែបនេះដែរ ដូចទៅនឹងការពិភាក្សាអំពីថាតើអង្គហេតុទាំងនេះមានតម្លៃស្មើនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ពាក់ព័ន្ធផ្សេងទៀត ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ឬការធ្វើទុក្ខបុកម្នេញ។ ដីកាដំណោះស្រាយមិនអាចគ្រាន់តែស្រង់យកផ្នែកមួយនៃភស្តុតាងពាក់ព័ន្ធទៅនឹងប្រធានបទជាក់លាក់ណាមួយនោះ

[21] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៤២-១៤៦។

[22] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១០-៤១៨។ ដោយសារតែការលើកឡើងដែលជាការស្មាន និងគ្មានសំអាងហេតុរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ អំពីភាពអាចជឿជាក់បានរបស់ ប្រាក់ យុត មានគោលបំណងជំទាស់ ឬធ្វើឲ្យចុះខ្សោយដល់ការសន្និដ្ឋានទាំងនេះ បញ្ហានេះត្រូវបានដោះស្រាយនៅក្នុងផ្នែក IV.ឃ.1 ខាងក្រោម។ យ៉ាងណាក៏ដោយ ចំណុចដែលថា ការអានដោយយកចិត្តទុកដាក់ទៅលើដីកាសម្រេចលើកលែងចោទប្រកាន់នេះ ធ្វើឲ្យមានភាពមិនច្បាស់លាស់ជាច្រើនចំពោះថាតើ ការសន្និដ្ឋានអ្វីពិតជាត្រូវបានធ្វើឡើងនោះ បញ្ជាក់អំពីតម្រូវការឲ្យមានសេចក្ដីសន្និដ្ឋានអង្គច្បាប់ដែលមានសំអាងហេតុដែលបណ្ដឹងឧទ្ធរណ៍នេះស្នើសុំ។

[23] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៧-៤១៤។

ខកខានមិនបានសន្និដ្ឋានដោយមានសំអាងហេតុ ហើយបន្ទាប់មក ងាកទៅប្រធានបទផ្សេងទៀត ដោយធ្វើលំៗនោះឡើយ។

16. នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ សចសជ ខ្លួនឯងផ្ទាល់បានទទួលស្គាល់ថា ការកំណត់ជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក តម្រូវឲ្យមានការវាយតម្លៃទាំងលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនត្រូវចោទ[24] ដោយនេះគឺជាការវាយតម្លៃមួយដែលគាត់មិនបានធ្វើ និងដែលត្រូវការជាចាំបាច់នូវសេចក្ដីសន្និដ្ឋានផ្លូវច្បាប់ដែលគាត់មិនបានធ្វើ។ គួរកត់សម្គាល់ថា ដីកាដំណោះស្រាយទាំងអស់របស់ អ.វ.ត.ក មកទល់ពេលនេះ រួមទាំងដីកាសម្រេចលើកលែងចោទប្រកាន់របស់ សចស ក្នុងសំណុំរឿង ០០៤/១ មានការសន្និដ្ឋាននានាទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង និងការទទួលខុសត្រូវរបស់ជនសង្ស័យចំពោះឧក្រិដ្ឋកម្មទាំងនោះ[25]។

## ២. ការគ្មានការសន្និដ្ឋានអង្គច្បាប់ដែលផ្អែកលើការសន្និដ្ឋានផ្នែកអង្គហេតុរបស់ដីកាសម្រេចលើកលែងចោទប្រកាន់

17. បើទោះជាដីកាសម្រេចលើកលែងចោទប្រកាន់មិនបានពិនិត្យឲ្យបានលម្អិតទៅលើភ័ស្តុតាងក្នុងសំណុំរឿងនេះ និងមិនមានការសន្និដ្ឋានផ្នែកអង្គហេតុដែលចេញពីការពិនិត្យទៅលើភ័ស្តុតាងគ្រប់ជ្រុងជ្រោយនោះ ក្នុងស្ថានភាពខ្លះ ដីកាសម្រេចលើកលែងចោទប្រកាន់នេះ ពិតជាមានការពិនិត្យទៅលើភ័ស្តុតាងមួយផ្នែក និងមានការសន្និដ្ឋានលើអង្គហេតុមួយចំនួន ដូចបានរៀបរាប់លម្អិតនៅក្នុងផ្នែកនេះ។ ទោះជាយ៉ាងណា សូម្បីតែនៅក្នុងស្ថានភាពទាំងនេះ ដីកាសម្រេចលើកលែងចោទប្រកាន់នេះមិនមានការសន្និដ្ឋានអង្គច្បាប់អំពីការប្រព្រឹត្តិឧក្រិដ្ឋកម្ម និងការទទួលខុសត្រូវរបស់ អោ អាន ដែលចេញពីការសន្និដ្ឋានផ្នែកអង្គហេតុនានារបស់ខ្លួន។

---

[24] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៥។ សំណុំរឿង០០៤/១-**D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ) ជើងទំព័រ ៧៣៥។ *សូមមើលផងដែរ* សំណុំរឿង០០១-**E188** សាលក្រម *ឌុច* កថាខណ្ឌ ២២។ សំណុំរឿង ០០៤/១-**D308/3/1/20** សេចក្ដីពិចារណារបស់ អ.ប.ជ ស្ដីពីដីកាដំណោះស្រាយក្នុងរឿងក្ដី អ៊ឹម ចែម កថាខណ្ឌ ៣២១។

[25] សចអ កត់សម្គាល់ថា រូបគាត់មិនទាន់មានឱកាសពិនិត្យមើលដីកាដំណោះស្រាយរបស់ សចសជ ក្នុងសំណុំរឿង ០០៣ នៅឡើយទេ ដោយសារតែកំពុងធ្វើការបកប្រែជាភាសាអង់គ្លេសនៅឡើយ អាស្រ័យហេតុនេះមិនបានដឹងថាតើវាមានសេចក្ដីសន្និដ្ឋានអង្គច្បាប់ទាក់ទងនឹងឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវ ដែរឬទេ។

18. *<u>មុខតំណែង និងសិទ្ធិអំណាចរបស់ អោ អាន៖</u>* ឧទាហរណ៍ ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា អោ អាន បានកាន់មុខតំណែងសំខាន់ៗជាច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយបានឡើងតួនាទីខ្ពស់បំផុតរបស់គាត់ជាលេខាតំបន់៤១ និងជាអនុលេខាភូមិភាគកណ្ដាល[26]។ ដីកានេះបានរកឃើញថា អោ អាន បានផ្ដល់ការបណ្ដុះបណ្ដាលគោលនយោបាយដល់កម្មាភិបាលក្នុងតំបន់ ៤១ បានរកឃើញថា គាត់ "គ្រប់គ្រង" តំបន់ ៤១ និងបានកំណត់ថាគាត់ "តែងមានវត្តមាន" ក្នុងតំបន់៤១[27]។ ដីកានេះរកឃើញថា អោ អាន បានទទួលបញ្ជាពី កែ ពក ថា "នៅតំបន់ហ្នឹង អាន មើលខ្មាំងចាប់ឲ្យឆាប់អស់" និងបានទទួលស្គាល់ភ័ស្តុតាងដែលថាមនុស្សរាប់ពាន់នាក់ត្រូវបានចាប់ខ្លួន និងសម្លាប់ចោលតាមបញ្ជាទាំងនេះ[28]។ ដីកានេះទទួលស្គាល់ថា គោលនយោបាយរបស់ អោ អាន គឺថា "អ្នកណាដែលតវ៉ាត្រូវបានចាប់ខ្លួន" និងថាអ្នកដែល នៅក្នុងតំបន់៤១ យល់ថា ផែនការលុបបំបាត់ខ្មាំងជា "ផែនការរបស់ តា អាន"[29]។

19. *<u>ទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុស៖</u>*[30] ដីកាសម្រេចលើកលែងចោទប្រកាន់រកឃើញថា ទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុស គឺជាគុកភូមិភាគដែលមានទីតាំងនៅជិតមន្ទីរស្រុកកំពង់សៀម[31] បានរក

---

[26] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៨៩-១៩៣, ១៩៩, ២៤២។

[27] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៥១-២៥២។

[28] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៦២។ បញ្ហាមួយក្នុងចំណោមបញ្ហាដដែលៗទាក់ទងនឹងដីកាសម្រេចលើកលែងចោទប្រកាន់នេះគឺ ទំនោររបស់ដីកានេះក្នុងការដកស្រង់ភ័ស្តុតាងត្រង់ចំណុចមួយ ដោយមិនបានបញ្ជាក់ឲ្យបានច្បាស់ថាតើភ័ស្តុតាងនេះត្រូវបានទទួលយក ឬត្រូវបានបដិសេធនោះទេ។ នៅពេលដែលការសំអាង និងការដកស្រង់ទាំងនេះត្រូវបានបង្ហាញក្នុងបរិបទរួមដែលធ្វើឲ្យក្លាយជាការសន្និដ្ឋានអង្គហេតុនោះ ការសំអាង និងការដកស្រង់ទាំងនេះក៏ត្រូវបានចាត់ទុកដូច្នោះដែរ។ ទោះជាយ៉ាងណា ភាពមិនច្បាស់លាស់នៃវិធីសាស្ត្រនេះបញ្ជាក់ពីតម្រូវការឲ្យមានការកំណត់ប្រភេទបទចោទ ដែលបណ្ដឹងឧទ្ធរណ៍នេះស្នើសុំ។

[29] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៥៩-២៦០។

[30] ដីកាសម្រេចលើកលែងចោទប្រកាន់លើកឡើងថា សចសអ បានដក វត្តភ្នំប្រុស ចេញពីសំណុំរឿង បានឈប់ធ្វើការស៊ើបអង្កេតនៅទីនោះ ហើយ សពអ មិនបានជំទាស់ទេ (*សូមមើល* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥០៥)។ ចំណុចនេះមិនត្រឹមត្រូវឡើយ។ សចសអ បានជូនដំណឹងដល់ភាគីទាំងឡាយថា ការចោទប្រកាន់នានាទាក់ទងនឹងការចោទប្រកាន់ពីរក្នុងចំណោមការចោទប្រកាន់ទាំងឡាយនៅវត្តភ្នំប្រុស ដែលជា ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទុក្ខបុកម្នេញ នឹងមិនត្រូវធ្វើការស៊ើបអង្កេតបន្ថែមទៀតទេ ដោយសារតែស្ថិតនៅក្រោមវិធាន ៦៦*ស្ទួន* (*សូមមើល* ឯកសារ **D307/3** សេចក្ដីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ កថាខណ្ឌ១ (អង្គហេតុ៥) ១៣(ឃ), ២២, ២៣)។ សពអ មិនបានជំទាស់ទៅនឹងការកាត់បន្ថយបទចោទប្រកាន់បណ្ដោះអាសន្ននោះទេ ដោយសារតែអង្គហេតុដែលនៅសេសសល់ត្រូវបានមានភាពតំណាងគ្រប់គ្រាន់ហើយ (*សូមមើល* ឯកសារ **D307/4/1** ចម្លើយ

ឃើញថា អ្នកទោសដែលត្រូវបានយកទៅកាន់ភ្នំប្រុស ត្រូវបានសម្លាប់ចោលភ្លាមៗ ដោយមិនមានការឃុំខ្លួនមុនពេលសម្លាប់ពួកគេឡើយ[32] និងបានរកឃើញថា ជនរងគ្រោះដល់ទៅ ១០០.០០០ នាក់ អាចត្រូវបានសម្លាប់នៅទីនោះ[33]។ ដីកាសម្រេចលើកលែងចោទប្រកាន់រកឃើញថា ទីតាំងនេះស្ថិតក្រោមការគ្រប់គ្រងរបស់ កែ ពក ដែលពេលខ្លះបានមកមើលទីតាំងនេះ[34] ប៉ុន្តែ ក៏បានទទួលស្គាល់ភ័ស្តុតាងមកពីកូនប្រុសរបស់ កែ ពក ថា អោ អាន បានចេញបញ្ជាឱ្យសម្លាប់នៅភ្នំប្រុស[35] (ទោះបីជាដីកាសម្រេចលើកលែងចោទប្រកាន់ក្រោយមកបានចោទសួរពីភាពអាចជឿជាក់បានរបស់ កែ ពេជ្រវណ្ណៈ លើចំណុចនេះក្តី)[36]។

20. *__មន្ទីរសន្តិសុខវត្តអូរត្រកួន៖__* ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា អ្នកទោសនៅមន្ទីរសន្តិសុខវត្តអូរត្រកួនត្រូវបានឃុំខ្លួនក្នុងអគារវត្ត[37] អ្នកទោសប្រុសជាប់ខ្នោះជើង[38] អ្នកទោសត្រូវបានបែងចែកជាអ្នកទោសស្រាល និងអ្នកទោសធ្ងន់[39] អ្នកទោសធ្ងន់មិនត្រូវបានដោះលែងឡើយ និង "ត្រូវបានយកទៅសម្លាប់"[40] អ្នកទោសត្រូវ "ធ្វើទារុណកម្មយ៉ាងខ្លាំង" ដើម្បីយក

---

តបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុលោមតាមវិធាន ៦៦ *ស្ទួន* (២) ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ២) និង នៅពេលដែល សចស បានបញ្ចប់ការស៊ើបអង្កេត សចសអ បានប្រើប្រាស់វិធាន ៦៦*ស្ទួន* ដើម្បីកាត់បន្ថយបទចោទប្រកាន់ជាផ្លូវការ ដោយបានដកចេញអង្គហេតុនានាដែលត្រូវបានផ្អាកជាបណ្តោះអាសន្នទាំងនោះ (*សូមមើល* ឯកសារ **D337** ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ កថាខណ្ឌ៤, ១៣)។ ទោះជាយ៉ាងណា បទចោទសម្រាប់អំពើមនុស្សឃាតការសម្លាប់រង្គាល និងមនុស្សឃាតគិតទុកជាមុន នៅតែមានសម្រាប់វត្តភ្នំប្រុស។ ទីតាំងនេះមិនត្រូវបាន "ដកចេញ" ពីសំណុំរឿងឡើយ (*សូមមើល* ឯកសារ **D303** កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀត ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ EN 01213487-89)។

[31] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ២៨៩។

[32] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩០។

[33] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩៧។

[34] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩៣-២៩៦។

[35] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩២។

[36] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥០៥។

[37] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០០។

[38] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០០។

[39] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៣។

[40] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៣។

ចម្លើយសារភាព[41] អ្នកទោសជាទូទៅត្រូវបានសម្លាប់ជាក្រុមម្តង ១០ នាក់[42]។ យ៉ាងហោចណាស់ក្នុងករណីមួយ ការដាំដុះដំណាំដើម្បីជាអាហារផ្ទាល់ខ្លួន ត្រូវបានចាត់ទុកថាជាកំហុសធ្ងន់ល្មមក្នុងការនាំទៅសម្លាប់ចោល[43] ហើយការសម្លាប់ភាគច្រើនបានធ្វើឡើងនៅក្នុងឆ្នាំ១៩៧៧ ដោយមានជនជាតិចាមត្រូវបានសម្លាប់ ជាពិសេសក្នុងខែ កញ្ញា និង តុលា ឆ្នាំ១៩៧៧[44] និងថា ចំនួនមនុស្សដែលត្រូវបានសម្លាប់សរុបនៅមន្ទីរសន្តិសុខនេះ អាចលើសចំនួននៃការសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ទៅទៀត និងអាចលើស ៣០.០០០ នាក់[45]។

21. *ចាមនៅមន្ទីរសន្តិសុខវត្តអូរត្រកួន៖* ទាក់ទងនឹងជនរងគ្រោះចាមនៅមន្ទីរសន្តិសុខវត្តអូរត្រកួន ដីកាសម្រេចលើកលែងចោទប្រកាន់រកឃើញថា មានផែនការសម្លាប់ "ក្រុមចាមទាំងអស់"[46] បានរកឃើញថា ជនជាតិចាមស្ទើតែទាំងអស់នៅក្នុងស្រុកកងមាសត្រូវបានសម្លាប់ចោល[47] និងបានរកឃើញថា ក្នុងខែ កញ្ញា និង តុលា ឆ្នាំ១៩៧៧ (នៅពេលដែលដីកាសម្រេចលើកលែងចោទប្រកាន់ទទួលស្គាល់ថា អោ អាន បានធ្វើជាលេខាតំបន់ ៤១ រួចទៅហើយនោះ[48]) គឺជាពេលដែលមានការសម្លាប់ជនជាតិចាមច្រើននៅវត្តអូរត្រកួន[49]។

22. *មន្ទីរសន្តិសុខវត្តបាធាយ៖* ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា មួយផ្នែកធំនៃទីតាំងជិតពីរហិកតាត្រូវបានប្រើដើម្បីកប់សាកសពនៅមន្ទីរសន្តិសុខវត្តបាធាយ[50] ដោយចំណុចនេះបង្ហាញអំពីកម្រិតនៃការសម្លាប់នៅទីនោះ បានរកឃើញថា ចំនួនមនុស្សសរុបដែលត្រូវបាន

[41] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៣។

[42] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៤។

[43] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៤។

[44] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៥។ ដីកាសម្រេចលើកលែងចោទប្រកាន់ទទួលស្គាល់ថា អោ អាន ជាលេខាតំបន់ ៤១ នៅពេលនេះ។ *សូមមើល* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២០៣, ២៤២។

[45] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣១១។

[46] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៧។

[47] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៧។

[48] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២០៣, ២៤២។

[49] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៥។

[50] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣១៣។

សម្លាប់ត្រូវបានប៉ាន់ប្រមាណថា "រាប់ពាន់នាក់ ឬប្រហែល ម៉ឺននាក់"[51] បានរកឃើញថា កម្រិតនៃការចាប់ខ្លួនគឺថា អ្នកទោសត្រូវបានរក្សាទុកតែមួយយប់ប៉ុណ្ណោះ ហើយត្រូវសម្លាប់ចោលនៅថ្ងៃបន្ទាប់ ដើម្បីជៀសវាងកុំឱ្យចង្អៀតគុក[52] បានរកឃើញថា អ្នកទោសជាប់ខ្នោះជើង និងរងការធ្វើទារុណកម្មយ៉ាងឃោរឃៅ[53] បានរកឃើញថា ក្នុងឆ្នាំ១៩៧៨ មានការសម្លាប់ជនជាតិចាម (រួមទាំង កូនក្មេង) និងប្រជាជនបូព៌ា ក្នុងរយៈពេលខ្លីមួយ[54] បានរកឃើញថា អ្នកទោសដែលបញ្ជូនទៅកាន់វត្តបាធាយស្ទើតែទាំងអស់ត្រូវបានសម្លាប់ ("កម្ររស់ណាស់")[55] បានរកឃើញថា សរីរាង្គខ្លះរបស់អ្នកទោសត្រូវបានប្រមូលក្រោយពេលសម្លាប់[56] បានរកឃើញថា លេខាស្រុកបាធាយ ឈ្មោះ ភឹម "តែងតែឃើញចេញចូល" មន្ទីរសន្តិសុខនេះ[57] និងបានរកឃើញថា ប្រមាណ ១០ ភាគរយនៃចំនួនជនរងគ្រោះសរុបគឺជាជនជាតិចាម[58]។

23. <u>*មន្ទីរសន្តិសុខមិត្តសុប/គៈ*</u> ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា អ្នកទោសនៅមន្ទីរសន្តិសុខមិត្តសុប/គ ជាប់ខ្នោះជើង និងខ្នោះដៃជាក្រុម ហើយ "តែងទទួលរងនូវការធ្វើទារុណកម្ម" ក្នុងពេលសួរចម្លើយ[59] បានរកឃើញថា អ្នកទោសភាគច្រើនត្រូវបានគេសម្លាប់ដោយដំបងឈើ ឬដែក ខណៈដែលអ្នកខ្លះទៀតបានស្លាប់ដោយសារជំងឺ[60] បានរកឃើញថា ការសម្លាប់ត្រូវបានធ្វើឡើងតាមបញ្ជារបស់ តា អាន និង តា ង៉ូវ ដែលជាប្រធានមន្ទីរសន្តិសុខ និងជាអ្នកក្រោមបង្គាប់ តា អាន[61] បានរកឃើញថា តា អាន បានមកមើលមន្ទីរសន្តិសុខនេះ

---

[51] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២២។

[52] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣១៥។

[53] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣១៦, ៣១៨។

[54] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣១៧។

[55] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣១៨។

[56] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២០។

[57] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២១។

[58] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២១។

[59] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២៧។

[60] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៣០-៣៣១។

[61] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២៨-៣៣០។

(ដែលជាគុកតំបន់) "ជាច្រើនលើក"[62] និងថា អ្នកទោសសរុបប្រមាណ ២.០០០ នាក់ ត្រូវបានសម្លាប់ ឬបានស្លាប់ដោយសារជំងឺនៅទីនោះ[63]។

24. ***ទីតាំងសម្លាប់មនុស្សគោកព្រីង៖*** ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា ការសម្លាប់នៅទីតាំងសម្លាប់មនុស្សគោកព្រីងបានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៧០ និងបានបន្តមកក្រោយពេលក្រុមកម្មាភិបាលមកពីភូមិភាគនិរតីមកដល់ក្នុងឆ្នាំ១៩៧៧[64] បានរកឃើញថា រយៈពេលនៃការបាត់ខ្លួន "ខ្លាំង" នៅគោកព្រីងបានចាប់ផ្តើមនៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ ដោយមានមនុស្សពី ២០ ទៅ ៥០ នាក់ ត្រូវបានសម្លាប់នៅទីនោះរៀងរាល់យប់[65] និងបានរកឃើញថា ការប៉ាន់ប្រមាណពីចំនួនសរុបនៃមនុស្សដែលត្រូវបានសម្លាប់នៅគោកព្រីងមានចំនួនពី ១.០០០ ទៅ ៧.០០០នាក់[66]។

25. ***មន្ទីរសន្តិសុខវត្តអង្គញដី និងទីតាំងសម្លាប់មនុស្សទួលបេង៖*** ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា មន្ទីរសន្តិសុខវត្តអង្គញដី ត្រូវបានប្រើដើម្បីឃុំឃាំងទាំងជនជាតិខ្មែរ និងជនជាតិចាម មកពីស្រុកកំពង់សៀម[67] បានរកឃើញថា អ្នកទោសជាប់ខ្នោះជើង និង "តែងត្រូវបានគេធ្វើទារុណកម្ម" ក្នុងពេលសួរចម្លើយ[68] បានរកឃើញថា អ្នកទោស ជាទូទៅ ត្រូវបានឃុំខ្លួនមួយរយៈពេលខ្លីមុនពេលយកទៅកាន់កន្លែងផ្សេងដើម្បីសម្លាប់ចោល ជាញឹកញាប់យកទៅទួលបេង ប៉ុន្តែ អ្នកទោសខ្លះត្រូវបានសម្លាប់នៅវត្តអង្គញដី[69] និងបានរកឃើញថា មន្ទីរសន្តិសុខនេះគឺជាគុកស្រុកកំពង់សៀមដែលស្ថិតក្រោមការគ្រប់គ្រងរបស់ ប្រាក់ យុត[70]។ ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា ទីតាំងសម្លាប់មនុស្សទួលបេងគឺជាទីតាំងសម្លាប់មនុស្សរបស់ស្រុកកំពង់សៀម ស្ថិតក្រោមការគ្រប់គ្រងរបស់ ប្រាក់ យុត[71] ដែលមានសមត្ថភាពដាក់អ្នក

[62] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២៣, ៣២៨។

[63] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៣១។

[64] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៣២។

[65] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៣៣។

[66] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៣៦។

[67] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៩០។

[68] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៨៨។

[69] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៨៧។

[70] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៨៧, ៣៨៩។

[71] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៩២, ៣៩៦។

ជាប់ឃុំម្តងប្រមាណ ២០០នាក់ ហើយអ្នកដែលត្រូវបាននាំមកសម្លាប់នៅទួលបេង ត្រូវបានឃុំនៅទីនោះមួយរយៈពេលខ្លីមុនពេលសម្លាប់[72]។ ការសម្លាប់នៅទួលបេង បានកើនឡើងយ៉ាងខ្លាំងក្នុងឆ្នាំ១៩៧៨ ហើយជនរងគ្រោះមានទាំង "ជនជាតិចាមជាច្រើននាក់"[73]។ មនុស្សរាប់ពាន់នាក់អាចត្រូវបានគេសម្លាប់នៅទួលបេងនេះ[74]។

26. <u>*មន្ទីរសន្តិសុខវត្តតាមះ៖*</u> ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា វត្តតាមះ គឺជាមន្ទីរសន្តិសុខតំបន់ ដែលគ្រប់គ្រងដោយថ្នាក់ក្រោមរបស់ អោ អាន ឈ្មោះ អួន ដែលក៏ជាអ្នកអនុវត្តបញ្ជាឲ្យចាប់ខ្លួន និងដឹកជញ្ជូនអ្នកទោសទៅកាន់មន្ទីរសន្តិសុខនេះផងដែរ[75] បានរកឃើញថាអ្នកទោសត្រូវបានចាប់ខ្លួន និងដឹកមកកាន់វត្តតាមះជារៀងរាល់ថ្ងៃ[76] បានរកឃើញថា អ្នកទោសត្រូវបាន "ធ្វើទារុណកម្មជាខ្លាំង" និងជាប់ខ្នោះជើង ដាក់ច្រវ៉ាក់ ឬចង ក្នុងពេលឃុំឃាំង[77] បានរកឃើញថា អ្នកទោសត្រូវបានប្រមូលផ្តុំ និងសម្លាប់នៅក្នុងវាលមួយនៅវត្តតាមះ[78] និងបានរកឃើញថា តា អាន បានទទួលព័ត៌មានជាប្រចាំអំពីវត្តតាមះ និងបានចូលរួមប្រជុំដោយផ្ទាល់នៅទីនោះ[79]។

27. <u>*ការដ្ឋានទំនប់អន្លង់ជ្រៃ៖*</u> ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា ទំនប់អន្លង់ជ្រៃគឺជាការដ្ឋានតំបន់ និងថា អោ អាន បានត្រួតពិនិត្យមើលការដ្ឋាននេះ និងបានចោទប្រកាន់កម្មករនៅទីនោះថាបានស៊ើបការណ៍សម្ងាត់ឲ្យ សេ.អ៊ី.អា និងវៀតណាម[80]។ ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានធ្វើការសន្និដ្ឋានអំពីលក្ខខណ្ឌនៅទីតាំងនោះ ឬឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅទីនោះទេ។

---

[72] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៩៤។

[73] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៩៥។

[74] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៩៥។

[75] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៤២។

[76] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៤៩។

[77] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៤៥។

[78] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៤៦។

[79] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៤៨។

[80] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៣៧-៣៣៨។

28. *ការរកឃើញទាក់ទងនឹងអំពើប្រល័យពូជសាសន៍ចាម៖* ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា អោ អាន បានបញ្ជា ប្រាក់ យុត និងលេខាស្រុកទាំងអស់ក្នុងតំបន់៤១ ឲ្យចាប់ជនជាតិចាមទាំងអស់ដែលស្ថិតក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់ខ្លួន[81] បានរកឃើញថា អោ អាន បានបញ្ជាឲ្យ ប្រាក់ យុត សម្លាប់ជនជាតិចាមទាំងអស់ក្នុងស្រុករបស់គាត់[82] បានរកឃើញថា ភាគច្រើននៃជនជាតិចាមនៅក្នុងស្រុកកំពង់សៀមត្រូវបានសម្លាប់តាមបញ្ជាទាំងនេះ[83] បានរកឃើញថា ក្រោយពីការសម្លាប់ទាំងនេះ ប្រាក់ យុត បានរាយការណ៍ត្រឡប់ទៅ តា អាន វិញ[84] បានរកឃើញថា ភាគច្រើននៃជនជាតិចាមនៅក្នុងស្រុកកងមាសក៏ត្រូវបានសម្លាប់ផងដែរតាមកម្មវិធីរៀបចំទុកមួយ[85] បានរកឃើញថា ប្រមាណ ១០% នៃជនរងគ្រោះរាប់ពាន់ដែលត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តបាធាយគឺជាជនជាតិចាម[86] និងបានរកឃើញថា "ជនជាតិចាមជាច្រើននាក់" ស្ថិតក្នុងចំណោមជនរងគ្រោះរាប់ពាន់នាក់ដែលត្រូវបានសម្លាប់នៅទីតាំងសម្លាប់មនុស្សទួលបេង[87]។

29. *ការរកឃើញទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ៖* ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា "អង្គការ" ជាប្រចាំបានរៀបចំអាពាហ៍ពិពាហ៍នៅក្នុងស្រុកកំពង់សៀម ទាំងនៅមុន និងក្រោយពេលកម្មាភិបាលភូមិភាគនិរតីមកដល់[88] បានរកឃើញថា សមាជិកកងចល័តនៅក្នុងស្រុកព្រៃឈរត្រូវបានបង្ខំឲ្យរៀបការ និងមិនមានអ្នកណាម្នាក់ហ៊ានជំទាស់ទៅនឹងការណែនាំទាំងនេះឡើយ ដោយខ្លាចត្រូវសម្លាប់ចោល[89] បានរកឃើញថា មិនមានអ្នកណាម្នាក់ហ៊ានបដិសេធ

[81] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១០។

[82] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១០-៤១២, ៤១៥។ ក្នុងវិសាលភាពដែលថាការទាយស្មាន និងការពិភាក្សាគ្មានសំអាងហេតុអំពីភាពអាចជឿជាក់បានរបស់ ប្រាក់ យុត ក្រោយមកទៀតនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ មានគោលបំណងជំទាស់ ឬធ្វើឲ្យចុះខ្សោយការរកឃើញជាក់ស្តែងទាំងនេះ បញ្ហានេះត្រូវបានដោះស្រាយនៅក្នុងផ្នែក IV.ឃ.1។

[83] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១៣-៤១៥។

[84] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១៥-៤១៦។

[85] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៧។

[86] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២១-៣២២។

[87] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៩៥។

[88] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៩៧, ៤០៦-៤០៨។

[89] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤០៦។

អាពាហ៍ពិពាហ៍ដែលរៀបចំឡើងដោយអង្គការឡើយ ពីព្រោះពួកគេ "ខ្លាចគេយកទៅសម្លាប់"[90] និងបានរកឃើញថា អោ អាន បានបញ្ជាឲ្យអ្នកដែលទើបតែរៀបការថ្មីរួមភេទ ហើយអ្នកណាដែលមិនបានធ្វើតាមនឹងត្រូវកសាង បង្អត់អាហារ ឬសម្លាប់ចោល[91]។

30. ឧក្រិដ្ឋកម្មដែលបានរៀបរាប់ទាំងអស់ខាងលើនេះបានកើតមានឡើងនៅក្នុងតំបន់៤១ ជាទីកន្លែងដែល អោ អាន បានបម្រើការជាលេខាស្រុក ដែលមានសិទ្ធិអំណាចខ្ពស់បំផុតក្នុងការដឹកនាំខ្មែរក្រហមក្នុងតំបន់នោះ។ យ៉ាងហោចណាស់ ការរកឃើញទាំងនេះបង្ហាញថា ការស៊ើបអង្កេតបានកំណត់ភវនីយភាពដែល អោ អាន ទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ដែលជាអំពើអមនុស្សធម៌ផ្សេងៗទៀត។ សពអ សន្និដ្ឋានថា ការរកឃើញទាំងនេះតែឯង បង្ហាញថា អោ អាន ស្ថិតក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ។

31. ដើម្បីឲ្យច្បាស់ ស.ព.អ រក្សាការយល់ឃើញរបស់ខ្លួនថា ភ័ស្តុតាងនៅក្នុងសំណុំរឿងនេះបង្ហាញថា អោ អាន ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ និងមិនមែនត្រឹមតែឧក្រិដ្ឋកម្មនានា ដែលត្រូវបានលើកឡើងនៅក្នុងការសន្និដ្ឋានផ្នែកអង្គហេតុមួយចំនួននោះឡើយ។ ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយជាញឹកញាប់ខកខានមិនបានបញ្ចូលការសន្និដ្ឋាននានាស្តីពីការចូលរួម និងការទទួលខុសត្រូវរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្មទាំងនេះទេ[92]។

---

[90] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤០៦។

[91] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤០៥។

[92] ការរកឃើញទាំងនេះទាក់ទងនឹងឧក្រិដ្ឋកម្មនានាក្នុងតំបន់៤១ មានសេចក្តីលម្អិតសំខាន់ៗ ប៉ុន្តែជាញឹកញាប់ខកខានមិនបានដាក់បញ្ចូលការរកឃើញអំពីការចូលរួមប្រព្រឹត្ត និងការទទួលខុសត្រូវរបស់ អោ អាន ។ ឧទាហរណ៍មួយនៃបញ្ហានេះទាក់ទងនឹងមន្ទីរសន្តិសុខវត្តអូរត្រកួន និងមន្ទីរសន្តិសុខវត្តបាធាយ។ នៅវត្តអូរត្រកួន ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា បញ្ជាឲ្យសម្លាប់ត្រូវបានចេញដោយប្រធានមន្ទីរសន្តិសុខនោះ ដែលជាអ្នកក្រោមបង្គាប់មិនផ្ទាល់របស់ អោ អាន។ ទាក់ទងទៅនឹងការរកឃើញរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ ដែលថាបញ្ជាឲ្យសម្លាប់ត្រូវតែចេញមកពីថ្នាក់ភូមិភាគ ឬខាងលើ និងថា បញ្ជា និងការណែនាំរបស់របបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានបញ្ជូនចុះក្រោមតាមរយៈ "ភាគច្រើនខ្សែឈរនៃការទំនាក់

## ខ. ការកំហុសអង្គច្បាប់ និងអង្គហេតុដោយការផ្ដល់ទម្ងន់ច្រើនទៅលើការបង្ខិតបង្ខំ ការគាបសង្កត់ និងបញ្ជាថ្នាក់លើ

### ១. ដីកាសម្រេចលើកលែងចោទប្រកាន់ផ្ដល់ទម្ងន់ច្រើនហួសទៅលើបញ្ជាថ្នាក់លើការគាបសង្កត់ និងការបង្ខិតបង្ខំ ក្នុងការវិភាគអំពីយុត្តាធិការបុគ្គល

32. ការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា អោ អាន មិនបានស្ថិតនៅក្នុងប្រភេទជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានផ្ដោតជាសំខាន់ទៅលើអង្គហេតុដែលថា អោ អាន (i) ស្ថិតក្រោមបញ្ជាថ្នាក់លើ (ii) ត្រូវបានចាត់ឲ្យអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក") និង (iii) បំពេញមុខងារក្នុងប្រព័ន្ធបង្ខិតបង្ខំដែលបានបង្កើតឡើងដោយ ប.ក.ក និងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្លឹមសារនេះលើកឡើងដដែលៗជាញឹកញាប់ក្នុងដីកាសម្រេចលើកលែងចោទប្រកាន់[93] និងលើកឡើងយ៉ាងសំខាន់បំផុតនោះនៅក្នុងកថាខណ្ឌពីរ ដែលដីកាសម្រេចលើកលែងចោទប្រកាន់ផ្ដល់សេចក្ដី

---

ទំនងក្នុងខ្សែសង្វាក់នៃការបញ្ជា" ការបកស្រាយដ៏សមហេតុផលតែមួយនោះគឺថា បញ្ជាឲ្យធ្វើការសម្លាប់នៅមន្ទីរសន្តិសុខវត្តអូរត្រកួន ត្រូវបានបញ្ជូនចុះក្រោមដោយ អោ អាន ទៅកាន់លេខាស្រុកកងមាស ហើយបន្ទាប់មកបន្តទៅប្រធានមន្ទីរសន្តិសុខវត្តអូរត្រកួន។ ប៉ុន្តែ ទោះបីជាអង្គហេតុដែលថា ចំណុចនេះគឺជាការសន្និដ្ឋានសមហេតុផលតែមួយគត់លើការរកឃើញផ្ទាល់របស់ដីកាសម្រេចលើកលែងចោទប្រកាន់យ៉ាងណាក៏ដោយ ក៏ដីកាសម្រេចលើកលែងចោទប្រកាន់នេះខកខានមិនបានរក ឃើញថា អោ អាន បានចេញបញ្ជាទាំងនេះដែរ។ *សូមមើល* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១០៥-១០៦, ២១៤-២១៦, ២៦១, ៣១០, ៤៦៦។ ស្រដៀងគ្នានេះដែរ ទាក់ទងនឹងមន្ទីរសន្តិសុខវត្តបាធាយ ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា លេខស្រុកបាធាយឈ្មោះ ភឹម ដែលជាអ្នកក្រោមបង្គាប់ផ្ទាល់របស់ អោ អាន (យ៉ាងហោចបំផុត) មានតួនាទីគ្រប់គ្រងដ៏ធំដំនៅទីនោះ និងថា មនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់នៅទីនោះ។ ជាថ្មីម្ដងទៀត ជាការសមហេតុផលដូចគ្នានេះដែរ ការបកស្រាយដ៏សមហេតុផលតែមួយគត់លើការរកឃើញរបស់ដីកាសម្រេចលើកលែងចោទប្រកាន់គឺថា បញ្ជានានាឲ្យសម្លាប់នៅមន្ទីរសន្តិសុខវត្តបាធាយត្រូវបានបញ្ជូនចុះក្រោមពី អោ អាន ទៅកាន់ ភឹម (ហើយបន្ទាប់មក ទៅកាន់បុគ្គលិកមន្ទីរសន្តិសុខ)។ ប៉ុន្តែ ដីកាសម្រេចលើកលែងចោទប្រកាន់ខកខានមិនបានមានសេចក្ដីសន្និដ្ឋានដែលមានទាំងអស់នេះទេ។ *សូមមើល* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១០៥-១០៦, ២១៤-២១៦, ៣២១, ៤៦៦។ ការមិនបានរកឃើញថា អោ អាន ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការសម្លាប់ទាំងនេះ មានសារសំខាន់ខ្លាំងចំពោះការវិភាគអំពីយុត្តាធិការបុគ្គល ដូចដែលដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា ជនរងគ្រោះដល់ទៅ ៤០.០០០ នាក់ អាចត្រូវបានសម្លាប់នៅទីនោះ។ *សូមមើល* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣១១, ៣២២។

[93] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៩៦, ៤៩៩-៥០១, ៥១០-៥១១, ៥១៩, ៥២៨, ៥៣៣, ៥៣៥, ៥៤៦-៥៤៧, ៥៥២-៥៥៣។

សន្និដ្ឋានបញ្ចប់អំពីយុត្តាធិការបុគ្គល។ ត្រង់កន្លែងនោះ ដីកាសម្រេចលើកលែងចោទប្រកាន់សង្កត់ធ្ងន់ថា មិនមានយុត្តាធិការបុគ្គលលើ អោ អាន ទេ ពីព្រោះ "គាត់ត្រូវបានធ្វើឡើងតាមបញ្ជា និងការណែនាំរបស់ កែ ពក ដែលស្ថិតនៅគ្រប់គ្រងដឹកនាំភូមិភាគកណ្តាល" និង "ប្រសិនបើ [គាត់] មានការប្រឆាំងជំទាស់ [គាត់] នឹងមិនរួចផុតពីសេចក្តីស្លាប់ឡើយ"[94]។ ដីកាក៏បានសង្កត់ធ្ងន់ផងដែរថា "អោ អាន មិនបានចូលរួមធ្វើគោលនយោបាយរបស់ ប.ក.ក ឡើយ"[95]។

33. ជនជាប់ចោទមួយចំនួនដែលត្រូវបានបញ្ជូនទៅជំនុំជម្រះនៅ អ.វ.ត.ក បានអះអាងថា ពួកគេគ្រាន់តែធ្វើតាមបញ្ជាប៉ុណ្ណោះ និងភ័យខ្លាចអំពីសុវត្ថិភាពរបស់ខ្លួន ប្រសិនបើពួកគេមិនគោរពតាម។ ខៀវ សំផន បានអះអាងថា រូបគាត់មិនឯកភាពតាមផ្នែកមួយចំនួននៃគោលនយោបាយរបស់ ប.ក.ក ប៉ុន្តែ និយាយថា "ខ្ញុំមិនអាចនៅរស់រានមានជីវិតបានទេ ប្រសិនបើខ្ញុំហ៊ានលើកឡើងពីការជំទាស់ណាមួយនោះ"[96]។ ដូចបានបង្ហាញខាងក្រោម ឌុច បានសំដែងការភ័យខ្លាចរបស់គាត់ក្នុងពាក្យពេចន៍ដ៏ច្បាស់លាស់[97]។ សូម្បីតែ នួន ជា បានប្រាប់អ្នកនិពន្ធជីវប្រវត្តិរបស់គាត់ថា រូបគាត់ភ័យខ្លាចគេហៅថាជាខ្មាំង បន្ទាប់ពីមានកម្មាភិបាលដឹកនាំជាច្រើនបានបាត់ខ្លួន[98]។ ប្រសិនបើការធ្វើតាមបញ្ជា បានដកមនុស្សម្នាក់ចេញពីក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យមែននោះ មិនមាននណាម្នាក់ត្រូវបានវិនិច្ឆ័យទោសនោះឡើយ ដោយសារតែទាំងអស់គ្នាអាចអះអាងថា ប៉ុល ពត នៅពីលើពួកគេ និងមិនអត់ឱនចំពោះការជំទាស់ណាមួយឡើយ។

34. តាមពិតនោះគោលការណ៍ជាមូលដ្ឋានដែលថាជនទាំងឡាយដែលអនុវត្តតាមបញ្ជាថ្នាក់លើដែលខុសច្បាប់យ៉ាងជាក់ស្តែងនោះ នៅតែទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មណាមួយដែលពួកគេបានប្រព្រឹត្ត។ គោលការណ៍នេះត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងច្បាប់ទម្លាប់អន្តរជាតិ[99] និងច្បាប់

---

[94] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥៥២-៥៥៣។

[95] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥៥៣។

[96] ឯកសារ **D6.1.1036** កំណត់ហេតុស្ដួរចម្លើយ ខៀវ សំផន EN 00156757។

[97] *សូមមើល* ផ្នែក IV.ខ.4 *ខាងក្រោម*។

[98] ឯកសារ **D219/370.1.7** Gina Chon & ថេត សម្បត្តិ *នៅពីក្រោយវាលពិឃាត* EN 00757519។

[99] *សូមមើល ឧទាហរណ៍* ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ – ឧបសម្ពន្ធទៅនឹងកិច្ចព្រមព្រៀងសម្រាប់ការកាត់ទោស និងការដាក់ទណ្ឌកម្មឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៅអឺរ៉ុប ("កិច្ចព្រមព្រៀងទីក្រុងឡុងដ៍") ទីក្រុងឡុងដ៍ ៨២ UNTS 279 ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៤៥ ("ធម្មនុញ្ញ Nuremberg") មាត្រា ៨ ["ការពិតដែលថា ចុងចោទបានបានធ្វើសកម្មភាពអនុលោមតាម

បញ្ជារបស់រដ្ឋាភិបាលរបស់ខ្លួន ឬថ្នាក់លើណាម្នាក់នោះ មិនត្រូវរួចខ្លួនពីការទទួលខុសត្រូវឡើយ ប៉ុន្តែអាចត្រូវបានពិចារណាបន្ធូបន្ថយទណ្ឌកម្ម ប្រសិនបើតុលាការកំណត់ថាត្រូវធ្វើបែបនោះ។"] ច្បាប់គ្រប់គ្រងក្រុមប្រឹក្សាលេខ ១០ ការដាក់ទណ្ឌកម្មបុគ្គលដែលមានពិរុទ្ធភាពឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៤៥ ("ច្បាប់គ្រប់គ្រងក្រុមប្រឹក្សាលេខ ១០") មាត្រា II(៤)(ខ)។ ធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៤៦ ("ធម្មនុញ្ញតូក្យូ") មាត្រា ៦។ *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធាអន្តរជាតិ ក្រោមច្បាប់គ្រប់គ្រងក្រុមប្រឹក្សាលេខ ១០* ភាគ XI "រឿងក្តីចំណាប់ខ្មាំង" ខែតុលា ឆ្នាំ១៩៤៦-មេសា ១៩៤៩ ទំព័រ ១២៣៦។ លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣ ដែលបានធ្វើបច្ចុប្បន្នភាពខែកញ្ញា ឆ្នាំ២០០៩ ("លក្ខន្តិកៈតុលាការ ICTY") មាត្រា ៧(៤)។ លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វាន់ដា ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ដែលបានធ្វើបច្ចុប្បន្នភាពថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៤ ("លក្ខន្តិកៈតុលាការ ICTR") មាត្រា ៦(៤)។ លក្ខន្តិកៈតុលាការពិសេសសម្រាប់សៀរ៉ាលេអូន ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលសៀរ៉ាលេអូន ស្តីពីការបង្កើតតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាលេអូន ទីក្រុង Freetown ថ្ងៃទី១៥ ខែមករា ឆ្នាំ២០០២ មាត្រា ៦(៤)។ សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ១៧៥៧ ឯកសារភ្ជាប់ លក្ខន្តិកៈតុលាការពិសេសសម្រាប់ប្រទេសឡេបាណុន UN Doc. S/RES/1757 ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ មាត្រា ៣(៣)។ សំណុំរឿង០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៥២៧ ["ការទទួលខុសត្រូវចំពោះការបញ្ជាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មអាចកើតមាននៅពេលជនជាប់ចោទចេញបញ្ជា *ផ្តល់អំណាច* ឬផ្ទេរបញ្ជា" (គូសបញ្ជាក់បន្ថែម)]។ សំណុំរឿង០០២-ឯកសារ **E313** សំណុំរឿង ០០២/០១ សាលក្រម ថ្ងៃទី៧ ខែសីហា ឆ្នាំ២១៤ កថាខណ្ឌ ៧០២ ["ការទទួលខុសត្រូវអាចកើតមាននៅពេលដែលជនជាប់ចោទចេញបញ្ជា ឬផ្ទេរបញ្ជា ដែលរួមទាំងតាមរយៈអន្តរការីផងដែរ។"]។ *រដ្ឋអាជ្ញា ទល់នឹង Taylor,* SCSL-03-01-T សាក្រម អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១២ កថាខណ្ឌ ៤៧៦ ["អន្តរការីខាងក្រោមនៅក្នុងខ្សែសង្វាក់នៃការបញ្ជា ដែលចេញបញ្ជាបន្តទៅកាន់ចារី ក៏អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះការចេញបញ្ជាឱ្យមានបទល្មើសដែរ ដរាបណារូបគាត់មានចេតនាដែលចាំបាច់។"] *ត្រូវបានតម្កល់* នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Taylor,* SCSL-03-01-A, សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ កថាខណ្ឌ ៥៨៩។ *រដ្ឋអាជ្ញា ទល់នឹង Milutinović និងគូកន* IT-05-87-T សាលក្រម ភាគ១ នៃ ៤ អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ កថាខណ្ឌ ៨៧ ["អន្តរការីខាងក្រោម [...] នៅក្នុងខ្សែសង្វាក់នៃការបញ្ជា ដែលចេញបញ្ជាបន្តទៅអ្នកផ្សេង ក៏អាចដាក់ឱ្យទទួលខុសត្រូវក្នុងនាមជាអ្នកចេញបញ្ជាដែលត្រូវបានប្រព្រឹត្តឡើង ឬបទល្មើសជាមូលដ្ឋាន ដរាបណារូបគាត់មានចេតនាដែលចាំបាច់។"]។ *រដ្ឋអាជ្ញា ទល់នឹង Kupreškić និងគូកន,* IT-95-16-T, សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៨៦២ ["[Šantić] ក៏បានចេញបញ្ជាបន្តពីថ្នាក់លើរបស់គាត់ទៅកាន់ថ្នាក់ក្រោមគាត់ដែរ ដែលស្មើទៅនឹងការចេញបញ្ជាឡើងវិញ ដែលខុសច្បាប់នៅក្នុងកាលៈទេសៈទាំងនោះ"]។ Antonio Cassese *និងគូកន ច្បាប់អន្តរជាតិរបស់ Cassese (Cassese's International Criminal Law)* បោះពុម្ពលើកទីបី ឆ្នាំ២០១៣ ទំព័រ ២២៨-២៤០ ជាពិសេសទំព័រ ២៣៧ ["ប្រសិនបើបញ្ជារបស់ថ្នាក់លើពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មអន្តរជាតិ (ឬ [...] ខុសច្បាប់ទាំងស្រុងក្រោមច្បាប់អន្តរជាតិ) ថ្នាក់ក្រោមមានកាតព្វកិច្ចបដិសេធគោរពតាមបញ្ជានោះ។"]។

អ.វ.ត.ក ចែងថា "ប្រការដែលថាជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋ ទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់លើណាមួយ មិនអាចជួយជនសង្ស័យនេះ ឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះបានឡើយ"[100]។

35. សំខាន់ជាងនេះទៀត ដីកាសម្រេចលើកលែងចោទប្រកាន់ខកខានមិនបានទទួលស្គាល់ថា អោ អាន មិនមែនគ្រាន់តែជាជនជាតិកម្ពុជាម្នាក់ផ្សេងទៀត ដែលត្រូវបានបង្ខំឲ្យធ្វើសកម្មភាពប្រឆាំងនឹងឆន្ទៈរបស់ខ្លួនតាមរយៈស្ថានភាពបង្ខិតបង្ខំនៃរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះនោះទេ ផ្ទុយទៅវិញ អោ អាន គឺជាមនុស្សម្នាក់ក្នុងចំណោមជនទាំងឡាយដែលបានជួយបង្កើតប្រព័ន្ធនោះ មានស្វ័យភាពដ៏ច្រើនក្នុងការប្រតិបត្តិអំណាចផ្តាច់ការរបស់ខ្លួន និងបានទទួលផលប្រយោជន៍ពីអំពើឧក្រិដ្ឋរបស់ខ្លួន ដោយសារតែគាត់បានឡើងឋានៈជាបន្តបន្ទាប់ក្នុងរបបខ្មែរក្រហម។ ប្រព័ន្ធបង្ខិតបង្ខំរបស់កម្ពុជាប្រជាធិបតេយ្យ មិនអាចត្រូវបានបង្កើតឡើងបានឡើយ បើសិនជាគ្មានការជួយជ្រោមជ្រែងពីសំណាក់កម្មាភិបាលស្មោះត្រង់ ដូចជា អោ អាន ដែលស្ម័គ្រចិត្តថែរក្សាម៉ាស៊ីននៃភាពភ័យខ្លាចនេះ។ ដីកាសម្រេចលើកលែងចោទប្រកាន់បញ្ជាក់អង្គហេតុដែលថា ប.ក.ក បានតាមដានឃ្លាំមើល "គ្រប់សកម្មភាព គ្រប់ពេលវេលា គ្រប់ទីកន្លែង" និង "គ្រប់ទីតាំង និងអង្គភាព"[101] នៅទូទាំងប្រទេសទាំងមូល ប៉ុន្តែមិនអើពើទៅនឹងការដែលថា បុរសប្រាំពីរនាក់នៅក្នុងគណៈអចិន្ត្រៃយ៍មិនអាចតាមដានឃ្លាំមើលដោយខ្លួនឯង "គ្រប់សកម្មភាព គ្រប់ពេលវេលា គ្រប់ទីកន្លែង" បានទេ បើសិនជាមិនមានជំនួយពីអ្នកក្រោមបង្គាប់ដ៏ស្មោះត្រង់ជាច្រើនអ្នកនោះ។ ដីកាសម្រេចលើកលែងចោទប្រកាន់បានលើកឡើងថា អោ អាន តែលតោល និងគ្មានជម្រើសអ្វីក្រៅពីគោរពតាម ពីព្រោះបើមិនដូច្នោះទេ "អង្គការភ្នែកម្នាស់ចាប់កំហុស" នឹងដាក់ទណ្ឌកម្មគាត់[102] ដោយមើលរំលងការដែលថា អោ អាន *ខ្លួនឯងផ្ទាល់* គឺជាភ្នែកមួយក្នុងចំណោមភ្នែកជាច្រើនរបស់អង្គការនេះ។ ស្រដៀងគ្នានេះដែរ ដីកាសម្រេចលើកលែងចោទប្រកាន់លើកឡើងថា អោ អាន មានការទទួលខុសត្រូវតិចតួច ពីព្រោះ "មនុស្សរស់នៅក្នុងសភាពភ័យខ្លាចគ្រប់វិនាទី

---

[100] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដូចដែលបានវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/២០០៦) ("ច្បាប់ អ.វ.ត.ក") មាត្រា ២៩។

[101] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥២៨។

[102] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥២៨។

និងស្ថិតនៅមាត់ជ្រោះមរណៈ:"[103]។ ប៉ុន្តែតាមពិតនោះ អោ អាន គឺជាបុគ្គលដែលមនុស្សនៅក្នុងតំបន់៤១ រស់ក្នុងភាពភ័យខ្លាចរូបគាត់ ហើយប្រសិនបើមរណៈចូលមកដល់នោះ ជាធម្មតាវាស្ថិតនៅក្នុងដៃរបស់ជនទាំងឡាយដែលស្ថិតក្រោមបញ្ជារបស់ អោ អាន។ អោ អាន គឺជា *អង្គការ* យ៉ាងហោចណាស់ក្នុងតំបន់៤១។

36. ក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "[...] គេមិនអាចអះអាងថាមានការបង្ខិតបង្ខំនោះទេ នៅពេលដែលការគំរាមកំហែងនោះកើតចេញពីការអនុវត្តគោលនយោបាយដែលធ្វើឲ្យមានភាពភ័យរន្ធត់ ដែលជនជាប់ចោទខ្លួនឯងបានចូលរួមយ៉ាងសកម្ម និងដោយស្ម័គ្រចិត្ត"[104]។ ចំណុចនេះបង្ហាញយ៉ាងច្បាស់ពីស្ថានភាពរបស់ អោ អាន។ ជាមួយនឹងការទទួលយកមុខតំណែងជាច្រើនរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អោ អាន បានទទួលផលប្រយោជន៍ជាច្រើនក្នុងការទទួលបានអំណាច និងទទួលបានអត្ថប្រយោជន៍ជាសារវ័ន្ត និងសន្តិសុខ ដោយធៀប [ទៅនឹងអ្នកឯទៀត]។ ក្នុងនាមជាកម្មាភិបាលដ៏គួរឲ្យទុកចិត្តដែលទទួលបានការតម្លើងមុខតំណែងដ៏ធំជាងមុនប្រកបដោយអំណាច និងសេចក្តីទុកចិត្តនោះ រូបគាត់បានចូលរួមចំណែកយ៉ាងសកម្ម និងដោយស្ម័គ្រចិត្ត ក្នុងការបង្កើតប្រព័ន្ធនៃការបង្ខិតបង្ខំដែលមានលក្ខណៈឧក្រិដ្ឋរបស់របបកម្ពុជាប្រជាធិបតេយ្យ។ ដោយបានចូលរួមចំណែកក្នុងការ បង្កើតម៉ាស៊ីននៃភាពភ័យខ្លាច អោ អាន ក៏បានដឹងខ្លួនឯងផងដែរថា ក្នុងកម្រិតណាមួយនោះ រូប គាត់ស្ថិតនៅក្រោមប្រព័ន្ធនោះ ទោះតាមវិធីណាក៏ដោយ មិនអាចត្រូវបានយកមកបន្ធូរបន្ថយការ ទទួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មនានាដែលគាត់បានប្រព្រឹត្តនោះឡើយ។ ស្ថានភាពរបស់ គាត់ពិតជាមិនអាចត្រូវបានយកទៅប្រៀបធៀបជាមួយស្ថានភាពភាគច្រើនរបស់ជនរងគ្រោះរបស់ គាត់បានទេ ដោយពួកគេទាំងនោះ

---

[103] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥២៨។

[104] សំណុំរឿង០០១-ឯកសារ **E188** *សាលក្រម ឌុច*, កថាខណ្ឌ ៥៥៧។ ទោះបីជាច្បាប់ និងយុត្តិសាស្ត្រដែលបានផ្អែកលើនៅក្នុងផ្នែកនេះ ទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល មិនមែនជាទស្សនៈយុត្តាធិការអំពី "ការទទួលខុសត្រូវខ្ពស់បំផុត" ក៏ដោយ ក៏មិនមានសំអាងហេតុត្រឹមត្រូវក្នុងការមិនអនុវត្តបទដ្ឋានដូចគ្នាចំពោះការវិភាគយុត្តាធិការនោះដែរ។ វានឹងជាលទ្ធផលចម្លែក និងគ្មានគោលការណ៍ ប្រសិនបើអ្នកទាំងឡាយណាដែលមានការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលចំពោះឧក្រិដ្ឋកម្មនានាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានដាក់ តាមវិធីណាមួយ មិនឲ្យស្ថិតក្នុងចំណោមបុគ្គលទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ។ សចសជ ខ្លួនឯងផ្ទាល់បានទទួលស្គាល់ថា "ការពិចារណាដែលត្រូវធ្វើឡើងលើបញ្ហាចោទ អំពីយុត្តាធិការបុគ្គល ពុំមែនខុសគ្នាទាំងស្រុងនឹងការពិចារណាដែលយើងត្រូវគិតនៅពេលកំណត់ទោសឡើយ។" *សូមមើល* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥៦២។

ស្ថិតនៅក្រោមអំណាចតាមអំពើចិត្តរបស់របបកម្ពុជាប្រជាធិបតេយ្យចំពោះជីវិត និងការស្លាប់តាមរយៈអំពើរបស់ពួកគេផ្ទាល់ ឬដោយគ្មានកំហុស។

37. ក្នុងការលើកឡើងថា អោ អាន គ្មានជម្រើសអ្វីក្រៅពីចូលរួមក្នុងឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ ដីកាសម្រេចលើកលែងចោទប្រកាន់ក៏បានមើលរំលងអង្គហេតុដែលថា មានអ្នកផ្សេងទៀតបានភៀសខ្លួន ឬបានប្រឆាំងទៅនឹងរបបនោះ។ ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានពិចារណាលើអង្គហេតុដែលថា អោ អាន មានអត្ថប្រយោជន៍ដោយសារស្ថិតនៅឆ្ងាយពីទីបញ្ជាការរបស់ ប.ក.ក នៅក្រុងភ្នំពេញ និងស្ថិតនៅជិតព្រំដែនវៀតណាមជាង (ខុសពីអ្នកផ្សេងទៀត ដូចជា ឌុច ដែលទោះជាយ៉ាងណាត្រូវបានគេរកឃើញថាស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត)។ ទោះបីជាវាមិនអាចធ្វើទៅបានដោយគ្មានហានិភ័យក៏ដោយ ក៏កម្មាភិបាល ប.ក.ក មួយចំនួនបានធ្វើដូចនឹងអ្វីដែលដីកាសម្រេចលើកលែងចោទប្រកាន់បានសន្និដ្ឋានថាមិនអាចធ្វើទៅបាន គឺថា ពួកគេឈប់ចូលរួមចំណែកក្នុងសកម្មភាពឧក្រិដ្ឋរបស់ ប.ក.ក និងបានភៀសខ្លួនចូលទៅក្នុងព្រៃ ឬឆ្លងព្រំដែន។ កម្មាភិបាល និងប្រជាជនធម្មតាមួយចំនួនតូចក៏បានចូលរួមក្នុងការតស៊ូប្រដាប់អាវុធក្នុងតំបន់មួយចំនួន។ និយាយថា អោ អាន គ្មានជម្រើសអ្វីក្រៅពី សម្លាប់ប្រជាជនកម្ពុជារាប់ពាន់នាក់ដើម្បីសង្គ្រោះជីវិតខ្លួនឯងនោះ ជាការមើលរំលងវិធីដោះស្រាយដែលអាចធ្វើទៅបានផ្សេងទៀតទាំងអស់នេះ។

### ២. អោ អាន ប្រព្រឹត្តឧក្រិដ្ឋកម្មដោយស្ម័គ្រចិត្ត និងយ៉ាងសកម្មដោយគ្មានការបង្ខិតបង្ខំ

38. ការពិចារណារបស់ដីកាសម្រេចលើកលែងចោទប្រកាន់ទាក់ទងនឹងបញ្ហារបស់ថ្នាក់លើ ការបង្ខិតបង្ខំ និងការគាបសង្កត់ ក៏ផ្អែកលើមូលដ្ឋានមិនត្រឹមត្រូវដែលថា ការភ័យខ្លាចទណ្ឌកម្មត្រូវតែជាហេតុផលដែល អោ អាន បានប្រព្រឹត្តឧក្រិដ្ឋកម្ម[105] ដោយសារតែអ្នកដែលមិនគោរពតាមរបបកម្ពុជាប្រជាធិបតេយ្យត្រូវទទួលរងទណ្ឌកម្ម។ ដូច្នោះ មានការសន្និដ្ឋានថា ការគំរាមកំហែងនៃទណ្ឌកម្មបន្ថយការទទួលខុសត្រូវរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្មដែលគាត់បានប្រព្រឹត្តដើម្បីធ្វើឲ្យគាត់មិនស្ថិតនៅក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត"[106]។

[105] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥២១-៥៣៥។

[106] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥៥៣-៥៥៤។

39. អំណះអំណាងនេះមិនត្រឹមត្រូវទេ។ អង្គហេតុដែលថា បុគ្គលម្នាក់អាចទទួលរងទណ្ឌកម្ម ដោយសារខកខានមិនបានប្រព្រឹត្តបទឧក្រិដ្ឋ មិនមែនមានន័យថា អំពើរបស់គាត់ចាំបាច់ត្រូវតែត្រូវបានជំរុញតែដោយការភ័យខ្លាចទណ្ឌកម្មប៉ុណ្ណោះនោះទេ។ ការជំរុញទឹកចិត្តផ្សេងៗទៀត ដូចជា ការចង់បានអំណាច ឬជឿទៅលើមូលហេតុអ្វីមួយ ក៏អាចទៅរួចដែរ។ ដោយបុគ្គលបែបនេះ *មិន*ត្រូវបានជំរុញទឹកចិត្តដោយការភ័យខ្លាចទណ្ឌកម្មនោះ លទ្ធភាពតាមទ្រឹស្តីនៃទណ្ឌកម្ម មិនអាចប្រើដើម្បីកាត់បន្ថយការទទួលខុសត្រូវព្រហ្មទណ្ឌ ឬការទទួខុសត្រូវផ្នែកសីលធម៌របស់គាត់ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងឡើយ ដោយសារ និយាយសាមញ្ញ ការគំរាមកំហែងមិនមានអ្វីទាក់ទងនឹងឧក្រិដ្ឋកម្មនោះទេ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញក្នុងសំណុំរឿង០០១ ថា “អ្នកនៅក្រោមបង្គាប់ដែលអាចបង្ហាញឲ្យឃើញនូវអត្ថិភាពនៃបញ្ជារបស់ថ្នាក់លើអាចនឹងទទួលការផ្តន្ទាទោសកម្រិតស្រាលបានតែនៅក្នុងករណីដែលបង្ហាញច្បាស់ថា បញ្ជារបស់ថ្នាក់លើពិតជាអាចកាត់បន្ថយកម្រិតនៃពិរុទ្ធភាពរបស់អ្នកទៅក្រោមបង្គាប់។ ប្រសិនបើបញ្ជានោះមិនមានឥទ្ធិពលអ្វីទៅលើអាកប្បកិរិយានៃការប្រព្រឹត្តខុសច្បាប់នោះទេ ដោយសារជនជាប់ចោទបានត្រៀមខ្លួនរួចជាស្រេចក្នុងការអនុវត្តបញ្ជានោះ គេមិនអាចនិយាយថាមានស្ថានសម្រាលទោសបានឡើយ”[107]។

40. ភ័ស្តុតាងក្នុងសំណុំរឿង០០២/២ បង្ហាញច្បាស់ថា អោ អាន ត្រូវបានរៀបចំឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មដោយមិនមានការគៀបសង្កត់ណាមួយឡើយ។ គាត់បានអនុវត្តកិច្ចការរបស់គាត់ដោយពេញចិត្តយ៉ាងជាក់ស្តែង ចំពោះអំណាចដែលគាត់មានលើប្រជាជនស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។ ឧទាហរណ៍ គាត់បានប្រើភាសាកាចសាហាវក្នុងពាក្យពេចន៍របស់គាត់អំពីខ្មាំង ដែលធ្វើឲ្យពួកគេបាត់លក្ខណៈជាមនុស្ស ជា “ឡានដែលមានកង់ចាស់ៗ ដែលត្រូវដកចេញ និងជៀរសម្រាប់ផលិតស្បែកជើង” និងបានគំរាមថា “ស្លាប់ច្រើនជាងបេ-៥២ចាក់ទៅទៀត!” ទៅទៀត។[108] គាត់បានបញ្ជាយ៉ាងឃោរឃៅឲ្យអ្នកក្រោមបង្គាប់របស់គាត់សម្លាប់ និងវះពោះស្ត្រីមានផ្ទៃពោះម្នាក់ ដែលបានមកកាន់មន្ទីរតំបន់ម្តងហើយម្តងទៀតដើម្បីសួរនាំអំពីប្តីរបស់គាត់ ដែលត្រូវបាន

---

[107] សំណុំរឿង០០១-ឯកសារ **E188** សាលក្រម ***ឌុច***, កថាខណ្ឌ ៦០៧ (អញ្ញត្តិរ:ខាងក្នុង និងការយោងសំអាងត្រូវបានលុបចោល) (គូសបញ្ជាក់បន្ថែម)។

[108] ឯកសារ **D219/504** កំណត់ហេតុស្តាប់ចម្លើយ សាត ភាព ឆ.២៤-២៥។ **D219/226** កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា ឆ.៦។

ចាប់ខ្លួន[109] ហើយការសម្លាប់បានបន្តក្នុងតំបន់នៃការគ្រប់គ្រងរបស់ អោ អាន រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ទោះបីជាមានសេចក្តីណែនាំឆ្នាំ១៩៧៨ របស់បក្ស ដែលមានបំណងបន្ថយគោលនយោបាយបោសសំអាតក៏ដោយ[110]។ សូម្បីតែក្រោយពេលដែលសេចក្តីណែនាំនោះត្រូវបានដាក់ឱ្យអនុវត្តក៏ដោយ ក៏ អោ អាន បានណែនាំឱ្យថ្នាក់ក្រោមរបស់គាត់ "ចុះទៅតាមភូមិផ្ទាល់" ដើម្បីចងក្រងបញ្ជីឈ្មោះជនជាតិចាមឱ្យបានច្បាស់លាស់ជាងបញ្ជីដែលមេភូមិបានផ្តល់ឱ្យ ប៉ុន្តែវៀតណាមបានចូលមកដល់មុនពេលការបោសសំអាតបន្តទៀតត្រូវបានធ្វើឡើង។[111] ចំពោះពលកម្មការងារដោយបង្ខំ អោ អាន និងថ្នាក់ក្រោមផ្ទាល់របស់គាត់ ឈ្មោះ អួន ជាញឹកញាប់បានទៅមើលការដ្ឋានទំនប់អន្លង់ជ្រៃ ជាទីដែលពួកគេបានត្រួតពិនិត្យដោយផ្ទាល់លើការរីកចម្រើននៃការងារនោះ និងបានធ្វើការប្រជុំដែលនៅក្នុងនោះពួកគេបានប្រាប់កម្មករឱ្យធ្វើឱ្យបានតាមជំនួនកំណត់ បើមិនដូច្នោះទេពួកគេនឹងត្រូវចាត់ទុកថាជាខ្មាំង[112]។ ក្នុងពេលមួយនៅ

---

[109] ឯកសារ **D219/837** កំណត់ហេតុស្តាប់ចម្លើយ សូ សារ៉េន ឆ.៧៥-៧៧។

[110] *សូមមើល ឧទាហរណ៍* ទាក់ទងនឹងសេចក្តីណែនាំនេះ៖ ឯកសារ **D179/1.2.27** ប្រតិចារឹក សៅ សារុន ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២ ម៉ោង 10.01.37-10.03.56។ ឯកសារ **D6.1.141** កំណត់ហេតុស្តាប់ចម្លើយ សៅ សារុន EN 00278694, 97។ ឯកសារ **D118/259** កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម ឆ.១៨៨-១៩១។ ឯកសារ **D219/80** កំណត់ហេតុស្តាប់ចម្លើយ ធូ លាង ឆ.៣៣។ ឯកសារ **D219/405** កំណត់ហេតុស្តាប់ចម្លើយ ឈឹម ប៊ុនសេរី ឆ.១៣, ១៨។ ឯកសារ **D219/504** កំណត់ហេតុស្តាប់ចម្លើយ សាត ភាព ឆ.៣៦។ ប៉ុន្តែ ទោះបីជាមានសេចក្តីណែនាំនេះ ការសម្លាប់នៅក្នុងតំបន់ ៤១ នៅតែបន្ត។ ឧទាហរណ៍ អ្នកទោសដែលនៅសល់នៅក្នុងមន្ទីរសន្តិសុខតំបន់ ៤១ (មិត្តសុប/គ) ត្រូវបានសម្លាប់ បន្តិចមុនពេលវៀតណាមចូលមកដល់ (*សូមមើល* ឯកសារ **D3/15** កំណត់ហេតុស្តាប់ចម្លើយ ដួង ស៊ឹម ឆ.៩។ ឯកសារ **D219/24** កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុខឿន ឆ.៦០។ ឯកសារ **D117/67** កំណត់ហេតុស្តាប់ចម្លើយ កៅ ឃន ឆ.១២)។ ការចាប់ខ្លួន និងការសម្លាប់ក៏បានបន្តធ្វើនៅវត្តបាធាយ រហូតដល់វៀតណាមរំដោះអ្នកទោស (*សូមមើល* ឯកសារ **D97** កំណត់ហេតុស្តាប់ចម្លើយ សេង វុន EN 00746830-31) នៅវត្តអូរត្រកួន (*សូមមើល* ឯកសារ **D6.1.192** កំណត់ហេតុស្តាប់ចម្លើយ សេង ស្រ៊ុន EN 00242087។ ឯកសារ **D6.1.400** កំណត់ហេតុស្តាប់ចម្លើយ សំរិត មុយ EN 00235508) និងវត្តតាមះ (*សូមមើល* ឯកសារ **D219/504** កំណត់ហេតុស្តាប់ចម្លើយ សាត ភាព ឆ.១៥២)។

[111] ឯកសារ **D219/702.1.87** យូ វ៉ាន់ ប្រតិចារឹក ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ម៉ោង 15.25.57-15.28.23។ ឯកសារ **D219/138** កំណត់ហេតុស្តាប់ចម្លើយ យូ វ៉ាន់ ឆ.១០២។

[112] ឯកសារ **D117/50** កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម ប៊ុន ឆ.៣៥-៣៧។ ឯកសារ **D219/800** កំណត់ហេតុស្តាប់ចម្លើយ សូ សារ៉េន ឆ.៦៩-៧០, ៧២, ៩១-៩២។ ឯកសារ **D219/331** កំណត់ហេតុស្តាប់ចម្លើយ ផន សុផល ឆ.២៤-២៨, ៣៦, ៣៨-៤២, ៤៧។ ឯកសារ **D219/17** កំណត់ហេតុស្តាប់ចម្លើយ ពិន ដន ឆ.៤ ["តាអាន គាត់មកកន្លែងទំនប់ហ្នឹងតែរាល់ថ្ងៃ ដោយជិះឡានហ្ស៊ីប។"]។ ឯកសារ **D78** កំណត់ហេតុស្តាប់ចម្លើយ ជិន ស៊ីណាល់ ឆ.១-២, ៩។ ឯកសារ **D3/4.1** កំណត់ហេតុនៃកិច្ចសម្ភាសន៍ ជិន ស៊ីណាល់ ដោយ កសព EN 00210442។ ឯកសារ **D1.3.11.4** កំណត់ហេតុនៃកិច្ចសម្ភាសន៍ បោ ទ្រព្យ ដោយ កសព EN 00210428។ ឯកសារ **D219/285** កំណត់ហេតុស្តាប់ចម្លើយ ហូ ហឿន ឆ.១៨ ["ខ្ញុំនៅចាំត្រង់ចំណុចដែល [អោ

ជិតចុងបញ្ចប់នៃរបបនោះ អោ អាន ចុះទៅទីតាំងនេះនៅពេលយប់ និងបានដើររយៈពេលមួយម៉ោងតាមរោងដែលកម្មករកងចល័តដេក ដោយបានចោទប្រកាន់ពួកគេថាជាភ្នាក់ងារ សេ.អ៊ី.អា និងគិញវៀតណាម[113]។ កម្មករម្នាក់បានរៀបរាប់ពីអំណាចរបស់ អោ អាន ថា "ផ្តាច់ការ" និងបាននិយាយថា នៅពេលដែល អោ អាន នៅទីតាំងនោះ "កម្មករមិនហ៊ានសម្រាកទេ" ដោយខ្លាចថាពួកគេនឹងត្រូវគេយល់ថាខ្ជិល និងត្រូវសម្លាប់ចោល[114]។

41. ការតម្លើងតួនាទីជាប្រចាំរបស់ អោ អាន ក្នុងរយៈពេលទាំងមូលនៃរបបកម្ពុជាប្រជាធិបតេយ្យ បង្ហាញទៀតអំពីការប្រកាន់ខ្ជាប់យ៉ាងពេញចិត្តនូវភារកិច្ចរបស់គាត់ក្នុងនាមជាកម្មាភិបាល ប.ក.ក [115]។ សូម្បីតែក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ អោ អាន បានរត់ទៅកាន់តំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហម បានបង្ហាញពីភក្តីភាពបន្តទៀតរបស់គាត់ចំពោះខ្មែរក្រហម និងគោលនយោបាយរបស់របបនោះ[116]។ ដូចដែលនៅចុងឆ្នាំ២០១១ រយៈពេលជាង ៣០ ឆ្នាំ ក្រោយចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ អោ អាន បាននិយាយថា រូបគាត់ "ពេញចិត្តពេញថ្លើម [នឹងរបបកម្ពុជាប្រជាធិបតេយ្យ]" និងមានអារម្មណ៍ថា មេដឹកនាំរបស់របបនោះ "ខំកសាងប្រទេស ហើយស្តារប្រទេសឡើងវិញ"[117]។ រូបគាត់មិនបានបង្ហាញពីវិប្បដិសារីណាមួយឡើយ និងមិនបានសុំទោសមនុស្សរាប់ម៉ឺននាក់ដែលទទួលរងទុក្ខវេទនាក្រោមការគ្រប់គ្រងរបស់គាត់ឡើយ។

---

អាន] និយាយថា យើងត្រូវខិតខំធ្វើការងារតាមការចាត់តាំង បើមិនដូច្នេះគេនឹងត្រូវចាត់ទុកថាជាខ្មាំង។ គាត់ក៏បានប្រាប់ផងដែរអំពីចំនួនប្រជាជនដែលចូលរួមលើកទំនប់នេះ គឺមានចំនួន ២០.០០០នាក់"]។ ឯកសារ **D219/870** កំណត់ហេតុស្តាប់ចម្លើយ រី ញ៉ ទ.៣៥។ ឯកសារ **D219/286** កំណត់ហេតុស្តាប់ចម្លើយ មិន អាត ទ.២៥, ២៨។ ឯកសារ **D117/52** កំណត់ហេតុស្តាប់ចម្លើយ ប៊ុំ សែ ទ.១៦-១៧។ ឯកសារ **D219/582** កំណត់ហេតុស្តាប់ចម្លើយ តួយ មៀច ទ.១៥៧។ ឯកសារ **D219/324** កំណត់ហេតុស្តាប់ចម្លើយ ជិន ទិត ទ.៥-៦។

113 ឯកសារ **D219/331** កំណត់ហេតុស្តាប់ចម្លើយ ផន សុផល ទ.៣៩-៤២។

114 ឯកសារ **D219/582** កំណត់ហេតុស្តាប់ចម្លើយ តួយ មៀច ទ.១៥៥, ១៥៧, ១៦០។

115 ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៩១-១៩២, ១៩៩-២០០, ២៤២។

116 ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨៤។ *សូមមើលផងដែរ* ឯកសារ **D191.2** បទសម្ភាសន៍ អោ អាន ដោយ DC-Cam, EN 01025331-35។

117 ឯកសារ **D191.2** បទសម្ភាសន៍ អោ អាន ដោយ DC-Cam, EN 01025335។

## ៣. លក្ខខណ្ឌតម្រូវគ្មានមូលដ្ឋានដែលថា ការចូលរួមប្រព្រឹត្តរបស់ អោ អាន ក្នុងឧក្រិដ្ឋកម្មហួសឆ្ងាយពីសិទ្ធិអំណាចផ្លូវការរបស់គាត់

42. ក្នុងការឈានទៅសន្និដ្ឋានថា អោ អាន មិនស្ថិតក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ដីកាសម្រេចលើកលែងចោទប្រកាន់ពឹងផ្អែកយ៉ាងខ្លាំងទៅលើការរកឃើញមួយដែលថា សកម្មភាពឧក្រិដ្ឋរបស់ អោ អាន មិនហួសពីវិសាលភាពសិទ្ធិអំណាចផ្លូវការរបស់គាត់ទេ[118] ប៉ុន្តែ ដីកាខកខានមិនបានដកស្រង់ការយោងសំអាងណាមួយសម្រាប់ការអះអាងថា ការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្នុងវិសាលភាពនៃសិទ្ធិអំណាចរបស់មនុស្សម្នាក់ (ក្នុងរបបឧក្រិដ្ឋយ៉ាងជាក់ស្តែង) ធ្វើឱ្យបុគ្គលនោះមានការទទួលខុសត្រូវតិចតួចចំពោះឧក្រិដ្ឋកម្មទាំងនោះឡើយ ហើយមិនមានការយោងសំអាងនេះត្រូវបានបង្ហាញឱ្យឃើញទេ។ តាមពិតនោះ វាគឺជាគោលការណ៍ច្បាប់ទម្លាប់អន្តរជាតិដែលត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវដែលថា តួនាទីផ្លូវការមិនបានធ្វើឱ្យបុគ្គលម្នាក់រួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ[119]។ ហើយក៏មិនមានអំណះអំណាងតាមកត្តវិជ្ជាណាមួយសម្រាប់គោលការណ៍នោះដែរ គឺថា សហឧក្រិដ្ឋកម្មទ្រង់ទ្រាយធំភាគច្រើនផ្អែកលើការបែងចែកភារកិច្ច និងសិទ្ធិអំណាចក្នុងចំណោមក្រុមបុគ្គលសហការគ្នា ដោយម្នាក់ៗធ្វើសកម្មភាពក្នុងវិសាលភាពនៃសិទ្ធិអំណាចរបស់ខ្លួន ដើម្បីបង្កើតការចូលរួមចំណែករបស់ខ្លួនក្នុងផែនការ

---

[118] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៩៤-៥១០។

[119] *សូមមើលឧទាហរណ៍* ធម្មនុញ្ញតុលាការ Nuremberg មាត្រា ៧។ ធម្មនុញ្ញតូក្យូ មាត្រា ៦។ ច្បាប់គ្រប់គ្រងក្រុមប្រឹក្សាលេខ១០ មាត្រា II(៤)(ក)។ អនុសញ្ញាស្តីពីការទប់ស្កាត់ និងការដាក់ទណ្ឌកម្មឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ក្រុងប៉ារីស ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ ("អនុសញ្ញាប្រល័យពូជសាសន៍"), 78 UNTS 277, មាត្រា IV ["ជនទាំងឡាយណាដែលបានប្រព្រឹត្តអំពើប្រល័យពូជាសាសន៍ ឬអំពើណាមួយដទៃទៀត ដូចបានរៀបរាប់ក្នុងមាត្រា III ត្រូវទទួលទោស មិនថាជនទាំងនោះ តាមរដ្ឋធម្មនុញ្ញ ជាមេដឹកនាំដែលមានការទទួលខុសត្រូវ មន្ត្រីសាធារណៈ ឬបុគ្គលឯកជនឡើយ។"]។ អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាប និងការដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្ម*អាប៉ាថេត* ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៣, A/RES/3068(XXVIII), មាត្រា III។ លក្ខន្តិកៈតុលាការ ICTY មាត្រា ៧(២)។ លក្ខន្តិកៈតុលាការ ICTR មាត្រា ៦(២)។ លក្ខន្តិកទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨, 2187 UNTS 90, មាត្រា ២៧។ *រដ្ឋអាជ្ញា ទល់នឹង Blagojević & Jokić*, IT-02-60-A, សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៧ កថាខណ្ឌ ១៨៩ [ក្នុងបរិបទការទទួលខុសត្រូវនៃការជួយ និងសម្រួល៖ "ក្នុងករណីដែលជនជាប់ចោទបានចូលរួមប្រព្រឹត្តដោយដឹងឮក្នុងការប្រព្រឹត្តិបទល្មើស និង/ឬ ការចូលរួមរបស់គាត់បានប៉ះពាល់យ៉ាងខ្លាំងលើការប្រព្រឹត្តិបទល្មើសនោះ អង្គហេតុដែលថា ការចូលរួមរបស់គាត់បង្កើតបានជាមិនលើសពី "ការងារប្រចាំ" របស់គាត់ នឹងមិនដោះបន្ទុកជនជាប់ចោទទេ។"]។ *រដ្ឋអាជ្ញា ទល់នឹង Popović និងគូកន*, IT-05-88-A, សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ១៦១៥។ Antonio Cassese *និងគូកន ច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់* Cassese បោះពុម្ពលើកទីបី ឆ្នាំ២០១៣ ទំព័រ២៤០-២៤៦។

ធំមួយ។ ក្នុងស្ថានភាពទាំងនេះ ការប្រព្រឹត្តិឧក្រិដ្ឋកម្មត្រូវបានជួយជ្រោមជ្រែងដោយអ្នកចូលរួមប្រព្រឹត្តម្នាក់ៗ ដែលបានធ្វើសកម្មភាពក្នុងសិទ្ធិអំណាចរបស់ខ្លួន។

## ៤. ការប្រព្រឹត្តិចំពោះបទបញ្ជា ការបង្ខិតបង្ខំ និងការគាបសង្កត់របស់ថ្នាក់លើខុសគ្នាតាមទំនើងចិត្ត នៅក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០៤/២

43. តាមពិត ការរកឃើញផ្ទាល់ខ្លួនរបស់សហចៅក្រមស៊ើបអង្កេតជាតិនៅក្នុងដីកាដំណោះស្រាយ ក្នុងសំណុំរឿង០០១ ផ្តល់អំណះអំណាងផ្ទុយមួយអំពី "គោលការណ៍" នៃសំណុំរឿង០០៤/២ ដែលថា ការធ្វើឡើងអនុលោមតាមបញ្ជារបស់ថ្នាក់លើ និងនៅក្នុងសមត្ថភាពផ្លូវការរបស់នរណាម្នាក់ បានដកបុគ្គលនោះចេញពីប្រភេទ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"។ នៅក្នុងសំណុំរឿង ០០១ ស.ច.ស ដែលរួមទាំង ស.ច.ស.ជ ផង បានរកឃើញថា ឌុច បានទទួលបញ្ជាជាក់លាក់ពីថ្នាក់លើរបស់គាត់លើការងារមួយចំនួន ដែលរួមមាន (i) ការទាញយក និងខ្លឹមសារនៃចម្លើយសារភាពជាក់លាក់[120] (ii) របបអាហារដែលត្រូវផ្តល់ឱ្យអ្នកទោស[121] (iii) ការពិសោធន៍វេជ្ជសាស្ត្រដែលបានធ្វើឡើងចំពោះអ្នកទោស[122] (iv) ការប្រើអំពើទារុណកម្មលើអ្នកទោសជាក់លាក់[123] (v) នីតិវិធីរដ្ឋបាលជាក់លាក់ដែលត្រូវអនុវត្តនៅពេលសម្លាប់អ្នកទោស[124] និង (vi) របៀប

---

[120] សំណុំរឿង ០០១-ឯកសារ **D99** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្កេកអ៊ាវ ហៅ ឌុច, ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ("ដីកាដំណោះស្រាយ"), កថាខណ្ឌ ៤៤ ["ឌុច និយាយថា ក្នុងករណីជាច្រើន គាត់ទទួលបានសេចក្តីណែនាំអំពីខ្លឹមសារជាក់លាក់ ដែលគាត់ត្រូវយកឱ្យបានពីអ្នកដែលគេកំណត់ឱ្យ"]។

[121] សំណុំរឿង ០០១-ឯកសារ **D99** ដីកាដំណោះស្រាយ, កថាខណ្ឌ ៦៨ ["ឌុច បានអះអាងថា របបអាហារត្រូវបានសម្រេចដោយ 'ថ្នាក់លើ' ហើយថាគាត់មិនអាចផ្លាស់ប្តូររបបអាហារនេះបានទេ។ គាត់បាននិយាយថា ការបង្អត់អាហារអ្នកទោស ជាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា"]។

[122] សំណុំរឿង ០០១-ឯកសារ **D99** ដីកាដំណោះស្រាយ, កថាខណ្ឌ ៧០ ["មានភស្តុតាងបង្ហាញថា បុគ្គលិកនៅមន្ទីរ ស-២១ បានធ្វើការពិសោធន៍វេជ្ជសាស្ត្រទៅលើអ្នកទោស។ ឌុច បានបញ្ជាក់ប្រាប់ថា *"ការស្រាវជ្រាវថ្នាំពុល ត្រូវបានធ្វើឡើងតាមបញ្ជារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និយាយឱ្យចំគឺ នួន ជា"*]។

[123] សំណុំរឿង ០០១-ឯកសារ **D99** ដីកាដំណោះស្រាយ, កថាខណ្ឌ ៨៥, ៨៩ ["ឌុច បានពន្យល់ថា *'[...] ចំពោះអ្នកទោសសំខាន់ដូចជា យ៉ា ជាដើម គឺ សុន សេន ជាអ្នកបញ្ជាមកខ្ញុំ និងជាអ្នកសម្រេចអំពីការធ្វើទារុណកម្ម'*។ [...] ចំពោះបញ្ហាចុងក្រោយ ឌុច បានទទួលស្គាល់ថា គាត់បានសរសេរទៅកូនចៅរបស់គាត់ គឺ ប៉ុន ដែលជាអ្នកសួរចម្លើយ ឱ្យធ្វើទារុណកម្ម [...] ឌុច បានអះអាងថា នៅពេលនោះ គាត់បានទទួលបញ្ជាពី សុន សេន តាមទូរស័ព្ទ"]។

[124] សំណុំរឿង ០០១-ឯកសារ **D99** ដីកាដំណោះស្រាយ, កថាខណ្ឌ ១០៧ ["បន្ទាប់ពីមានហេតុការណ៍មួយ ដែលមានអ្នកទោសម្នាក់ស្លាប់មុនបញ្ចប់ការសួរចម្លើយ សុន សេន បានតម្រូវឱ្យ ឌុច សម្រេចលើរាល់ការសម្លាប់"]។

នៃការសម្លាប់ និងការចោលសាកសព/សំណល់សាកសពអ្នកទោសសំខាន់មួយចំនួន[125]។ ពួកគាត់បានរកឃើញបន្ថែមទៀតថា ឌុច មានឥទ្ធិពលក្នុងកំណត់ទៅលើអ្នកដែលត្រូវចាប់ខ្លួន[126]។ គាត់មិនអាចបដិសេធមិនទទួលអ្នកទោសណាម្នាក់ដែលគេបានបញ្ជូនមកគាត់បានឡើយ ហើយក៏មិនអាចធ្វើការសន្និដ្ឋានដោយសេរីបន្ទាប់ពីការស៊ើបអង្កេតដែលរកឃើញថា អ្នកនោះជាជនស្លូតត្រង់ដែរ[127]។ គាត់មិនអាចដោះលែងអ្នកទោសបានឡើយ[128] ហើយគាត់ក៏គ្មានឆន្ទានុសិទ្ធិដើម្បីសម្លាប់អ្នកទោសណាម្នាក់ដែលបានបញ្ជូនមកគាត់បានដែរ សិទ្ធិអំណាចដ៏ធំបំផុតដែលថ្នាក់លើគាត់បានផ្តល់ឱ្យគាត់ គឺសិទ្ធិអំណាចឱ្យទុកអ្នកទោសដែលមានជំនាញខ្លះឱ្យនៅរស់មួយរយៈពេលណាមួយដើម្បីធ្វើការងារ[129]។ ស.ច.ស បានរកឃើញយ៉ាងច្បាស់ថា "តួនាទីជាបឋមរបស់ស-២១ *គឺដើម្បីអនុវត្តមាគ៌ានយោបាយក្ស ចំពោះខ្មាំង*"[130] ហើយ ឌុច ខ្លួនឯងក៏បានបញ្ជាក់យ៉ាងច្បាស់ថា ខ្លួនគាត់ធ្វើទៅតាមកម្រិតនៃបទបញ្ជា និងសិទ្ធិអំណាចផ្លូវការ ដោយគាត់និយាយថា "ការបោសសម្អាតផ្ទៃក្នុងបក្ស និងការបោសសម្អាតនៅក្នុងចំណោមប្រជាជន [...] វាជាការងាររបស់យើងទាំងអស់គ្នា។ យើងម្នាក់ៗត្រូវធ្វើឱ្យបាន *តាមតួនាទី និងការទទួលខុសត្រូវរបស់យើង* ដោយគេចមិនរួច" ដោយនេះជាភ័ស្តុតាងមួយដែលដីកាលើកលែងចោទប្រកាន់បានទទួលស្គាល់យ៉ាងច្បាស់ក្រឡែត[131]។ ជាសង្ខេប ក្នុងសំណុំរឿង០០១ សចស រួមទាំង ស.ច.ស.ជ បច្ចុប្បន្ននេះផង បានរកឃើញដោយគ្មានមន្ទិលថា ឌុច បានធ្វើប្រតិបត្តិការផ្តាច់មុខតាមសិទ្ធិអំណាចផ្លូវការរបស់គាត់ និងបានចូលរួមក្នុងការអនុវត្តគោលនយោបាយ បកក ដែលអនុលោមតាមបទបញ្ជារបស់ថ្នាក់លើ ប៉ុន្តែកត្តាទាំងអស់នោះមិនបានដកគាត់ចេញពីប្រភេទជា "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ទេ។

---

[125] សំណុំរឿង ០០១-ឯកសារ **D99** ដីកាដំណោះស្រាយ, កថាខណ្ឌ ១២២ ["នៅក្នុងឆ្នាំ១៩៧៨ ជនបរទេសបួននាក់ត្រូវបានគេដុតទាំងរស់ជាមួយនឹងសំបកកង់ឡាន នៅចន្លោះមហាវិថីម៉ៅសេទុង និងសង្កាត់បឹងទំពុន។ នួន ជា ទំនងជាបានបញ្ជា ឌុច ឱ្យធ្វើយ៉ាងណាកុំឱ្យគេរកឃើញសាកសពជនទាំងនោះ"]។

[126] សំណុំរឿង ០០១-ឯកសារ **D99** ដីកាដំណោះស្រាយ, កថាខណ្ឌ ៣៣, ៥១-៥២។

[127] សំណុំរឿង ០០១-ឯកសារ **D99** ដីកាដំណោះស្រាយ, កថាខណ្ឌ ៤៤, ៥៣។

[128] សំណុំរឿង ០០១-ឯកសារ **D99** ដីកាដំណោះស្រាយ, កថាខណ្ឌ ៣១។

[129] សំណុំរឿង ០០១-ឯកសារ **D99** ដីកាដំណោះស្រាយ, កថាខណ្ឌ ៣១, ១១១។

[130] សំណុំរឿង ០០១-ឯកសារ **D99** ដីកាដំណោះស្រាយ, កថាខណ្ឌ ៣១ (សង្កត់ន័យបន្ថែមត្រង់ឃ្លាអក្សរទ្រេត)។

[131] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៥៦, *លើកយោង* ឯកសារ **D6.1.1073** ការដាក់ចម្លើយរបស់ កាំង ហ្គេកអ៊ាវ ឆ្លើយតបទៅនឹងសំណួរជាលាយលក្ខណ៍អក្សររបស់សហចៅក្រមស៊ើបអង្កេត, EN 00251378 (សង្កត់ន័យបន្ថែមត្រង់អក្សរទ្រេត)។

44. ការពិនិត្យត្រឹមត្រូវយុត្តិធម៌មួយលើដីកាដំណោះស្រាយក្នុងសំណុំរឿង ០០១ និងភ័ស្តុតាងនៅក្នុងសំណុំរឿង០០៤/២ បង្ហាញឲ្យឃើញថា អោ អាន មានឆន្ទានុសិទ្ធិ*ច្រើនជាង* ឌុច នៅក្នុងរបៀបដែលគាត់បានអនុវត្តសេចក្ដីណែនាំរបស់ខ្លួន។ ខណៈដែល អោ អាន ច្បាស់ណាស់ថា បានទទួលភារកិច្ចក្នុងការអនុវត្តគោលនយោបាយខ្មាំងរបស់ បកក ក៏ពិតមែន តែមានភ័ស្តុតាងតិចតួចណាស់ ឬគ្មានសោះ អំពីការទទួលបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់បុគ្គលណាមួយជាក់លាក់។ ខុសពី ឌុច ដែលមានសិទ្ធិអំណាចមានការកំណត់ ឬគ្មានសិទ្ធិអំណាចសោះក្នុងការដោះលែងអ្នកទោសដែលគាត់បានទទួលបញ្ជាឲ្យសួរចម្លើយ និងសម្លាប់។ ច្បាស់ណាស់ អោ អាន មានអំណាចធ្វើសេចក្ដីសម្រេចលើជោគវាសនារបស់បុគ្គលជាក់លាក់ណាមួយនៅក្រោមអំណាចរបស់ខ្លួន ដូចបានបង្ហាញតាមរយៈសេចក្ដីសម្រេចរបស់គាត់ឲ្យទុកជីវិត ភាព ដែលស្ថិតក្រោមការមើលថែរបស់ប្រាក់ យុត[132]។ ខុសពី ឌុច ចំពោះ អោ អាន មានភ័ស្តុតាងតិចតួចណាស់ ឬគ្មានសោះដែលថាគាត់ "ស្ថិតនៅក្រោមការតាមដានជាប់ជាប្រចាំ"[133] ដោយថ្នាក់លើរបស់គាត់។ ខណៈដែលអ្នកទាំងពីរទាំង ឌុច និង អោ អាន សុទ្ធតែមានភារកិច្ចក្នុងការអនុវត្តគោលនយោបាយ បកក និងក្រោមបញ្ជារបស់ថ្នាក់លើដូចគ្នាក៏ដោយ ក៏ អោ អាន នៅតែមានទំហំការងារធំជាងក្នុងរបៀបដែលគាត់បានអនុវត្តបទបញ្ជារបស់គាត់ និងស្ថិតក្រោមការគ្រប់គ្រងខ្នាតតូចបំផុតតិចតួចប៉ុណ្ណោះ។

45. ដីកាលើកលែងចោទប្រកាន់ក៏បានចាត់ទុកការភ័យខ្លាចបែបអត្តនោម័តិដូចដែលគេបានអះអាងរបស់ អោ អាន និងរបស់ ឌុច ក៏មានលក្ខណៈខុសគ្នាដែរ។ ដីកាលើកលែងការចោទប្រកាន់បានរកឃើញថា "អោ អាន បានអះអាងថា គាត់ត្រូវតែគោរពតាម [បញ្ជាទាំងអស់]ជាដាច់ខាត ហើយគាត់ភ័យខ្លាចចំពោះការបាត់បង់អាយុជីវិតរបស់គាត់បើគាត់មិនអនុវត្តតាម"[134] ដែលប្រាប់ឲ្យដឹងថា នេះជាមូលហេតុដែលរកឃើញថា អោ អាន មិនមែនជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុត"[135]។ ប៉ុន្តែ នៅក្នុងសំណុំរឿង ០០១ ស.ច.ស បានទទួលស្គាល់ថា ភ័ស្តុតាងរបស់ ឌុច ដែល

---

[132] ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១៧ ("ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ"), កថាខណ្ឌ ៥៩, ៦៩-៧០។ ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៣៩០ ["សាក្សីឈ្មោះ ញ៉ឹម កុល បានលើកឡើងថា *"មិនមានជនជាតិចាមណាម្នាក់ត្រូវបានទុកជាជីវិតទេ លើកលែងតែ ភា ដែលត្រូវបាន យុត ការពារ"]*, 414។

[133] សំណុំរឿង ០០១-ឯកសារ **D99** ដីកាដំណោះស្រាយ, កថាខណ្ឌ ១៧០។

[134] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៥៣៣។

[135] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៤៩៦, ៥២១-៥៣៥, ៥៥២។

ថា ការបោសសម្អាតរបស់ បកក បានធ្វើឱ្យគាត់ចាប់ផ្តើម "ភ័យស្លន់ស្លោរធ្វើអ្វីលែងកើត"[136] "ខ្លាចរហូតដល់គិតតែពីដេកទាំងយប់ទាំងថ្ងៃ" និងភ័យខ្លាចចំពោះអាយុជីវិតរបស់សមាជិកគ្រួសារគាត់[137]។ ការភ័យខ្លាចរបស់ ឌុច ត្រូវបានបន្ថែមតាមរយៈបទពិសោធន៍របស់គាត់ដោយសារគាត់បានដឹងថា សមាជិកជាន់ខ្ពស់ជាច្រើននាក់នៃ បកក ដែលស្ថិតក្នុងតំណែងខ្ពស់ជាងគាត់យ៉ាងឆ្ងាយ នៅក្នុងឋានានុក្រមបក្ស ត្រូវបានចាប់ដាក់គុក ធ្វើទារុណកម្ម និងសម្លាប់នៅ ស-២១។

46. ដោយសារបទបញ្ជា ការបង្ខិតបង្ខំ និងការគាបសង្កត់របស់ថ្នាក់លើទាំងនេះមិនបានដក ឌុច ចេញពីប្រភេទ"ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះ អោ អាន វិញ គេមិនអាចធ្វើដូច្នេះបានឡើយ។ បើចង់សម្រេចផ្សេងចំពោះ អោ អាន នេះគឺជាការអនុវត្តច្បាប់ខុសគ្នាតាមទំនើងចិត្តចំពោះមនុស្សដែលស្ថិតក្នុងស្ថានភាពស្រដៀងគ្នា។

## គ. កំហុសផ្នែកច្បាប់ដែលសម្រេចថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់"

47. ដីកាលើកលែងចោទប្រកាន់ផ្ទាល់បានឱ្យដឹងអំពីមូលហេតុមួយនៃការប្រព្រឹត្តិខុសគ្នាតាមទំនើងចិត្តចំពោះ អោ អាន និង ឌុច ដែលបង្ហាញថា ស.ច.ស.ជ ជឿថា *តាមការទាយ* និងតាមអង្គច្បាប់ប្រភេទ "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" អាចអនុវត្តបានចំពោះតែ ឌុច ម្នាក់ប៉ុណ្ណោះ។ តាមការស្ទាបស្ទង់របស់ខ្លួនទៅលើប្រវត្តិនៃការចរចារបស់ អ.វ.ត.ក ដីកាលើកលែងចោទប្រកាន់បញ្ជាក់ថា ""ឃ្លា "ជនដែលទទួលខុសត្រូវខ្ពស់បំផុត"" បានដាក់បញ្ចូលចំៗដោយយោងសំដៅទៅរក [...] កាំង ហ្គេក អ៊ាវ *ហៅ* ឌុច"[138]។ ដីកានេះបន្តអះអាងទៀតថា មានបំណងឱ្យ "ការចោទប្រកាន់ចំពោះមេដឹកនាំជាន់ខ្ពស់ទាំងនេះ *មិនត្រូវពង្រីកទៅកម្មាភិបាលថ្នាក់ក្រោមឡើយក្រៅតែឌុច* ដែលឈ្មោះរបស់គាត់ត្រូវបានពិចារណាដោយអង្គនីតិប្បញ្ញត្តិរួចហើយ"[139]។ ជាចុងក្រោយ ដីកាលើកលែងចោទប្រកាន់បានបញ្ជាក់យ៉ាងច្បាស់ថា "ជនគោលដៅរបស់ អ.វ.ត.ក គឺមេដឹកនាំជាន់ខ្ពស់ និង ឌុច *ដែលជាជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់*"[140] ។

[136] សំណុំរឿង ០០១-ឯកសារ **D99** ដីកាដំណោះស្រាយ, កថាខណ្ឌ ១៦៩។

[137] សំណុំរឿង ០០១-ឯកសារ **D99** ដីកាដំណោះស្រាយ, កថាខណ្ឌ ១៧០។

[138] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៤៧៣។

[139] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៤៧៨។

[140] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៥៤២ (សង្កត់ន័យបន្ថែមត្រង់អក្សរទ្រេត)។

48. ការសន្និដ្ឋានជាចុងក្រោយថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់" និងថា "ការចោទប្រកាន់មិនត្រូវពង្រីកទៅកម្មាភិបាលថ្នាក់ក្រោមក្រៅតែ ឌុច" មិនត្រឹមត្រូវទេ អាស្រ័យដោយយ៉ាងហោចណាស់ក៏មូលហេតុចំនួនប្រាំដូចតទៅ (i) ជាសេចក្តីថ្លែងការណ៍ផ្ទុយដោយផ្ទាល់ទាក់ទងនឹងយុត្តាធិការបុគ្គលដែលបានធ្វើឡើងជូនសភាកម្ពុជា ដោយឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលក្នុងពេលនោះស្ថាប័ននេះកំពុងតែពិចារណាលើច្បាប់ អ.វ.ត.ក ដូច្នេះ គឺជាការខកខានក្នុងការគោរពចំពោះចេតនារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតច្បាប់ អ.វ.ត.ក (ii) វាមិនស៊ីសង្វាក់គ្នាជាមួយនឹងការយល់យ៉ាងច្បាស់របស់អង្គការសហប្រជាជាតិ (អ.ស.ប) អំពីអត្ថន័យនៃប្រភេទ "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ក្នុងពេលនៃកិច្ចចរចា (iii) វាផ្ទុយនឹងសេចក្តីថ្លែងការណ៍របស់ ស.ច.ស.ជ ខ្លួនឯងផ្ទាល់ដែលគ្មានមូលដ្ឋានចំពោះអំណះអំណាងថា យុត្តាធិការបុគ្គលមានគោលបំណងកំហិតចំនួនជាក់លាក់នៃបុគ្គលដែលមានឈ្មោះរួចហើយ (iv) វាមិនស៊ីសង្វាក់នឹងអត្ថន័យធម្មតានៃច្បាប់ និងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និង (v) វារំលោភលើនិយាមសិទ្ធិមនុស្សអន្តរជាតិ និងការការពារដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា។ កត្តានីមួយៗនៃកត្តាទាំងនេះ នឹងត្រូវបានលើកយកមកបកស្រាយតាមលំដាប់លំដោយដូចខាងក្រោម។

## ១. ការសម្រេចថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់" គឺផ្ទុយទៅនឹងសេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងដោយប្រធានក្រុមចរចារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងពេលនៃកិច្ចចរចា ដូច្នេះ គឺជាការខកខានក្នុងការគោរពចំពោះចេតនាយ៉ាងច្បាស់របស់រាជរដ្ឋាភិបាលកម្ពុជា នៅពេលច្បាប់ អ.វ.ត.ក ត្រូវបានបង្កើត

49. ក្នុងពេលពិភាក្សាដេញដោលរបស់រដ្ឋសភាកម្ពុជាស្តីពីការធ្វើវិសោធនកម្មច្បាប់ អ.វ.ត.ក ដើម្បីឲ្យស្របទៅនឹងពាក្យពេចន៍នៃកិច្ចចរចាររវាង អ.ស.ប និង រាជរដ្ឋាភិបាលកម្ពុជា[141] ("កិច្ចព្រមព្រៀង អ.វ.ត.ក") អ្នកធ្វើច្បាប់ជាច្រើនរូបបានសួរថាតើនរណាខ្លះដែលនឹងត្រូវស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់តុលាការ[142]។ ឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលជាប្រធានក្រុមចរចាជា

[141] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, រាជធានីភ្នំពេញ, ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក")។

[142] ប្រតិចារឹកបកប្រែដោយ DC-Cam អំពីសម័យកាលដំបូងនៃនីតិកាលទីបីនៃសភាជាតិ ថ្ងៃទី៤-៥ ខែតុលា ឆ្នាំ២០០៤ ("ប្រតិចារឹកសភាជាតិ") ទំព័រ៩ [ឯកឧត្តម លី ធុចៈ "ប្រជាជន និងសង្គមស៊ីវិលចង់សុំឲ្យឯកឧត្តមបញ្ជាក់ឲ្យច្បាស់ថា តើ

មួយអង្គការសហប្រជាជាតិ បានឆ្លើយតបយ៉ាងច្បាស់ថា គ្មានចំនួនកំណត់សម្រាប់ជនដែលអាចនឹងស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ ហើយក៏គ្មានបញ្ជីឈ្មោះជនមុខសញ្ញាសក្តានុពលសម្រាប់កិច្ចស៊ើបសួរដែរ។ គាត់បានបញ្ជាក់យ៉ាងច្បាស់ផងដែរថា ប្រភេទ "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" គឺសំដៅទៅលើមុខសញ្ញាច្រើន។ និយាយឲ្យចំ សុខ អាន បានថ្លែងយ៉ាងដូច្នេះថា៖

> ប្រសិនបើយើងសួរសំណួរថា "តើនរណាខ្លះនឹងត្រូវចោទប្រកាន់បញ្ជូនខ្លួនទៅជំនុំជម្រះ? ទាំងអង្គការសហប្រជាជាតិ និងទាំងរាជរដ្ឋាភិបាលកម្ពុជា គឺមិនអាចផ្តល់ចម្លើយជូនបានទេ។ ដោយសារនេះជាកិច្ចការរបស់តុលាការ៖ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ បើសិនជាយើងមានបញ្ជីឈ្មោះមនុស្សដែលនឹងត្រូវធ្វើការចោទប្រកាន់ជំនួសតុលាការ នោះយើងរំលោភអំណាចរបស់តុលាការ។ ហេតុដូច្នេះយើងមិនអាចកំណត់អត្តសញ្ញាណ ក.ខ.គ ឬ ឃ បានឡើយសម្រាប់អ្នកដែលនឹងត្រូវចោទប្រកាន់បញ្ជូនខ្លួនទៅជំនុំជម្រះ។ ដើម្បីជាដំណោះស្រាយ យើងបានកំណត់អត្តសញ្ញាណជនមុខសញ្ញាចំនួនពីរ៖ *មេដឹកនាំជាន់ខ្ពស់* និង *ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត។* បើពិចារណាអំពី*មេដឹកនាំជាន់ខ្ពស់* យើងសំដៅទៅលើមនុស្សមិនលើសពី១០នាក់ទេ ប៉ុន្តែយើងមិនច្បាស់ថា ពួកគេជាសមាជិកគណៈអចិន្ត្រៃយ៍ នោះឡើយ។ នោះជាកិច្ចការរបស់សហព្រះរាជអាជ្ញា ដើម្បីសម្រេចថាតើនរណាជាមេដឹកនាំជាន់ខ្ពស់។ [...] យ៉ាងណាមិញ យើងនៅមានប្រភេទជនមុខសញ្ញាទីពីរទៀត។ ពួកគេមិនមែនជាមេដឹកនាំជាន់ខ្ពស់ទេ ប៉ុន្តែពួកគេបានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នង។ អីចឹងហើយបានជាយើងប្រើពាក្យថា *ជនដែលទទួលខុសត្រូវខ្ពស់បំផុត។* <u>គ្មាន</u>

---

នរណាជាមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត? តើពួកគេរួមបញ្ចូលផងដែរនូវប្រធានកងរបស់អង្គការដែរទេ?"] ទំព័រ១៤ [ឯកឧត្តម កែវ រេមី៖ "តើនរណាជាមេដឹកនាំជាន់ខ្ពស់? [...] តើប្រធានភូមិភាគនឹងត្រូវកាត់ទោសដែរឬទេ? ឬតើច្បាប់នេះធ្វើតែដើម្បីកាត់ទោសមេដឹកនាំ ៤ ឬ ៥នាក់? តើនរណាទៀតនឹងត្រូវកាត់ទោស? វាមិនយុត្តិធម៌ទេ បើសិនជាយើងកាត់ទោសតែមនុស្ស ៣ ឬ៤នាក់នោះ។"] ទំព័រ២៧ [ឯកឧត្តម អេង ឆៃអ៊ាង៖ "ខ្ញុំក៏មិនច្បាស់អំពីជនដែលទទួលខុសត្រូវខ្ពស់បំផុតដែរ។ តើជនទាំងឡាយណានោះនឹងត្រូវទទួលខុសត្រូវខ្ពស់បំផុតកម្រិតណា? [...] ខ្ញុំចង់ឲ្យតំណាងរដ្ឋាភិបាលបញ្ជាក់ថាតើការទទួលខុសត្រូវខ្ពស់បំផុតកម្រិតណា ដែលជនទាំងនោះត្រូវមាន។ [...] ខ្ញុំសូមរម្លឹកប្រជាជនកុំឲ្យមិនច្បាស់។ ប្រសិនបើយើងសង្កត់ធ្ងន់តែទៅលើថ្នាក់ខ្ពស់បំផុតនោះ យើងមានន័យថា ប៉ុល ពត ដែលស្លាប់បាត់ហើយហ្នឹង។"]។

ចំនួនមនុស្សជាក់លាក់ទេក្នុងក្រុមមុខសញ្ញាទីពីរនេះ ដែលនឹងត្រូវចោទប្រកាន់បញ្ជូនខ្លួនទៅជំនុំជម្រះ[143] (សង្កត់ន័យដើមត្រង់ឃ្លាមានគូសបន្ទាត់ពីក្រោម)។

## ២. ការសម្រេចថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់" មិនស៊ីសង្វាក់គ្នាជាមួយនឹងការយល់យ៉ាងច្បាស់អំពីយុត្តាធិការបុគ្គល និងចេតនារបស់ អ.ស.ប នៅក្នុងពេលចរចាទេ

50. ច្បាស់ណាស់ថា អ.ស.ប ដែលជាភាគីទីពីរនៃកិច្ចចរចាបង្កើត អ.វ.ត.ក បានរួមចំណែកនៅក្នុងការយល់ដឹងនេះថា យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក គ្មានការកំណត់ជាក់លាក់អំពីចំនួនឡើយ ប៉ុន្តែ ផ្ទុយទៅវិញ គឺទុកឲ្យសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតជាអ្នកកំណត់។ នៅក្នុងឆ្នាំ១៩៩៩ ក្រុមអ្នកជំនាញ អ.ស.ប ដែលបានចាត់តាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិដើម្បីស្វែងរកជម្រើសផ្សេងៗដែលល្អបំផុតក្នុងការនាំមកនូវយុត្តិធម៌ បានថ្លែងយ៉ាងដូច្នេះថា៖

> ក្រុមផ្តល់អនុសាសន៍ឲ្យសាលាក្តី ផ្តោតលើជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរបំផុតទៅលើសិទ្ធិមនុស្ស ក្នុងពេលគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ។ ការនេះរួមទាំង មេដឹកនាំជាន់ខ្ពស់ដែលមានការទទួលខុសត្រូវចំពោះការរំលោភផ្សេងៗ ព្រមទាំងថ្នាក់ទាបជាងនេះដែលមានការពាក់ព័ន្ធដោយផ្ទាល់នៅក្នុងអំពើយង់ឃ្នងយ៉ាងធ្ងន់ធ្ងរ។ យើងមិនចង់ផ្តល់ការកំហិតជាតួរលេខអំពីចំនួននៃជនដែលអាចជាមុខសញ្ញានៃកិច្ចស៊ើបសួរទាំងនេះ ទេ។ យ៉ាងណាមិញ វាអាស្រ័យទៅលើការយល់ដឹងរបស់ក្រុម តាមរយៈការពិគ្រោះយោបល់ និងការស្រាវជ្រាវបង្ហាញថា ចំនួនមនុស្សដែលនឹងត្រូវនាំយកមកជំនុំជម្រះ អាចស្ថិតនៅក្នុងចន្លោះពី ២០ ទៅ ៣០ នាក់[144]។

---

[143] ប្រតិចារិករដ្ឋសភា, ទំព័រ ៣០-៣១ (សង្កត់ន័យបន្ថែម)។

[144] របាយការណ៍របស់ក្រុមអ្នកជំនាញ សម្រាប់កម្ពុជា ដែលបានបង្កើតឡើងដោយអនុលោមតាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៥២/១៣៥, ឯកសារ អ.ស.ប លេខ A/53/850, S/1999/231, ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ ១៩៩៩, កថាខណ្ឌ ១១០ (សង្កត់ន័យបន្ថែម)។

51. ឯកអគ្គរដ្ឋទូត ដេវីត សេហ្វ័រ (David Scheffer) បានរម្លឹកថា "ដោយធ្លាប់បានចូលរួមក្នុងដំណើរការចរចារជាច្រើនឆ្នាំ [គាត់បានដឹងថា] គ្មានសមូទានណាមួយពីក្រុមចរចារ អ.ស.ប ដើម្បីបកស្រាយអំពីអត្ថន័យនៃយុត្តាធិការបុគ្គល ដើម្បីកម្រិតចំនួនជនសង្ស័យឱ្យនៅត្រឹមតែបុគ្គលប្រាំនាក់ជាក់លាក់នោះឡើយ"[145]។ ច្បាស់ណាស់ថា គ្មានភាគីណាមួយមានចេតនាបកស្រាយទៅតាមការបកស្រាយដូចដែលបានធ្វើឡើងដោយដីកាលើកលែងចោទប្រកាន់នោះឡើយ។

## ៣. ការសម្រេចថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់" ផ្ទុយនឹងការសម្រេចរបស់ ស.ច.ស.ជ ខ្លួនឯងនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ និងដីកាដំណោះស្រាយនៃសំណុំរឿង ០០៤/១

52. ការអះអាងនៅក្នុងដីកាលើកលែងចោទប្រកាន់ថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់" ក៏ផ្ទុយផងដែរទៅនឹងការសម្រេចរបស់ ស.ច.ស.ជ ខ្លួនឯងនៅក្នុងដីកាលើកលែងការចោទប្រកាន់ដែលទទួលស្គាល់ថា ក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បានសម្រេចក្នុងន័យបង្កប់ថា "ក្នុងអំណះអំណាង គ្មានអង្គសេចក្តីណាមួយទាំងផ្នែកនយោបាយ - ប្រវត្តិសាស្ត្រដែលថា កិច្ចចរចាស្តីពីការបង្កើត អ.វ.ត.ក បាននាំឱ្យមានការយល់ជារួម និងមានលក្ខណៈចាប់បង្ខំថា មានតែបុគ្គល(ដែលមានឈ្មោះ)មួយចំនួនកំណត់ជាក់លាក់ប៉ុណ្ណោះ នឹងត្រូវដាក់ឱ្យស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ។ ការជ្រើសរើសបុគ្គលទាំងឡាយដើម្បីធ្វើការស៊ើបអង្កេត និងចោទប្រកាន់បញ្ជូនខ្លួនទៅជំនុំជម្រះ គឺជាឆន្ទានុសិទ្ធិរបស់ ក.ស.ព និង ក.ស.ច.ស សុទ្ធសាធ និងដោយផ្អែកលើអង្គសេចក្តីនៃសំណុំរឿងនីមួយៗទាំងស្រុង"[146]។ ពាក្យពេចន៍ដូចគ្នានេះក៏មាននៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០៤/១ ដែលបានចុះហត្ថលេខាដោយ ស.ច.ស.ជ និង ស.ច.ស.អ ដែរ[147]។

53. ស្របតាមស្មារតីនៃសេចក្តីថ្លែងការណ៍របស់ឧបនាយករដ្ឋមន្ត្រី សុខ អាន ដូចបានដកស្រង់ខាងលើ ការសម្រេចនេះប្រាកដណាស់ថាជាការត្រឹមត្រូវ។ គេច្បាស់ណាស់ថា ទាំងរាជរដ្ឋាភិបាល និងទាំងអង្គការសហប្រជាជាតិ ជឿថា កិច្ចព្រមព្រៀង ឬ ច្បាប់ មានអត្ថន័យថា "មានតែបុគ្គល(ដែលមាន

---

[145] David Scheffer, "ប្រវត្តិចរចាស្តីពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក", *Cambodia Tribunal Monitor*, ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១១, ទំព័រ ១០។

[146] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៤៦១។

[147] សំណុំរឿង ០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយ(សំអាងហេតុ), កថាខណ្ឌ ៣៧។

ឈ្មោះ)មួយចំនួនកំណត់ជាក់លាក់ប៉ុណ្ណោះ នឹងត្រូវដាក់ឲ្យស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ។ ការអះអាងនៅក្នុងដីកាលើកលែងចោទប្រកាន់ផ្សេងពីនេះ គឺជាកំហុសផ្នែកច្បាប់យ៉ាងច្បាស់មួយដែលប៉ះពាល់ដល់ការសម្រេចចុងក្រោយរបស់ ស.ច.ស.ជ ដែលថា អោ អាន មិនស្ថិតនៅក្នុងប្រភេទនៃ "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ។

## ៤. ការសម្រេចថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់" ផ្ទុយនឹងអត្ថន័យធម្មតានៃច្បាប់ និងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក

54. ការសម្រេចរបស់ដីកាលើកលែងចោទប្រកាន់ ក៏ផ្ទុយផងដែរទៅនឹងអត្ថន័យធម្មតានៃច្បាប់ អ.វ.ត.ក ដែលបានសរសេរជាពហុវចនៈ (*ជនទាំងឡាយ* ដែលទទួលខុសត្រូវខ្ពស់បំផុត) និងសំដៅយ៉ាងច្បាស់ទៅលើប្រភេទមនុស្សណាមួយ ជាជាងបុគ្គលណាម្នាក់[148]។

55. វិធានផ្ទៃក្នុងក៏មានការគិតគូរទុកជាមុនអំពីបុគ្គលច្រើនជាងម្នាក់ ដែលនឹងត្រូវដាក់បញ្ចូលក្នុងប្រភេទ "ទទួលខុសត្រូវខ្ពស់បំផុត"។ វិធាន៥៣ ចែងថា "ប្រសិនបើសហព្រះរាជអាជ្ញាមានហេតុផលជឿថា ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកើតមានពិត សហព្រះរាជអាជ្ញាត្រូវបើកការស៊ើបសួរ ដោយបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេតប្រឆាំងនឹងបុគ្គលមួយ ឬច្រើនរូប *ឬ ប្រឆាំងនឹងអញ្ញាត្រជន*"[149]។ វាមិនទំនងទាល់តែសោះបើសិនជាបុគ្គលណាម្នាក់ដែលស្ថិតក្នុងប្រភេទ "មេដឹកនាំជាន់ខ្ពស់" នឹងជា "អញ្ញាត្រជន" ហើយយើងច្បាស់ណាស់ថា ឌុច គឺជាជនសង្ស័យដ៏មានសក្តានុពលម្នាក់ (ព្រមទាំងកំពុងជាប់ឃុំឃាំង) នៅពេលដែលវិធានផ្ទៃក្នុងត្រូវបានប្រកាសឲ្យប្រើ។ អាស្រ័យហេតុនេះ វិធាន៥៣ បង្ហាញថា ប្រភេទនៃជនទាំងឡាយដែលត្រូវបានចាត់ទុកថា "ដែលទទួលខុសត្រូវខ្ពស់បំផុត" គ្មានចេតនាកំហិតត្រឹមតែ ឌុច នោះទេ។

[148] ច្បាប់ អ.វ.ត.ក, មាត្រា ១-២។

[149] វិធាន ៥៣ នៃវិធានផ្ទៃក្នុង។

## ៥. ការសម្រេចថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់" គឺជាការរំលោភលើនិយាម សិទ្ធិមនុស្សអន្តរជាតិ និងការការពារដែលបានផ្តល់ដោយរដ្ឋធម្មនុញ្ញកម្ពុជា

56. វាគឺជានិយាមសិទ្ធិមនុស្សជាមូលដ្ឋាន ដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស[150] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[151] និងលិខិតុបករណ៍សិទ្ធិមនុស្សតំបន់ដទៃទៀត[152] ដែលចែងថា មនុស្សគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់។ សំខាន់ គោលការណ៍នេះត្រូវបានបញ្ជាក់ឡើងវិញដោយនាយករដ្ឋមន្រ្តី ហ៊ុន សែន ក្នុងនាមកម្ពុជា នៅក្នុងការប្រកាសឱ្យប្រើសេចក្តីថ្លែងការណ៍ទីក្រុងភ្នំពេញស្តីពីការអនុម័តិសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន[153]។ គោលការណ៍នេះក៏ត្រូវបានឆ្លុះបញ្ចាំងផងដែរនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែរ[154]។

57. ច្បាស់ណាស់ថា ការសម្រេចថា ប្រភេទនៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" អាចជា *ការទាយស្មាន* និងជាបញ្ហាច្បាប់ ការយោងទៅតែ ឌុច ម្នាក់ (ដោយពុំគិតអំពីភ័ស្តុតាងដែលបានបង្ហាញអំពីការទទួលខុសត្រូវប្រហាក់ប្រហែលរបស់មនុស្សផ្សេងទៀត) គឺជាការមិនបានប្រព្រឹត្តចំពោះ ឌុច និងអ្នកផ្សេងទៀតដោយស្មើភាពទេ ដែលជាការរំលោភគោលការណ៍ និងការការពារទាំងនេះ។

---

[150] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស, ១០ ធ្នូ ១៩៤៨, សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ២១៧A(III), ឯកសារ អ.ស.ប A/810, មាត្រា ៧។

[151] កតិការសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ញូវយ៉ក, ១៦ ធ្នូ ១៩៦៦, 999 UNTS 171, មាត្រា ១៤(១)។

[152] *សូមមើល ឧទាហរណ៍* សេចក្តីប្រកាសរបស់អាមេរិកស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់មនុស្ស, ដែលបានអនុម័តិដោយសន្និបាតអន្តរជាតិលើកទីប្រាំបួន ស្តីពីរដ្ឋរបស់អាមេរិក, ទីក្រុងបូហ្គូតា, ឆ្នាំ១៩៤៨, មាត្រា II។ ធម្មនុញ្ញ(Banjul)របស់អាហ្វ្រិក ស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន ដែលបានអនុម័តិនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១, បានចូលជាធរមាននៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៨៦, មាត្រា ៣(១)។

[153] សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន និងសេចក្តីថ្លែងការណ៍ទីក្រុងភ្នំពេញស្តីពីការអនុម័តិសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន និងសំណៅបកប្រែនៃសេចក្តីប្រកាសនេះ, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២, គោលការណ៍ទូទៅ #៣ ["មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នានៅចំពោះមុខច្បាប់"], ដែលបានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន (*សូមមើល* ទំព័រ ១០)។

[154] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, អនុម័តិនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា ៣១ ["[ប្រជាពលរដ្ឋ]ខ្មែរគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់"]។

## ឃ. កំហុសអង្គហេតុ ទាក់ទងនឹងការវាយតម្លៃលើភាពជឿទុកចិត្តបាននៃភស្តុតាង

### ១. ភស្តុតាងរបស់ ប្រាក់ យុត ត្រូវបានបញ្ជាក់ និងអាចជឿទុកចិត្តបាន

58. គោលជំហររបស់ដីកាលើកលែងចោទប្រកាន់ទាក់ទងនឹងភស្តុតាងរបស់ ប្រាក់ យុត មានភាពមិនច្បាស់លាស់។ ដីកានេះពឹងផ្អែកលើភស្តុតាងរបស់គាត់នៅត្រង់ផ្នែកស្តីពីមូលដ្ឋានឧក្រិដ្ឋកម្មដំបូង[155] ប៉ុន្តែនៅក្នុងកិច្ចពិភាក្សាដែលគ្មានសំអាងហេតុក្នុងកថាខណ្ឌចំនួនពីរនៅជិតចប់ដីកានោះ បានឲ្យដឹងថា ភស្តុតាងរបស់គាត់អាច "មិនគួរឲ្យទុកចិត្តបាន"[156]។ សំអាងហេតុដែលត្រូវបានផ្តល់ប្រកបដោយភាពខ្វះខាតនៃភាពជឿជាក់បានយ៉ាងច្បាស់នេះ មានន័យថា (i) ភស្តុតាងរបស់ ប្រាក់ យុត បានក្លាយជាការដាក់បន្ទុកបន្ថែមទៀតទៅលើ អោ អាន នៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីនាពេលក្រោយមករបស់គាត់ និង (ii) ប្រាក់ យុយ បានលាក់ទុក "ភាពទោមនស្ស" ជាមួយរបបកម្ពុជាប្រជាធិបតេយ្យ (ហើយដោយសារការជាប់ជំពាក់របស់ខ្លួន គាត់ចង់ឆ្លើយដាក់ទៅលើ អោ អាន សម្រាប់មូលហេតុនោះ)[157]។

59. មូលហេតុទាំងនេះមិនសមស្រប និងជាការប្រឆាំងទាំងស្រុងទៅនឹងភស្តុតាងគាំទ្រដ៏ច្រើនសន្ធឹកសន្ធាប់ និងការរកឃើញនៅក្នុងដីកាលើកលែងចោទប្រកាន់ខ្លួនឯងផង។ ទីមួយ បើសិនជា ប្រាក់ យុត ចង់ទម្លាក់កំហុសលើ អោ អាន ដោយសារតែគាត់ "ទោមនស្ស" ជាមួយនឹងរបបកម្ពុជាប្រជាធិបតេយ្យ (ហើយនឹងតួនាទីរបស់ អោ អាន នៅក្នុងរបបនេះ) ម្ល៉េះ គាត់ (ប្រាក់ យុត) បានចាប់ផ្តើមធ្វើដូច្នេះភ្លាមៗទៅហើយ គឺនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីលើកទីមួយរបស់គាត់ ដោយមិនរង់ចាំជាច្រើនឆ្នាំរហូតដល់មានការស្តាប់ចម្លើយក្រោយៗមកទៀត (ដែល ប្រាក់ យុត មិនប្រាកដថានឹងមានអ្វីកើតឡើង)។ ការសន្និដ្ឋានដែលមានហេតុផលខ្លាំងជាងនេះយ៉ាងច្រើននោះគឺថា ប្រាក់ យុត បានដឹងថា គាត់មិនអាចប្រាប់ការពិតដោយពុំបានភ្ជាប់ខ្លួនឯង ព្រមទាំង អោ អាន ឡើយ ហើយគាត់បានប្រើពេលវេលាខ្លះសម្រាប់ឲ្យគាត់អាចផ្សះផ្សារចិត្តខ្លួនឯងជាមុនសិនមុននឹងគាត់អាចធ្វើដូច្នេះបាន។

---

[155] *សូមមើល ឧទាហរណ៍* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៩១, ១៤២, ៣៣៣, ៤១០-៤១១, ៤១៣, ៤១៥-៤១៧។

[156] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៥០៣-៥០៤។

[157] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៥០៣-៥០៤។

60. ទីពីរ ការវាយតម្លៃដែលគ្មានហេតុផលនេះលើភាពជឿទុកចិត្តបានរបស់ ប្រាក់ យុត គឺជាខកខានក្នុងការពិចារណាទៅលើភស្តុតាងគាំទ្រដ៏ច្រើនសន្ធឹកសន្ធាប់របស់សាក្សីនានា ដែលនិយាយថា ប្រាក់ យុត និង អោ អាន បានធ្វើដូចអ្វីដែល ប្រាក់ យុត បាននិយាយអំពីអ្វីដែលគេបានធ្វើ។ ជាឧទាហរណ៍ ប្រាក់ យុត បានផ្តល់ភស្តុតាងថា អោ អាន បានបញ្ជាឲ្យគាត់ដក និងដាក់មេភូមិ និងមេឃុំ ហើយ យូ វ៉ាន់, ញឹម កុល និង ពៅ សារុំ ដែលសុទ្ធតែបានបញ្ជាក់បន្ថែមពីចំណុចនេះ[158]។ ប្រាក់ យុត បានផ្តល់ភស្តុតាងថា អោ អាន បានណែនាំឲ្យគាត់ដកទាំងឫស និងសម្លាប់ប្រជាជនធម្មតាដែលសង្ស័យថាមិនស្មោះត្រង់នឹងរបប ឬបដិវត្តន៍ ហើយ ញឹម កុល, សូ សារ៉េន ពុត គល់ និង ញ៉ែម ចេន សុទ្ធតែបានបញ្ជាក់បន្ថែមពីចំណុចនេះ[159]។ ប្រាក់ យុត បានផ្តល់ភស្តុតាងថា អោ អាន បានបញ្ជាឲ្យគាត់សម្លាប់ចាមទាំងអស់នៅក្នុងស្រុករបស់គាត់ ហើយ មួក សេងលី និង យូ វ៉ាន់ សុទ្ធតែបានបញ្ជាក់បន្ថែមពីចំណុចនេះ[160] ដូចគ្នានឹងភស្តុតាងអំពីចាមដែលគេបានសម្លាប់នៅទូទាំងតំបន់៤១ ក្នុងពេលដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ អោ អាន[161]។ ការទាត់ចោលភស្តុតាងគាំទ្រយ៉ាងល្អរបស់ ប្រាក់ យុត ដោយសារតែការស្មានទៅលើ "ភាពទោមនស្ស" របស់គាត់ជាមួយនឹងរបបកម្ពុជាប្រជាធិបតេយ្យ បានធ្វើឲ្យគាត់ទម្លាក់កំហុសទៅលើ អោ អាន ទាំងខុសនោះ មិនសមហេតុផលទាល់តែសោះ។

61. លើសពីនេះទៀត ការវាយតម្លៃលើភាពជឿទុកចិត្តបានរបស់ ប្រាក់ យុត នេះ គឺជាការប្រឆាំងទាំងស្រុងទៅនឹងការសន្និដ្ឋានផ្នែកអង្គហេតុនៅក្នុងដីកាលើកលែងចោទប្រកាន់ខ្លួនឯង ដែលបានបញ្ជាក់ទៅលើភស្តុតាងរបស់ ប្រាក់ យុត ផងដែរ។ ក្រៅពីភស្តុតាងរបស់ ប្រាក់ យុត ដីកាលើកលែងចោទប្រកាន់រកឃើញថា មានគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យក្នុងការ "កម្ទេច" ចាមទាំងអស់ត្រឹមឆ្នាំ១៩៨០ ថាកំណត់ហេតុពិស្តារត្រូវបានបង្កើតឡើង និងរក្សាទុកស្តីពីចំនួនប្រជាជនចាម ហើយ កែ ពក បានតាមដានដើម្បីធ្វើឲ្យប្រាកដថា ផែនការកម្ទេចចាម ដំណើរ

---

[158] ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១៩-២០, កំណត់សំគាល់ជើងទំព័រ ៤៧-៥៨។

[159] ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ២៧-៣២, កំណត់សំគាល់ជើងទំព័រ ៧៧-៩២។

[160] ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៥៧-៦២, កំណត់សំគាល់ជើងទំព័រ ១៧៦-១៩៩។

[161] ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៥៩, កំណត់សំគាល់ជើងទំព័រ ១៨៥-១៩១។ ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៣០៧, ៤១៤។ ឯកសារ **D360** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ ៦៤៧, ៦៥១, ៦៥៣, ៦៥៥។

ការទៅមុខតាមពេលវេលាកំណត់[162]។ ដីកាលើកលែងចោទប្រកាន់ក៏បានរកឃើញផងដែរថា តាមពិត ចាមនៅក្នុងស្រុកកំពង់សៀម និងស្រុកកងមាស ភាគច្រើនត្រូវបានសម្លាប់[163]។ ជាចុងក្រោយ ដីកាលើកលែងចោទប្រកាន់បានរកឃើញថា បញ្ជា និងការណែនាំនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ត្រូវបានធ្វើឡើងតាមការបញ្ជូនទៅថ្នាក់ក្រោម "ភាគច្រើនតាមខ្សែបណ្ដោយនៃការប្រាស្រ័យទំនាក់ទំនងនៅក្នុងខ្សែសង្វាក់នៃការបញ្ជា"[164]។ ទាក់ទងនឹងភស្តុតាងអំពីគោលនយោបាយរបស់មជ្ឈិមក្នុងការសម្លាប់ចាម ដែលតាមភស្តុតាងបង្ហាញថា គោលនយោបាយនោះតាមពិត ត្រូវបានអនុវត្តនៅមូលដ្ឋានក្នុងតំបន់ ៤១ និងក៏ជាភស្តុតាងអំពីគោលនយោបាយដែលត្រូវបានបញ្ជូនពីថ្នាក់លើទៅថ្នាក់ក្រោមដែល "ភាគច្រើនតាមរយៈខ្សែបណ្ដោយនៃការប្រាស្រ័យទំនាក់ទំនង" ដែលគឺជារឿងតែមួយគត់ដែលយើងរំពឹងទុកចំពោះអ្វីដែល ប្រាក់ យុត នឹងនិយាយពិតប្រាកដ គឺដូចដែលគាត់បាននិយាយថា គាត់បានទទួលបញ្ជាឲ្យសម្លាប់ចាម ពីថ្នាក់លើរបស់គាត់គឺ អោ អាន និងថាគាត់បានបញ្ជូនបញ្ជាទៅនោះទៅថ្នាក់ក្រោមបង្គាប់របស់គាត់ ដែលពួកគេជាអ្នកអនុវត្តបញ្ជាទាំងនោះ[165]។ ចំពោះដីកាលើកលែងចោទប្រកាន់ដែលហៅភស្តុតាងនេះថា "មិនគួរឲ្យជឿទុកចិត្តបាន" ខណៈដែលយើងដឹងថា នេះគឺជាភស្តុតាងយ៉ាងច្បាស់ដែលយើងគ្រប់គ្នាកំពុងតែទន្ទឹងរង់ចាំដោយផ្អែកលើភស្តុតាងដទៃទៀតនោះ ប្រាកដណាស់ថា មិនហេតុសមផលទាល់តែសោះ។

## ២. អានុភាពនៃគោលនយោបាយនានារបស់កម្ពុជាប្រជាធិបតេយ្យ និងការកន្លងផុតទៅនៃពេលវេលាទៅលើភស្តុតាងរបស់សាក្សី ត្រូវតែមានការវាយតម្លៃទៅតាមករណីនីមួយៗ

62. ដីកាលើកលែងចោទប្រកាន់បានសម្រេចថា "ដើម្បីជឿលើកំណត់ហេតុរបស់សាក្សី*ណាម្នាក់* ទោះជាដាក់បន្ទុក ឬដោះបន្ទុក អោ អាន ក្ដី តម្រូវឲ្យមានការថ្លឹងថ្លែងពិចារណាឲ្យបានច្រើន រួមទាំងបរិបទនៃរបបខ្មែរក្រហមដ៏តឹងរ៉ឹងផង *គឺរឿងអ្នកណាអ្នកនោះដឹង* និងការពិតអំពីព្រឹត្តិការណ៍ដែលបានកើតមានជិត ៤០(សែសិប)ឆ្នាំមកហើយ ដែលអាចជាចំណោទមួយដល់ការចងចាំ"[166]។

---

[162] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៤២-១៤៦។

[163] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៣០៧, ៤១៤។

[164] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៤៦៦។

[165] អំណះអំណាងនេះប្រើភស្តុតាងរបស់ ប្រាក់ យុត *ដោយផ្លាស់ប្ដូរទៅតាមការចាំបាច់* អំពីការចាប់ខ្លួន និងការដាក់ជំនួសមេភូមិ និងមេឃុំ ហើយនឹងភស្តុតាងរបស់គាត់អំពីការកំណត់អត្តសញ្ញាណ និងការដក "ខ្មាំង" ចេញពីចំណោមប្រជាជនធម្មតា។

[166] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៥០៦ (សង្កត់ន័យបន្ថែមត្រង់ឃ្លាទីមួយ; សង្កត់ន័យដើមត្រង់ឃ្លាទីពីរ)។

បន្ទាប់មក ដីកាលើកលែងចោទប្រកាន់ក៏បានសន្និដ្ឋានថា កត្តាទាំងនេះបង្ហាញអំពី "មន្ទិលលើសក្ខីកម្មនិយាយពីការចូលរួម និងតួនាទីរបស់ អោ អាន ក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទ"[167]។ ការសន្និដ្ឋាននេះមិនត្រឹមតែសម្រាប់ផ្នែកនៃភ័ស្តុតាងដែលអាចមានបញ្ហានោះទេ ដោយអះអាងថាកត្តាទាំងពីរនេះបានធ្វើឲ្យភ័ស្តុតាង*ទាំងអស់* អំពីការចូលរួមរបស់ អោ អាន ក្នុងឧក្រិដ្ឋកម្មត្រូវបានចាត់ទុកថា មិនអាចឲ្យជឿទុកចិត្តបានទេ។

63. នេះគឺជាការអះអាងដែលគ្មានហេតុផលយ៉ាងច្បាស់ក្រឡែតមួយផ្សេងទៀត។ ខណៈការបំបែកព័ត៌មានដោយខ្មែរក្រហម ធ្វើឲ្យប៉ះពាល់ដល់កម្រិតនៃការដឹង ហើយការកន្លងផុតទៅនៃពេលវេលា ប្រាកដណាស់ថាអាចប៉ះពាល់ដល់ការចងចាំក៏ពិតមែន ជាការមិនសមហេតុផលទេ ដែលចាត់ទុកភស្តុតាងអំពីទង្វើឧក្រិដ្ឋទាំងអស់របស់ អោ អាន ថាមិនអាចឲ្យជឿទុកចិត្តបាន ដោយសារតែកត្តាទាំងនេះនោះ។ នៅពេលអ្នកក្រោមបង្គាប់ កងការពារ និងអ្នកបើកបររបស់ អោ អាន ផ្តល់ភ័ស្តុតាងអំពីអ្វីដែល អោ អាន បាននិយាយ បានធ្វើ គឺគ្មានអ្វីមួយនៅក្នុងគោលនយោបាយខ្មែរក្រហមដែលថា*"រឿងអ្នកណា អ្នកនោះដឹង"* បានធ្វើឲ្យចុះខ្សោយដល់ភ័ស្តុតាងនេះឡើយ ដោយសារយើងបានដឹងថាអ្វីដែល អោ អាន បាននិយាយ បានធ្វើ *គឺជា* "រឿង" របស់សាក្សីទាំងនេះ។ ស្រដៀងគ្នានេះដែរ ខណៈដែលការកន្លងផុតទៅនៃពេលវេលា ប្រាកដណាស់ថានឹងអាចប៉ះពាល់ដល់ការចងចាំរបស់សាក្សី តែចៅក្រមមានហេតុផលដែលមានអំណាចកាត់ក្តីលើអង្គហេតុមិនចេះតែសន្មតដោយងាយៗថា សាក្សីគ្មានការចងចាំគួរឲ្យជឿទុកចិត្តបានអំពីព្រឹត្តការណ៍ដ៏វិនាសកម្ម និងជាព្រឹត្តិការណ៍ដែលបានធ្វើឲ្យមានការផ្លាស់ប្តូរដល់ជីវិតដែលបានកើតឡើង៤០ឆ្នាំមកហើយនោះ ដោយគ្មានការវិភាគទៅលើកត្តានានា ដូចជា រឿងរ៉ាវរបស់សាក្សី ការបង្ហាញពីមន្ទិល ឬភាពប្រាកដប្រជា និងការបញ្ជាក់គាំទ្រនៅក្នុងចំណោមសាក្សីនោះទេ។

64. តាមពិតទៅ បើសិនជាការអះអាងទាំងនេះត្រឹមត្រូវ ម្ល៉េះគ្មានប្រយោជន៍អ្វីក្នុងការបង្កើត អ.វ.ត.ក ទេ ពីព្រោះថា កត្តាទាំងឡាយដែលបានលើកយោងក្នុងដីកាលើកលែងចោទប្រកាន់ដែលធ្វើឡើងដើម្បីបង្ខូចតម្លៃភ័ស្តុតាង នឹងត្រូវអនុវត្តចំពោះភ័ស្តុតាងនៃកិច្ចស៊ើបសួរទាំងអស់ដែរ។ ការជឿខុសលើអំណះអំណាងត្រូវបានបង្ហាញតាមរយៈការផ្តន្ទាទោសជាស្ថាពរក្នុងសំណុំរឿង ០០១ និង ០០២/០១ ដែលបង្ហាញឲ្យឃើញថា ទោះបីជាការកន្លងផុតទៅនៃពេលវេលា និងសារៈសំខាន់នៃ

[167] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៥០៦ (សង្កត់ន័យបន្ថែមត្រង់ឃ្លាទីមួយ; សង្កត់ន័យដើមត្រង់ឃ្លាទីពីរ)។

ភាពសម្ងាត់របស់កម្ពុជាប្រជាធិបតេយ្យ ក៏ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌត្រូវបានបញ្ជាក់ ភស្តុតាង*លើសពីវិមតិសង្ស័យ*ដែរ។ នៅក្នុងសំណុំរឿង ០០៤/២ ភស្តុតាងបង្ហាញឱ្យឃើញថា សាក្សីឯករាជ្យមួយចំនួនធំបានរៀបរាប់អំពីសកម្មភាព និងអំពើប្រព្រឹត្តរបស់ អោ អាន តាមរបៀបមួយដែលស៊ីសង្វាក់គ្នាបំផុត ដូចមានចែងក្នុងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ[168] និងខាងក្រោមក្នុងផ្នែកស្តីពីការកំហុសអង្គហេតុ។

## ខ. ការសន្និដ្ឋានខុសចំពោះអង្គហេតុ ជាមួយនឹងការប៉ះពាល់ច្បាស់លាស់មួយ នៅលើបញ្ហាយុត្តាធិការបុគ្គល

65. ជាការបន្ថែមទៅលើបញ្ហាជាប្រព័ន្ធដែលបានកំណត់ខាងលើ ដីកាលើកលែងចោទប្រកាន់ក៏មានការសន្និដ្ឋានអំពីអង្គហេតុដែលមិនសមហេតុផលផងដែរនៅលើចំណុចជាក់លាក់មួយចំនួន។ កំហុសអង្គហេតុទាំងនេះបានដើរតួនាទីជាគន្លឹះមួយក្នុងការវាយតម្លៃរបស់ដីកាលើកលែងចោទប្រកាន់ស្តីពីយុត្តាធិការបុគ្គល។

66. នៅក្នុងករណីភាគច្រើន កំហុសផ្នែកអង្គហេតុបានកើតមានឡើងដោយសារតែការខកខានរបស់ដីកាលើកលែងចោទប្រកាន់ក្នុងការពិនិត្យឱ្យបានហ្មត់ចត់លើភស្តុតាងដែលមាននៅក្នុងសំណុំរឿង និងវិធីសាស្ត្រក្នុងការពឹងផ្អែកទៅលើភស្តុតាងតែពីរបីផ្នែកប៉ុណ្ណោះនោះ[169]។ ក្នុងករណីមួយចំនួន ការសន្និដ្ឋានដោយមិនត្រឹមត្រូវគឺជាការសន្និដ្ឋានលើអង្គហេតុដោយសង្ខេប ដែលមិនត្រឹមតែផ្ទុយទៅនឹងភស្តុតាងដ៏សន្ធឹកសន្ធាប់ដែលមាននៅលើសំណុំរឿងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្ទុយទៅនឹងការសន្និដ្ឋានអង្គហេតុជាក់លាក់ ដែលបានសរសេរនៅកន្លែងផ្សេងទៀតក្នុងដីកាលើកលែងការចោទប្រកាន់នោះផងដែរ។

---

[168] ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៩-៧៥, ៧៨-៨៨។

[169] ខណៈដែលចៅក្រមមានឆន្ទានុសិទ្ធិស្វែងរកភស្តុតាងមួយចំនួនដែលគួរឱ្យជឿជាក់ជាងភស្តុតាងផ្សេងទៀតនោះ មិនមានឆន្ទានុសិទ្ធណាត្រូវមើលរំលងភស្តុតាងផ្ទុយដ៏ច្រើនដោយមិនមានការពន្យល់ ចំពោះថាតើហេតុអ្វីបានជាភស្តុតាងដែលបានជ្រើសរើសទទួលបានការជ្រើសរើសនោះឡើយ។ *សូមមើលឧទាហរណ៍* វិធាន៦៧(៤) នៃវិធានផ្ទៃក្នុង ["ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ។"]។ *Muvunyi ទល់នឹង រដ្ឋអាជ្ញា*, ICTR-2000-55A-A, សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ ១៤៤, ១៤៧។ *រដ្ឋអាជ្ញា ទល់នឹង Gotovina & Markač*, IT-06-90-A, សាលដីកាអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ កថាខណ្ឌ៦១។ *រដ្ឋអាជ្ញា ទល់នឹង Perišić*, IT-04-81-A, សាលដីកាអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ កថាខណ្ឌ ៩២។

## ១. មានភស្តុតាងលើសលប់ដែលបញ្ជាក់ថា អោ អាន បានបញ្ជាឲ្យមានការចាប់ខ្លួន និងសម្លាប់មនុស្ស ជាច្រើននាក់

67. នៅក្នុងផ្នែកដែលធ្វើការវិភាគអំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ចំពោះ អោ អាន ដីកាលើកលែងចោទប្រកាន់រកឃើញថា អោ អាន បានពាក់ព័ន្ធក្នុងការចូលរួមប្រជុំដោយផ្ទាល់ ការផ្សព្វផ្សាយគោលនយោបាយ និងមាន "តួនាទីជាអ្នកសម្របសម្រួល" ខណៈដែល "ផ្ទុយពីនេះគឺមាន*ភស្តុតាងតិចតួចប៉ុណ្ណោះ* ដែលបង្ហាញថា បញ្ជាឲ្យចាប់ខ្លួន និងសម្លាប់មនុស្សត្រូវបានចេញដោយ អោ អាន"[170]។ ដូចគ្នានេះដែរ ដីកាក៏លើកឡើងផងដែរថា "ភស្តុតាងបង្ហាញថា អោ អាន អាចមានការពាក់ព័ន្ធក្នុងការចេញបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់មនុស្ស *តែមួយចំនួនតូច*"[171]។ ការរកឃើញដូច្នេះ គឺផ្ទុយទៅនឹងភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់ដែលមាននៅក្នុងសំណុំរឿង និងក្នុងករណីខ្លះទៀត ផ្ទុយទៅនឹងការសន្និដ្ឋានផ្នែកអង្គហេតុនៅកន្លែងផ្សេងទៀតនៅក្នុងដីកាលើកលែងចោទប្រកាន់នោះដែរ។

68. ទាក់ទងនឹងការសន្និដ្ឋានផ្នែកអង្គហេតុនៅក្នុងដីកាលើកលែងចោទប្រកាន់ខ្លួនឯងផ្ទាល់ សេចក្តីអះអាងដែលថា មាន "ភស្តុតាងតិចតួច" ដែល អោ អាន បានបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់មនុស្ស គឺផ្ទុយទៅនឹងការសន្និដ្ឋានថា អោ អាន បានចេញបញ្ជាឲ្យសម្រាប់អ្នកទោសនៅមន្ទីរសន្តិសុខមិត្តសុប/គ និងការចាប់ខ្លួន និងសម្លាប់ចាមនៅទូទាំងតំបន់ ៤១[172]។

69. សំខាន់ជាងនេះទៀត ការសន្និដ្ឋាននេះផ្ទុយទៅនឹងភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់ដែលមាននៅក្នុងសំណុំរឿង ដែលភាគច្រើនបំផុតដីកាលើកលែងចោទប្រកាន់មិនបានលើកឡើង។ ភស្តុតាងដែលបញ្ជាក់ថា អោ អាន បានចេញបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់មនុស្ស រួមមានភស្តុតាងដូចតទៅ៖

---

[170] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៥៤៩ (សង្កត់ន័យបន្ថែម)។

[171] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៤៩៧ (សង្កត់ន័យបន្ថែម)។

[172] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៣០៦, ៣០៦-៣០៧, ៣១០-៣១១, ៣១៧, ៣២១-៣២២, ៣២៨-៣៣១, ៣៩៥-៣៩៦, ៤១៤-៤១៨។

ក. អោ អាន បានចេញបញ្ជាឲ្យលេខាស្រុករបស់គាត់កំណត់អត្តសញ្ញាណអ្នកដែល "ប្រឆាំងនឹងបដិវត្តន៍ [...] អ្នកដែលចង់ផ្តួលរំលំបដិវត្តន៍ [...] [ឬ] អ្នកដែលមិនពេញចិត្តនឹងលក្ខខណ្ឌជីវិតរបស់ខ្លួន និងឲ្យចាប់អ្នកទាំងអស់នោះយកទៅកម្ទេចចោល"[173]។

ខ. អោ អាន បានកោះហៅកម្មាភិបាលសរុបប្រហែល ៥០នាក់ដោយផ្ទាល់ ឲ្យមកផ្ទះរបស់គាត់ដើម្បីប្រជុំ ហើយបានបញ្ជាកងទ័ពដែលស្ថិតនៅក្រោមបញ្ជាការរបស់គាត់ ឲ្យចាប់ខ្លួនពួកគេនៅពេលពួកគេមកដល់[174]។

គ. អោ អាន បានបញ្ជាឲ្យ ប្រាក់ យុត "ប្រមូល" ប្រធានឃុំនៅក្នុងស្រុកកំពង់សៀម។ បន្ទាប់មកគាត់ "បានដឹកនាំការចាប់ខ្លួនពួកគេ និងបានរៀបចំមនុស្សមកជំនួស"[175]។ អោ

---

[173] ឯកសារ **D219/120** កំណត់ហេតុស្តាប់ចម្លើយសាក្សី ប្រាក់ យុត ឆ.១៩-២០ ["តាអាន ចេញបញ្ជាឲ្យខ្ញុំកំណត់អត្តសញ្ញាណអ្នកដែលប្រឆាំងនឹងបដិវត្តន៍ អ្នកដែលចង់ផ្តួលរំលំបដិវត្តន៍ និងអ្នកដែលមិនពេញចិត្តនឹងលក្ខខណ្ឌជីវិតរបស់ខ្លួន ហើយឲ្យចាប់អ្នកទាំងអស់នោះយកទៅកម្ទេចចោល។ [...] បទបញ្ជានេះត្រូវបានអនុវត្តចំពោះឃុំផ្សេងៗទាំងអស់នៅក្នុងស្រុកកំពង់សៀម ហើយក៏អនុវត្តនៅក្នុងស្រុកបួនផ្សេងទៀតផងដែរ"]។ ឯកសារ **D219/855** កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ចេន ឆ.៣១ ["សៈ ពេលដែលប្រជុំគ្នានៅកំពង់ចាម តើគេមាននិយាយអំពីការចាប់ខ្លួនជនស៊ីវិលទេ? ឆ៖ កាលខ្ញុំទៅប្រជុំ គេនិយាយតែការចាប់កម្មាភិបាល រឿងស៊ីវិលគាត់បញ្ជាឲ្យតាមស្រុកវិញ។"]។

[174] ឯកសារ **D219/582** កំណត់ហេតុស្តាប់ចម្លើយ តូយ មៀច ឆ.៩២-៩៩ ["[អោ អាន] ហៅអ្នកនោះមកប្រជុំ ហើយក៏ចាប់ពួកគេតែម្តង។ គាត់មិនចាំបាច់ចុះទៅចាប់តាមផ្ទះម្តងមួយៗនោះទេ។ [...] គាត់ហៅមនុស្សទាំងនោះឲ្យប្រជុំនៅផ្ទះគាត់ ហើយចាប់ខ្លួនពួកគេ។ អ្នកដែលនៅសល់ត្រូវបានចាប់ដោយទាហានរបស់គាត់។ [...] នៅផ្ទះគាត់តែម្តង។ [...] មានការប្រជុំរាល់ថ្ងៃ និងមានការចាប់មនុស្សរាល់ថ្ងៃដែរ។ គេហៅកម្មាភិបាលឲ្យមកប្រជុំ ហើយចាប់ខ្លួនតែម្តង។ [...] សៈ តើមានមនុស្សប៉ុន្មាននាក់ដែលត្រូវគេចាប់ខ្លួន? ឆ៖ប្រហែល ៥០នាក់ មកពីគ្រប់ផ្នែកទាំងអស់។ សៈ តើពីផ្នែកណាខ្លះ? ពីផ្នែកកសិកម្ម ឧស្សាហកម្ម សិប្បកម្ម តម្បាញ ពាណិជ្ជកម្ម ភស្តុភារ។ ពួកគេទាំងនោះត្រូវបានជំនួសដោយកម្មាភិបាលភូមិភាគនិរតី។"]។ ឯកសារ **D219/837** កំណត់ហេតុស្តាប់ចម្លើយ សូ សារ៉េន ឆ.១០៦-១០៧ ["របៀបគេចាប់ចងពេលនោះគឺ គេហៅកម្មាភិបាលថ្នាក់ស្រុក ឬឃុំ យកទៅប្រជុំ រួចហើយគេចាប់បញ្ជូនទៅបាត់ម្តងមួយៗ។ ពេលណាគេចង់ចងកម្មាភិបាល គេតាំងតែហៅទៅប្រជុំនៅតំបន់។ ខ្ញុំធ្លាប់នៅព្រឹត្តិការណ៍ចាប់ចងនេះ ដែលពេលដែលគេចាប់អតីតប្រធានយោធាតំបន់ ខ្ញុំមិនចាំឈ្មោះគាត់ទេ។ ប៉ុន្តែពេលគេចាប់គាត់នោះ ខ្ញុំក៏នៅក្នុងព្រឹត្តិការណ៍នោះដែរ។ សៈ តើលោកដឹងថាពេលដែលគេចាប់ពួកហ្នឹង តើ តាអាន ដឹងរឿងហ្នឹងដែរឬទេ? ហើយតើ តាអាន ដឹងកន្លែងគុកគរដែរឬទេ? ឆ៖ បាទ គាត់ដឹងអំពីការចាប់ចងនោះ ព្រោះ តាអាន ជាអ្នកហៅមកប្រជុំហើយ។ ពេលចាប់ចងគឺគាត់ដាក់កងការពារប្រាំប្រាំមួយនាក់ សម្រាប់នៅខាងក្រៅ។ ហើយនៅពេលចប់ការប្រជុំ បើគាត់ត្រូវចាប់កម្មាភិបាលណាម្នាក់ គាត់នឹងឲ្យកងការពារនោះចាប់ភ្លួងតែម្តង។ ចំណែកម៉េចគាត់មិនដឹង ពីព្រោះគាត់ជាប្រធានគណៈតំបន់ ពីព្រោះគុកគរជាកន្លែងរបស់តំបន់។"]។

អាន បានអនុវត្តដំណើរការដូចគ្នាដើម្បីចាប់ខ្លួន និងដាក់ជំនួសមេឃុំដែលកំពុងបំរើការងារនៅក្នុងស្រុកដទៃទៀតនៃតំបន់ ៤១"[176]។

ឃ. អោ អាន បានបញ្ជាថា មន្ត្រីជាន់ខ្ពស់ លន់ នល់ ត្រូវតែចាប់ខ្លួន និងបញ្ជូនទៅស្រុកផ្សេងនៅក្នុងតំបន់៤១[177]។

---

[175] ឯកសារ **D117/71** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត ឆ.៣៨-៤០ ["តាមខ្ញុំចាំ ខ្ញុំបានទៅដល់ស្រុកកំពង់សៀម នៅខែមករា ឆ្នាំ១៩៧៧។ ប្រហែលខែកុម្ភៈ ឆ្នាំ១៩៧៧ ភូមិភាគនិរតីបានបញ្ជូនកម្មាភិបាលរបស់គេមកជំនួសគណៈឃុំចាស់នៅក្នុងស្រុកកំពង់សៀម។ [...] ដំបូងខ្ញុំរាយការណ៍ទៅ តាអាន អំពីសកម្មភាពរបស់គណៈឃុំចាស់ ហើយស្នើជំនួសពួកគេដោយកម្មាភិបាលមកពីភូមិភាគនិរតី។ ក្រោយពេលពិគ្រោះយោបល់ជាមួយ កែពក តាអាន បានស្នើឱ្យខ្ញុំធ្វើការផ្លាស់ប្តូរកម្មាភិបាលចាស់ៗទាំងនោះ។ [...] ខ្ញុំមិនបានចូលរួមក្នុងការចាប់ខ្លួនគណៈឃុំចាស់ទាំងនោះទេ។ តាអាន ដឹកនាំការចាប់ខ្លួន និងការជំនួសកម្មាភិបាលមកពីនិរតី។ ការចាប់ខ្លួន និងការជំនួសនោះត្រូវបានធ្វើឡើងដោយថ្នាក់តំបន់។"]។ ឯកសារ **D117/70** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត ឆ.៣៦ ["តាមពិតនៅក្នុងពេលប្រជុំជាមួយតំបន់ ខ្ញុំបានរាយការណ៍ពីភាពអសកម្មរបស់គណៈឃុំ ហើយតំបន់បានណែនាំឱ្យប្រមូលពួកគេយកទៅអប់រំនៅតំបន់។ ប៉ុន្តែខ្ញុំមិនដឹងថាមានអ្វីកើតឡើងចំពោះពួកគេទេ។"]។ ឯកសារ **D219/120** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត ឆ.៥១ ["ដូចដែលខ្ញុំបានឆ្លើយនៅក្នុងការស្តាប់ចម្លើយរបស់ខ្ញុំ នាខែមិថុនា ឆ្នាំ២០១៣ ខ្ញុំបានធ្វើរបាយការណ៍បញ្ជូនទៅ តាអាន។ ក្រោយមក តាអាន បានពិភាក្សាជាមួយ កែពក រួចហើយក៏រៀបចំចាត់ចែងដកមេឃុំដែលនៅសេសសល់ទាំងអស់នេះចេញៗ"]។ ឯកសារ **D219/138** កំណត់ហេតុស្តាប់ចម្លើយ យូ វ៉ាន់ ឆ.៤៥, ៤៧ ["ឆ៖ តើប្រាក់ យុត មានសិទ្ធិផ្លាស់ប្តូរមេឃុំដែរឬទេ ឬក៏គាត់ត្រូវសុំការអនុញ្ញាតពីតាអាន? ឆ៖ បទបញ្ជាច្បាស់ជាចេញពីតាអាន ហើយ ព្រោះគាត់ជាប្រធានតំបន់។ ខុម ជាអ្នកដឹក ប្រាក់ យុត ទៅប្រជុំជាមួយ តាអាន នៅថ្នាក់តំបន់។ ពេលត្រឡប់មកវិញ ខុម បានប្រាប់ខ្ញុំថា គេនឹងចាត់ចែងឱ្យមានមេឃុំថ្មីហើយ។ [...] ដូចខ្ញុំប្រាប់លោកស្រីម្សិលម៉ិញហើយថា មេឃុំចាស់ៗមួយចំនួនបានបាត់ខ្លួន គឺជាការទទួលខុសត្រូវពួកយោធាស្រុក។ តាមខ្ញុំស្មានបទបញ្ជាគឺចេញមកពីស្រុក ហើយស្រុកទទួលបញ្ជាមកពីថ្នាក់តំបន់។ ខ្ញុំពុំបានឮផ្ទាល់ពី ប្រាក់ យុត ទេ ប៉ុន្តែមេឃុំចាស់ៗមួយចំនួនបានបាត់ខ្លួន ២ថ្ងៃបន្ទាប់ពីគាត់ចូលរួមប្រជុំនៅថ្នាក់តំបន់ជាមួយ តាអាន។ ៤ ថ្ងៃក្រោយមកទៀតមេឃុំថ្មីៗក៏ត្រូវបានតែងតាំង ជំនួសមេឃុំចាស់ៗ។"]។ ប្រាក់ យុត លើកឡើងថា អោ អាន អាចចេញបញ្ជាផ្ទាល់ទៅអនុរបស់គាត់ឈ្មោះ ស៊ី ឱ្យអនុវត្តការចាប់ខ្លួនទាំងនេះ៖ ឯកសារ **D117/70** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត ឆ.៣៩ ["ខ្ញុំសូមបញ្ជាក់ថា តាអាន មិនបានបញ្ជាខ្ញុំឱ្យចាប់មនុស្សទាំងនោះទេ ប៉ុន្តែប្រហែលជា តាអាន បានបញ្ជាផ្ទាល់ទៅ តាស៊ី ដែលជាអនុខ្ញុំក៏មិនដឹង។"]។

[176] ឯកសារ **D117/71** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត ឆ.៤៣ ["ការតែងតាំងគណៈឃុំថ្មីមានលក្ខណៈដូចគ្នាសម្រាប់ឃុំនានា ក្នុងស្រុកទាំងអស់នៅក្នុងតំបន់៤១"]។

[177] ឯកសារ **D219/702.1.95** ប្រាក់ យុត, ប្រតិចារឹក, ១៩ មករា ឆ្នាំ២០១៦, 10.59.08-11.01.20 ["ដូចខ្ញុំលើកអីចឹងថា យកទៅអប់រំអ្នកដែលមានស័ក្តិយសធំៗដែលមិននៅខាងក្រោម ដូចថាមានការលំបាក ដូចថានៅជាមួយប្រជាពលរដ្ឋ ជាមួយសហករណ៍អីចឹង វាពិបាក។ អីចឹងយើងត្រូវបញ្ជូនទៅខាងលើ ដូចជា ពូអាន អីចឹង។ ហើយបើថា ពូអាន គាត់យកទៅធ្វើនៅគោកព្រីង ខ្ញុំអត់បានដឹងដែរ។ នេះខ្ញុំជម្រាបត្រង់ហ្នឹង មិនដឹងថាគាត់យកអ្នកសំខាន់ទៅគោកព្រីងអី។"]។

ង. អោ អាន ជូនកាលបានបញ្ជាឲ្យចាប់បុគ្គលដែលបានកំណត់អត្តសញ្ញាណជាក់លាក់ ដែលមានឈ្មោះក្នុងបញ្ជីដែលគាត់បានផ្តល់ទៅឲ្យអ្នកក្រោមបង្គាប់របស់គាត់[178]។

ច. ដើម្បីអនុវត្តការបោសសម្អាតនេះ អោ អាន បានបញ្ជាឲ្យផ្នែកសន្តិសុខរបស់គាត់ "ដកស្មៅ ដកទាំងឫស" ជាបញ្ជាមួយដែលជាលទ្ធផលបានបង្កើតឲ្យមានការចាប់ "ទាំងអស់ឲ្យតែជាខ្មែរ [អតីតលេខាតំបន់៤១] តា តាំង"[179] ហើយនឹង

ឆ. អោ អាន បានបញ្ជាមេឃុំរបស់គាត់ ឲ្យប្រើល្បិចជាមួយអ្នកដែលធ្លាប់ធ្វើការជាមួយរបប លន់ នល់ ដើម្បីឲ្យបង្ហាញខ្លួន ដោយសន្យាឲ្យតំណែងចាស់របស់ពួកគេវិញ បើសិនជាពួកគេបង្ហាញដោយខ្លួនឯង[180]។

---

[178] ឯកសារ **D219/120** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត ឆ.៣២, ៧៦, ៩៤ ["សៈ តើ តាអាន ធ្លាប់ឲ្យបញ្ជីឈ្មោះអ្នកដែលត្រូវចាប់ខ្លួនឲ្យលោកស្រីដែរឬទេ? ឆៈ ចាស, ខ្ញុំធ្លាប់ទទួលបញ្ជីឈ្មោះមនុស្សដែលត្រូវចាប់ខ្លួនពី តាអាន។ ខ្ញុំមិនដឹងអំពីតួនាទីនិងមុខតំណែងរបស់បុគ្គលទាំងអស់នោះទេដោយសារខ្ញុំមិនបានចាប់អារម្មណ៍។ ប៉ុន្តែខ្ញុំគិតថា ប្រហែលជាភូមិភាគផ្ញើបញ្ជីឈ្មោះមនុស្សទាំងអស់នេះមកឲ្យគាត់ ហើយ តាអាន ត្រូវផ្ញើបញ្ជីនោះមកខ្ញុំ ព្រោះបញ្ជីឈ្មោះមនុស្ស ដែលត្រូវចាប់ខ្លួនទាំងអស់នេះស្ថិតនៅក្នុងស្រុករបស់ខ្ញុំ។ [...] បើតំបន់បញ្ជូនបញ្ជីអ្នកដែលត្រូវចាប់ខ្លួនមនុស្សមកខ្ញុំ គឺខ្ញុំត្រូវចារអំពីការចាប់ខ្លួន។ ខ្ញុំត្រូវទុកបញ្ជីដែលផ្ញើរមកដំបូង ហើយក្រោយមកខ្ញុំប្រមូលអ្នកទោសដែលត្រូវបញ្ជូនទៅតំបន់តាមឈ្មោះដែលមាននៅក្នុងបញ្ជីនោះ។ ចំណែកអ្នកដែលមកដឹកអ្នកទោសទៅតំបន់ គឺបានផ្តល់បញ្ជីថ្មីមួយ ដែលមានឈ្មោះអ្នកទោសទាំងអស់នោះ ដើម្បីឲ្យខ្ញុំចារថា "បានបញ្ជូនទៅ" ហើយនៅលើបញ្ជីឈ្មោះនោះគឺមានឈ្មោះ តាអាន។ [...] វាជារឿងអាយុជីវិតគេ ដូច្នេះយើងត្រូវធ្វើការឲ្យបានហ្មត់ចត់។ [...] ពេលខ្ញុំទទួលបានបញ្ជីឈ្មោះអ្នកដែលត្រូវចាប់ខ្លួនពីតំបន់ហើយ ខ្ញុំត្រូវតាមដានលើប្រវត្តិរូបអ្នកទាំងអស់នោះ ដើម្បីឲ្យដឹងថាតើឈ្មោះនៅក្នុងបញ្ជីដែលគេចុចមកនោះត្រឹមត្រូវដូចការប្រាប់ពីថ្នាក់តំបន់ ឬក៏អត់។ ដូច្នេះខ្ញុំផ្តល់បញ្ជីឈ្មោះនេះទៅដល់មេឃំឲ្យតាមដាន ។ ក្រោយពីតាមដានចប់ហើយ មេភូមិរាយការណ៍មកមេឃំហើយ មេឃុំរាយការណ៍មកខ្ញុំ។ ខ្ញុំពិនិត្យនិងវិភាគដោយយោងទៅលើរបាយការណ៍របស់មេឃុំ រួចហើយខ្ញុំធ្វើបញ្ជីឈ្មោះថ្មីមួយទៀត ដោយចារបញ្ជាក់ពីមូលហេតុថាអ្នកណាត្រូវទុកអប់រំ អ្នកណាត្រូវបញ្ជូនទៅតំបន់ ដោយភ្ជាប់បញ្ជូនទៅតំបន់វិញជាមួយនឹងបញ្ជីឈ្មោះដែលអ្នកតំបន់យកមកនៅពេលដឹកអ្នកទោសទៅតំបន់។"]។

[179] ឯកសារ **D219/731** កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ចេន ឆ.៩០-៩១ ["សៈ លោកដឹងទេ ការកាប់សម្លាប់កម្មាភិបាលអ្នកណាអ្នករៀបចំ? ឆៈ ដូមានតែបញ្ជាពីលើ កែ ពក ហៅ តំបន់ មក តាអាន ហើយ តាអាន បញ្ជាមកមន្ទីរសន្តិសុខ ដូចដកស្មៅដកទាំងឫស។ [...] ចាប់ទាំងអស់ឲ្យតែខ្មែរ តាតាំង ដូចបងជីដូនមួយខ្ញុំគេចាប់ពីឃុំ ចៅហ្វាយស្រុកអីចាប់ទាំងអស់។ ស្អីតិចខ្លាំងហើយក្បត់អស់ហើយ។"]។

[180] ឯកសារ **D219/855** កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ចេន ឆ.១៦៦-១៧២ ["រយៈពេលនេះ ១ឆ្នាំម្តង។ ពេលប្រជុំ គេនិយាយពីការចាប់ខ្មាំងតាមខេត្តតំបន់ អស់ហើយ តាមភូមិឃុំម្តង អ្នកណាជាប់ពាក់ព័ន្ធអីជំនាន់ណា ប់ផ្តើមស្រាវជ្រាវ។ សៈ ចង់ដឹងឲ្យ

70. ពាក់ព័ន្ធនឹងការចេញបញ្ជាឲ្យសម្លាប់ ចំណុចនេះមានភស្តុតាងដូចតទៅ៖

ក. បញ្ជារបស់ អោ អាន ឲ្យ ប្រាក់ យុត និងលេខាស្រុកក្នុងតំបន់ ៤១ ដទៃទៀត "កំណត់អត្តសញ្ញាណអ្នកដែលប្រឆាំងនឹងបដិវត្តន៍ អ្នកដែលចង់ផ្តួលរំលំបដិវត្តន៍ និងអ្នកដែលមិនពេញចិត្តនឹងលក្ខខណ្ឌជីវិតរបស់ខ្លួន ហើយឲ្យចាប់អ្នកទាំងអស់នោះយកទៅកម្ទេចចោល"[181]។

ខ. បញ្ជារបស់ អោ អាន ឲ្យ ប្រាក់ យុត និងលេខាស្រុកក្នុងតំបន់ ៤១ ដទៃទៀត សម្លាប់ចាមនៅក្នុងតំបន់៤១ ទាំងអស់[182]។

---

លោករៀបរាប់អំពីរបៀបដែលគេធ្វើការ ដូចថាធ្វើម៉េចដើម្បីឲ្យគេអាចកំណត់រកខ្មាំងឃើញ ដែលគេមានការប្រជុំថ្នាក់ភូមិនៅថ្នាក់នៅវត្តតាមះ? ឆ៖ គាត់ឲ្យធ្វើនយោបាយ អ្នកណាធ្វើទាហានស័ក្តិ៥ ឲ្យស័ក្តិ៥វិញ គ្រូឲ្យធ្វើគ្រូ ធ្វើមន្ត្រីអី ប្រាប់គេទៅ គេឲ្យកាន់មុខតំណែងហ្នឹងវិញ។ គេរកអ្នកចេញ។ ដល់នេះធ្វើមែន ដល់គេប្រាប់ហើយ គេបញ្ជូនទៅសម្លាប់។ [...] ប្រាប់ប្រធានសហករណ៍ថា ទៅយើងស៊ើបសួរទៅ អ្នកណាមានមុខតំណែងអី រដ្ឋអត់ធ្វើបាបអីទេ គេឲ្យមុខតំណែងហ្នឹងវិញ។ អ្នកណាធ្វើទាហាន ធ្វើទាហាន។ [...] ស៖ ចុះ តាអាន មានទៅអត់ក្នុងការប្រជុំនោះ? ឆ៖ គាត់ទៅ គាត់ទៅប្រជុំ គាត់អ្នកម្ចាស់កម្មវិធីទាំងអស់ គាត់និយាយនៅនុង។ ស៖ តើលោកនៅទីនោះដែរឬ? ឆ៖ បាទខ្ញុំនៅទីនោះដែរ ខ្ញុំទៅការពារ។"]។

[181] ឯកសារ **D219/120** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត ឆ.១៩-២០ ["តាអាន ចេញបញ្ជាឲ្យខ្ញុំកំណត់អត្តសញ្ញាណអ្នកដែលប្រឆាំងនឹងបដិវត្តន៍ អ្នកដែលចង់ផ្តួលរំលំបដិវត្តន៍ និងអ្នកដែលមិនពេញចិត្តនឹងលក្ខខណ្ឌជីវិតរបស់ខ្លួន ហើយឲ្យចាប់អ្នកទាំងអស់នោះយកទៅកំទេចចោល។ [...] បទបញ្ជានេះត្រូវបានអនុវត្តចំពោះឃុំផ្សេងៗទាំងអស់នៅក្នុងស្រុកកំពង់សៀម ហើយក៏អនុវត្តនៅក្នុងស្រុកបួនផ្សេងទៀតផងដែរ។"]។

[182] ឯកសារ **D117/73** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត ឆ.៤, ១២, ១៥ ["ថ្ងៃមួយ តាអាន បានមកជួបខ្ញុំ ហើយខ្សឹបប្រាប់ខ្ញុំថា គណៈមជ្ឈិមចាប់ផ្តើមចាប់ខ្លួនជនជាតិចាម ហើយគាត់បញ្ជាឲ្យខ្ញុំស្រង់ឈ្មោះជនជាតិចាមទាំងអស់ដែលនៅក្នុងស្រុកខ្ញុំ។ ខ្ញុំមិនដឹងទាល់តែសោះអំពីមូលហេតុដែលគេឲ្យស្រង់ឈ្មោះ និងតាមរកចាប់ខ្លួនជនជាតិចាម។ ខ្ញុំក៏ប្រគល់ភារកិច្ចនេះឲ្យអនុប្រធានខ្ញុំឈ្មោះ ណាន ជាអ្នកស្រង់ឈ្មោះ។ [...] តាមពិតខ្ញុំទទួលបញ្ជាពីគណៈតំបន់ឲ្យកំណត់អត្តសញ្ញាណ ឧទាហរណ៍ អតីតទាហាន លន់ នល់ និងជនជាតិចាមនៅក្នុងស្រុករបស់ខ្ញុំ។ ក្រោយមកខ្ញុំក៏ផ្ទេរភារកិច្ចនេះឲ្យអនុប្រធានរបស់ខ្ញុំដែលមានឈ្មោះ ណាន និងស៊ី។ ក្រោយពីពួកគេស្រង់ឈ្មោះបានមកហើយ ខ្ញុំក៏បញ្ជូនឈ្មោះទៅថ្នាក់តំបន់។ [...] តាមពិត ខ្ញុំទទួលបញ្ជាឲ្យអនុវត្តធ្វើអ្វីមួយពីតាអាន ប៉ុន្តែខ្ញុំមិនច្បាស់ថា តាអាន ជាអ្នកផ្តួចផ្តើមបញ្ជានោះ ឬក៏គាត់ទទួលបញ្ជានោះមកពីថ្នាក់លើឬយ៉ាងណានោះទេ។"]។ ឯកសារ **D117/72** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត ឆ.៦៖ ["តាអាន មិនបានប្រាប់ហេតុផលអីទេ។ គាត់គ្រាន់តែប្រាប់ខ្ញុំថាឲ្យផ្តោតគោលដៅលើជនជាតិចាម និងអតីតទាហាន លន់ នល់ ហើយចាប់ខ្លួនពួកគេ។"] ឯកសារ **D117/71** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត ឆ.៤៨៖ ["ក្នុងពេលប្រជុំប្រចាំខែ តាអាន បានបញ្ជាឲ្យខ្ញុំ កំណត់អត្តសញ្ញាណប្រជាជនចាម និងអតីតទាហាន លន់ នល់ ក្នុងឃុំនីមួយៗ។"]។ ឯកសារ **D219/484** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត ឆ.៨-៩៖ ["ខ្ញុំសូមបញ្ជាក់ថាខ្ញុំបានទទួលបញ្ជាពីថ្នាក់តំបន់ ដើម្បីឲ្យចាប់ខ្លួន និងសម្លាប់ជនជាតិចាមទាំងអស់។ បញ្ជាដែលខ្ញុំបានទទួលមានភាពច្បាស់លាស់

គ. បញ្ជារបស់ អោ អាន ឲ្យសម្លាប់កម្មាភិបាលភូមិភាគបូព៌ា នៅភ្នំប្រុស[183]។

ឃ. បញ្ជារបស់ អោ អាន ឲ្យសម្លាប់មនុស្ស១០ឡានទាហាន នៅភ្នំប្រុស[184]។

ង. បញ្ជារបស់ អោ អាន ឲ្យសម្លាប់អ្នកទោស នៅវត្តតាមះ[185]។

ច. បញ្ជារបស់ អោ អាន ឲ្យសម្លាប់អ្នកទោស នៅមន្ទីរសន្តិសុខមិត្តសុប/គ[186] ហើយនឹង

---

អំពីការសម្លាប់ជនជាតិចាមទាំងនោះ។ [...] នៅពេលដែលការសម្លាប់ជនជាតិចាមទាំងនោះត្រូវបានធ្វើរួចរាល់ ខ្ញុំបានទទួលរបាយការណ៍មួយពីអនុរបស់ខ្ញុំ ឬមេឈ្លបអំពីចំនួនជនជាតិចាមដែលគេបានសម្លាប់ ហើយខ្ញុំក៏បញ្ជូនរបាយការណ៍នោះទៅឲ្យតាអាន ដែលស្ថិតនៅថ្នាក់តំបន់។ [...] ខ្ញុំសូមបញ្ជាក់ម្តងទៀតថា បញ្ជាដែលខ្ញុំបានទទួល គឺមានភាពច្បាស់លាស់ ដោយគេបានបញ្ជាក់ថា ត្រូវសម្លាប់ជនជាតិចាមទាំងអស់ចោល។"]។ ឯកសារ **D117/70** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត ឆ.៤៤៖ ["ស៖ ក្រៅពីការចាប់ខ្លួនគណៈឃុំទាំងអស់នោះ តើអ្នកស្រីនៅចាំបានថា តាអាន បានបញ្ជាឲ្យចាប់ខ្លួនមនុស្សផ្សេងទៀតទេ? ឆ៖ ចាស ខ្ញុំទទួលបញ្ជាពី តាអាន ឲ្យប្រមូលជនជាតិចាម និងអតីតទាហាន លន់ នល់។ បន្ទាប់មកខ្ញុំមិនដឹងថា មានអ្វីកើតឡើងចំពោះអ្នកទាំងនោះទេ។"]។ ឯកសារ **D219/138** កំណត់ហេតុស្តាប់ចម្លើយ យូ វ៉ាន់ ឆ.១០០ ["ជាធម្មតាបទបញ្ជា គឺចេញពីថ្នាក់យោធាតំបន់មកយោធាស្រុក ប៉ុន្តែ បើ ផែន ចាប់ ឬរកអ្នកទាំងនោះមិនឃើញ គាត់នឹងសុំឲ្យយោធាតំបន់ជួយ គឺនៅពេលនោះឯងដែល តាអាន ជិះឡានមកជួប និងប្រាប់ ប្រាក់ យុត ផ្ទាល់ ជួនកាលទៀតផ្ញើរសំបុត្រទៅឲ្យ។ ចំពោះការចាប់ខ្លួនជនជាតិចាម អតីតទាហាន លន់ នល់ និនងមេភូមិ មេឃុំចាស់ៗ គឺជាករណីពិសេសមួយ ដូច្នេះបានជា តាអាន បញ្ជាមកប្រាក់ យុត ដោយផ្ទាល់។"]។ *សូមមើលផងដែរ* ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ សពអ កថាខណ្ឌ ៥៥-៦២ ជើងទំព័រ ១៧៥-១៩៩។

[183] ឯកសារ **D219/855** កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ចេន ឆ.៤២ ["ស៖ តើ តាអាន ពាក្យសម្តីគាត់ជាក់ស្តែងដែលគាត់និយាយ គាត់និយាយថាដូចម្តេចខ្លះ អំពីវត្តភ្នំប្រុស? ឆ៖ គាត់ថា បើយើង -- ពួកមិត្តធ្វើលិខិតតមកចាប់ពួកបូព៌ា ឲ្យមកស្នាក់នៅកន្លែងគាត់ហ្នឹងទៅ ធ្វើនយោបាយជប់លៀង រៀនសូត្រ បាយហើយ គេយកទៅដាក់ឡាន យកទៅសម្លាប់នៅភ្នំប្រុស ភ្នំស្រី។"]។

[184] ឯកសារ **D6.1.379** កំណត់ហេតុស្តាប់ចម្លើយ កែ ពេជ្រវណ្ណៈ EN 00346157 [កូនប្រុសរបស់ កែ ពក ក៏បានប្រាប់អ្នកស៊ើបអង្កេតថា៖ "ខ្ញុំចាំបានថា បន្ទាប់ពីឪពុកខ្ញុំទទួលបានព័ត៌មានថា មានការសម្លាប់ប្រជាជនទាំងឡានៗនៅភ្នំប្រុសភ្នំស្រី។"]។

[185] ឯកសារ **D219/582** កំណត់ហេតុស្តាប់ចម្លើយ តូយ មៀច ឆ.៨៣-៨៧ ["ស៖ លោកនិយាយថា ក្រោយពេលសន្និបាតនោះមានការសម្លាប់ តើគេសម្លាប់មនុស្សប៉ុន្មាននាក់? ឆ៖ ប្រហែលជាប្រាំនាក់។ កន្លែងនោះអាចដាក់មនុស្សបួនប្រាំនាក់។ ពួកគេប្រហែលជាមិនចង់យកអ្នកទាំងនោះទៅកន្លែងផ្សេងនៅខាងលើៗ។ ដូច្នេះហើយបានជាពួកគេសម្លាប់អ្នកទាំងនោះ ហើយកប់នៅជិតនោះតែម្តង។ ស៖ តើលោកមានន័យថាម៉េច ពេលលោកនិយាយថា "មិនចង់យកទៅកន្លែងខាងលើៗ"? ឆ៖ ពេលនោះមានមនុស្សតែបួនប្រាំនាក់ ដូច្នេះគេមិនចង់យកទៅមន្ទីរសន្តិសុខគ។ បានជាពួកគេសម្លាប់អ្នកទាំងនោះ ហើយកប់ពួកគេនៅជិតនោះ។ ស៖ ចុះ "ខាងលើៗមានន័យដូចម្តេច"? ឆ៖ ខាងលើនេះសំដៅទៅមន្ទីរសន្តិសុខគ។ ស៖ តើលោកមានដឹងថា អ្នកណាជាអ្នកបញ្ជាសម្លាប់មនុស្សទាំងនោះដែរឬទេ? ឆ៖ គឺ តាអាន ពីព្រោះគាត់ជាមេតំបន់នោះ ហើយយោធាទាំងនោះក៏ជារបស់គាត់។"]។

ឆ. បញ្ជារបស់ អោ អាន ឲ្យសម្លាប់ស្ត្រីមានផ្ទៃពោះ និងវះពោះពួកគេ ទុកជាទណ្ឌកម្មដែលពួកគេបានសួរអំពីវាសនារបស់ប្ដីខ្លួន[187]។

71. អង្គហេតុខាងលើទាក់ទងតែនឹងស្ថានការណ៍ទាំងឡាយដែល អោ អាន បានចេញបញ្ជាដោយផ្ទាល់យ៉ាងច្បាស់ឲ្យសម្លាប់មនុស្ស។ លើសពីនេះទៀត យើងក៏មានភ័ស្តុតាងយ៉ាងច្រើនលើសលប់ថា អោ អាន ចេញបញ្ជាឲ្យសម្លាប់មនុស្ស៖

ក. ការប្រកាសរបស់គាត់ថា "សង្គ្រាមអត់ស្នូរ" ប្រឆាំងនឹងខ្មាំងហៀបនឹងចាប់ផ្ដើមហើយ និងថានឹងមាន "មនុស្សស្លាប់ [...] ជាង បេ៥២ចាក់ទៅទៀត"[188]។

[186] ឯកសារ **D219/732** កំណត់ហេតុស្ដាប់ចម្លើយ ញ៉ែម ចេន ឆ.៣៣-៣៧ ["សៈ អ្នកណាជាអ្នកបញ្ជាឲ្យសម្លាប់ពួកនោះ [អ្នកទោសផ្ទេរមកពីមន្ទីរសន្តិសុខគ]? ឆៈ បញ្ជាចេញពីប្រធានតំបន់ទៅ។ សៈ ប្រធានតំបន់ ឈ្មោះអី? ឆៈ គាត់ឈ្មោះ តាអាន។ សៈ សម្រាប់លោកផ្ទាល់ លោកមានវត្តមានផ្ទាល់នៅពេលដែល តាអាន បញ្ជាឲ្យសម្លាប់អ្នកទោសទាំងនោះទេ? ឆ.៣៥ៈ ខ្ញុំនៅផ្ទាល់ដែរ ពេលតាអាន បញ្ជាយោធា ឲ្យទៅប្រាប់សន្តិសុខ។ សៈ តើតាអាន នៅមន្ទីរសន្តិសុខនោះ ពេលគាត់បញ្ជាឲ្យសម្លាប់មែនទេ? ឆៈ គាត់នៅមន្ទីរក្នុង។ គាត់បញ្ជាឲ្យយោធាតទៅសន្តិសុខ។ សៈ ពេល តាអាន បញ្ជាតាមរយៈយោធា លោកនៅណា? ឆៈ ខ្ញុំនៅមន្ទីរក្នុងជាមួយគាត់។"]។

[187] ឯកសារ **D219/837** កំណត់ហេតុស្ដាប់ចម្លើយ សូ សារ៉េន ឆ.៧៥-៧៧ ["តែខ្ញុំធ្លាប់ឃើញព្រឹត្តិការណ៍មួយ គឺមានប្រពន្ធយោធាតំបន់ ដែលមានផ្ទៃពោះហើយប្ដីរបស់គាត់ត្រូវបានគេចាប់។ ប្រពន្ធយោធានោះ ចេះតែមកសួរ តាអាន អំពីប្ដីគាត់ញឹកញាប់។ តាអាន ក៏បញ្ជាឲ្យយោធារបស់គាត់ យកទៅសម្លាប់ ហើយវះពោះ។ សៈ តើហេតុការណ៍ហ្នឹង នៅវត្តតាមៈ ឬនៅកន្លែងណា? ឆៈ នៅមន្ទីរតំបន់ ប៉ុន្តែនៅស្រែខាងក្រោយ។ សៈ អ៊ីចឹង អ្នកសម្លាប់ស្ត្រីហ្នឹង គឺ រុន ហ្នឹងមែនទេ? ឆៈ អ្នកសម្លាប់ខ្ញុំអត់ដឹងដែរ។ គេមកប្រាប់ខ្ញុំ។ ខ្ញុំដឹងថា តែយកទៅគឺសម្លាប់ហើយ។"]។

[188] ឯកសារ **D219/226** កំណត់ហេតុស្ដាប់ចម្លើយ ពេញ វ៉ា ឆ.៦ ["ខ្ញុំឃើញ តាអាន ដំបូងនៅពេល តាអាន ទៅដល់នៅក្នុងខែមីនា ឆ្នាំ១៩៧៧។ គាត់បានកោះហៅបុគ្គលិកថ្នាក់តំបន់ប្រហែល ៣០០ នាក់ឲ្យចូលរួមប្រជុំ នៅវត្តតាមៈ នៅឃុំជ្រៃវៀន ហើយគាត់ប្រកាស់ប្រាប់ថា គាត់គឺជាប្រធានតំបន់ ៤១ថ្មី។ [...] ក្នុងការប្រជុំនោះគាត់បានប្រកាស់ថា "ពួកអាមុន រ៉ៃ លន់ នល់ ជិះសេះ លន់ នល់" ដែលមានន័យថា ពួកអ្នកមុនស្អប់របប លន់ នល់ តែក្រោយពេលពួកគេទទួលបានជ័យជម្នះ ពួកគេធ្វើដូចរបប លន់ នល់ ដដែល។ គាត់បន្ថែមថា "ចាប់ពីថ្ងៃនេះទៅនឹងសម្លាប់ច្រើនជាង បេ-៥២ចាក់ទៅទៀត!""]។ ឯកសារ **D219/498** កំណត់ហេតុស្ដាប់ចម្លើយ ពេញ វ៉ា ឆ.៥, ៧ ["នៅពេលប្រជុំ តាអាន និយាយថា ពីពេលនេះតទៅ នឹងមានមនុស្សស្លាប់ច្រើនជាង បេ ៥២ ទៅទៀត។ [...] តាអាន ក្រោកឈរ នៅចំពោះមុខទាំងអស់គ្នាហើយនិយាយថា "ពីថ្ងៃនេះតទៅ នឹងមានមនុស្សស្លាប់ជាង បេ ៥២ចាក់ទៅទៀត ដោយសារតែសង្គ្រាមអត់ស្នូរ" មានន័យថា បេ៥២ មានសំឡេងឮខ្លាំង ប៉ុន្តែសង្គ្រាមដែលគេនិយាយនៅពេលនោះ ពុំមានសូរសំឡេងអ្វីឡើយ។"]។

ខ. សេចក្តីថ្លែងការណ៍យ៉ាងច្បាស់របស់គាត់ជូន កែ ពក - ដែល អោ អាន ខ្លួនឯងធ្លាប់បានទទួលស្គាល់ - ថា គាត់បានបញ្ជាឲ្យសម្លាប់ទាហាន លន់ នល់[189]។

គ. ការពិតដែលអ្នកទោសត្រូវបានធ្វើទារុណកម្មយ៉ាងឃោរឃៅ និងសម្លាប់ចោលដោយកងការពាររបស់ អោ អាន ក្នុងបរិវេណតំបន់ ៤១ ដែលមានផ្ទះ និងមន្ទីររបស់ អោ អាន ផង[190]។

---

[189] ឯកសារ **D103.1.39** បទសម្ភាសន៍ អោ អាន ជាមួយវិទ្យុសម្លេងសហរដ្ឋអាមេរិក វីអូអេ ផ្សាយជាភាសាខ្មែរ, *ជនសង្ស័យនៃអំពើឃោរឃៅយុងឃ្លងនិយាយថា គាត់ "មិនខ្លាច" សាលាក្តី, ឋានទរកទេ,* ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១, EN 00750163 ["គាត់បាននិយាយថា ទោះបីជាគាត់ធ្លាប់បានទទួលបញ្ជាពីមេបញ្ជាការយោធាខ្មែរក្រហម កែ ពក ឲ្យសម្លាប់អ្នកគាំទ្រនៃរបប លន់ នល់ ក៏ពិតមែន តែគាត់បានលាក់ពួកគេនៅឯវាលស្រែសមូហភាព។ [...] គាត់បានប្រាប់ថ្នាក់លើរបស់គាត់ថា គាត់បាន "បោសសម្អាត" ឬ សម្លាប់ពួកគេអស់ហើយ "តែតាមពិត ពួកគេនៅឯវាលស្រែសោះ""។

[190] ឯកសារ **D219/800** កំណត់ហេតុស្តាប់ចម្លើយ សូ សារ៉េន ឆ.១៣៣-១៣៧, ២១០-២១១, ២២០-២២១, ២២៣, ២៣៣ ["តើគេសួរចម្លើយអ្នកទាំងនោះនៅទីណាដែរ? ឆ៖ កន្លែងហ្នឹងមានសាលារៀនមួយ មានតែមួយកន្លែងហ្នឹង។ វានៅខាងក្រោយផ្ទះ តាអូន។ ហើយគេសួរចម្លើយនៅទីនោះ។ ស៖ តើលោកមានបានចូលរួម ឬក៏បានឃើញផ្ទាល់នឹងភ្នែកការសួរចម្លើយអ្នកទាំងនោះដែរទេ? ឆ៖ កន្លែងហ្នឹង ជិតកន្លែងខ្ញុំ គឺជិតផ្ទះ តាអូន។ ខ្ញុំឃើញ។ ស៖ តើគេសួរចម្លើយយ៉ាងដូចម្តេចដែរ? ឆ៖ សួរហ្នឹងដូចសួរតែ ខ្សែអ្នកណាខ្សែអ្នកណើទៅ។ តែអ្នកទោសអត់ដែលឆ្លើយមកវិញផង។ ទោះបីគេព្យួរជើង ក៏មិនមានឆ្លើយអ្វី គេរុំស្បោងក៏មិនមាននិយាយអ្វីដែរ។ ស៖ តើអ្នកទោសទាំងនោះត្រូវគេធ្វើទារុណកម្មមែនទេ? ឆ៖ បាទ។ ស៖ តើលោកបានឃើញការធ្វើទារុណកម្មអ្វីដែរ ចំពោះអ្នកទោសទាំងនោះ? ឆ៖ ពេលខ្លះឆក់ខ្សែភ្លើង ពេលខ្លះគេព្យួរជើង។ [...] ឆ៖ ចាំ ឈ្មោះ ពិន និង ផិន។ ពិន ហ្នឹងចៅហ្វាយស្រុក ហើយ ផិន ហ្នឹងអនុ។ មានប្រធានយោធាម្នាក់ទៀត តែឆក់ខ្សែភ្លើងពេលសួរចម្លើយនៅមន្ទីរតំបន់ ហើយងាប់នៅនៅក្នុងមន្ទីរតំបន់។ ខ្ញុំអត់ស្គាល់ឈ្មោះដែរ។ ស៖ តើលោកបានចូលរួមក្នុងការសួរចម្លើយដែរ ឬទេ? ឆ៖ កន្លែងហ្នឹងគឺកន្លែងខ្ញុំដេកតែម្តង ព្រោះគេសួរហ្នឹង សួរនៅផ្ទះ តាអូន។ អ៊ីចឹង ខ្ញុំអង្គុយមើលគេទៅ។ [...] ព្រោះ [អោ អាន] មិនដែលមករវីរវល់ទេ។ សួរចម្លើយគឺសួរតែដោយកងការពារគាត់ទេ។ កងការពារគាត់ពីរបីនាក់មកតខ្សែភ្លើងឆក់អ្នកទោសនៅកន្លែងខ្ញុំដេកហ្នឹង។ [...] មិនមែន តាអាន បញ្ជាមកទេ។ តែកងការពារ តាអាន មកសួរចម្លើយហើយឆក់ខ្សែភ្លើងទៅ។ [...] ស៖ តើលោកចាំឈ្មោះកងការពារ តាអាន ដែលបានសួរចម្លើយ និងបានធ្វើទារុណកម្មអ្នកទោសទាំងបីនាក់នោះដែរទេ? ឆ៖ ខ្ញុំចាំច្បាស់តែម្នាក់ឈ្មោះ រុន។ [...] ដំបូងពេលខ្ញុំ ទៅធ្វើការនៅមន្ទីរតំបន់ ខ្ញុំនៅយាមនៅប៉ុស្តិ៍នៅកន្លែងការពារ ហើយកន្លែងសួរចម្លើយនៅចម្ងាយប្រហែលជា ៥០ម៉ែតពីហ្នឹង។ ខ្ញុំពុំដែលធ្លាប់នឹងស្ថានភាពបែបហ្នឹងទេ គឺពេលនោះឯងដែលខ្ញុំបានឮសំឡេងស្រែក និងថ្ងូរទាំងនោះ។ ពេលព្រលឹម ខ្ញុំនឹកឃើញ ខ្ញុំក៏នាំគ្នាពីរបីនាក់ទៅមើល ហើយឃើញសាកសពមួយ និងឃើញអំបែងដបនៅហ្នឹង។ ខ្ញុំឮគេវ៉ៃស្រែកហ្នឹង បីបួនយប់ម្តង។"]។ ឯកសារ **D219/776.1.1** បទសម្ភាសន៍ សូ សារ៉េន ដោយ DC-Cam, EN 01309880-92 ["ចឹងខ្ញុំដេកនៅផ្ទះរោងក្រោយចឹង យប់ៗខ្ញុំឮតែគេវាយមនុស្សសួរចម្លើយ វាយមនុស្សសួរ ចម្លើយ អូយៗៗៗ! ស្រែករកពុកអើយម៉ែអើយ ចឹងបើចាក់គ្នាអំបែងដបនោះ។ [...] ដល់ព្រឹកឡើងខ្ញុំទៅមើល ទៅមើលឃើញមនុស្សងាប់នៅរោងហ្នឹងរួច ឃើញដបហ្នឹងវាយ ដបចាក់ផងអីផង ខ្ញុំអាំណោចអធម៌ពេលហ្នឹង ពេលគេស្រែកហ្នឹង។ [...] ប្រធានយោធាស្រុកមួយទៀតយកមក

ឃ. ការពិតដែល អោ អាន បានធ្វើដំណើរទៅមន្ទីរសន្តិសុខមិត្តសុប/គ គឺដើម្បីឲ្យប្រាកដថា បញ្ជាសម្លាប់អ្នកទោសពិតជាបានអនុវត្តប្រាកដមែន[191]។

ង. សំណើ និងការទទួលរបាយការណ៍របស់ អោ អាន អំពីដំណើរការនៃការសម្លាប់មនុស្សនៅតំបន់ ៤១[192]។

---

កន្លែងតំបន់សួរចម្លើយអីចឹង។ កាលហ្នឹងឆក់ខ្សែភ្លើង ឆក់វ៉ៃភ្លើងប៉ុនហ្នឹងទន់ខ្លួនល្អក ចឹងអាប៉ុមួយទៀតអនុស្រុកហ្នឹងឆក់ខ្សែភ្លើងឡើងទន់ ឲ្យខ្ញុំយកទៅចោលនៅវាលស្រែ តែខ្ញុំមិនបានយកទៅទេ ខ្ញុំអត់ហ៊ាន ដឹងថាចោលដឹងថាគេឲ្យយកវាយចោលហើយ។"] EN 01309895-97 ["ទៅសួរហើយ ជួនកាលចាប់មកកន្លែងហ្នឹង ចងជើងក្ដួរចឹង ហើយយោលគ្នាចឹងទង្គិចក្បាលអាគុសាលារៀននោះ។ [...] ជួនកាលជ្រលក់ទឹកពាងក៏មានដែរ។ [...] ជួនកាលយកអាថង់ផ្លាស្ទិចរុំ [អ្នកទោស] ចេះ ខ្ញុំស្គាល់ទាំងអស់ហ្នឹង។ សៈ [...] សួរចម្លើយអីហ្នឹង គេមានបង្រៀនយើងពីរបៀបសួរចម្លើយដែលអត់? ឆៈ កាលហ្នឹងមិនមែនខ្ញុំអ្នកសួរអីទេ អញ្ចឹងៗ ប៉ុន្តែខ្ញុំនៅហ្នឹងដែរ។ សៈ បានឃើញដែរ? ឆៈ បាទ! បានទៅមើល។ ថាតំបន់ គឺថាខ្ញុំទៅត្រង់ណាក៏ខ្ញុំទៅដែរ។ ប៉ុន្តែត្រង់គេប្រាប់អ្នកហ្នឹងឲ្យសួរម៉េចគឺខ្ញុំអត់បានដឹងហ្នឹងគេទេ។ អត់ដឹងហ្នឹងគេទេ។ [...] សៈ ហើយនៅមន្ទីរតំបន់ហ្នឹង មានរបៀបធ្វើទារុណកម្មជ្រលក់ក្បាលក្នុងទឹកពាងអីអញ្ចឹងដែរ? ឆៈ ការពិត ពាងៗអីហ្នឹងដូចជាគ្មានរៀបចំអីទេ។ ការពិត មានទឹកមានអីនៅហ្នឹងហើយ សាលារៀនហ្នឹងហើយ ព្យួរអញ្ចឹង ជ្រលក់អញ្ចឹង ចងជើងឡើងលើអញ្ចឹងទៅ។ យោលចឹង ទង្គិចក្បាលគ្នាម៉ុងៗអញ្ចឹងទៅ។ សៈ លោកពូ បានឃើញ? ឆៈ ឃើញហ្នុង ស្រីៗពីរនាក់បងប្អូនចាប់មក ចងអត់មានខោះដាក់។ ចងនៅមុខរោងអញ្ចឹង ចងស្លាបសេកចោលនៅហ្នឹងណា។ ស្រាប់តែព្រលឹមឡើងបាត់ បាត់រកអត់ឃើញ។ រកអត់ឃើញទៅណាអញ្ចេះ ទៅអើតមើលក្នុងអណ្ដូង នៅក្នុងអណ្ដូងទឹក ប៉ុន្តែអត់ងាប់ទេ។ លោតទាំងពីរនាក់បងប្អូន ជាប់ប្រតាយគ្នាចឹង។ លោតក្នុងអណ្ដូងហ្នឹង។ ហើយ អាប៉ុ ហ៊ុំ ចេះអីមិនដឹង, ហ៊ុំ ហ្នឹង អីចឹងហើយ ហ៊ុំ ហ្នឹងហើយយកឫស្សី បង្អោងត្នោតហ្នឹងការលើកមក។ ការចំអាចំណងលើកមក ២នាក់ លើកតែម្នាក់ឯងរួច។ សៈ លើករួចដែរ? ឆៈបាទ! សៈ ការពីអណ្ដូងមកហ្នឹង? ឆៈ បាទ! លើកពីក្នុងអណ្ដូងមក។ អណ្ដូងជ្រៅដែរ ប្រហែល ៤-៥ ម៉ែត្រដែរ។ សៈ នៅណាហ្នឹង? ឆៈ នៅព្រៃទទឹងហ្នឹង។"]។ *សូមមើលផងដែរ* ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ អពអ កថាខណ្ឌ ៤៧-៥០ ជើងទំព័រ ១៣៩-១៥៦។

[191] ឯកសារ **D219/732** កំណត់ហេតុស្ដាប់ចម្លើយ ញ៉ែម ចេន ឆ.៣០-៤០ ["សៈ នៅពេលដែលគេដឹកទៅ ពីមន្ទីរតំបន់ទៅមន្ទីរសន្តិសុខគរ តើអ្នកដែលគេដឹកទៅដើរដោយសេរីទេ? ឆៈ គេហៅដាក់ឡាន ប្រាប់ថា ដូចទៅរៀន ទៅប្រជុំអ៊ីចឹង។ ពេលទៅដល់មន្ទីរសន្តិសុខគរ គេហៅចូលបន្ទប់ម្ដងមួយ រួចគេចាប់ចង។ [...] បន្តិចមកគេយកទៅវ៉ៃចោលតែម្ដងនៅយប់នោះ ឬយប់បន្ទាប់។ សៈ អ្នកណាជាអ្នកបញ្ជាឲ្យសម្លាប់ពួកនោះ? ឆៈ បញ្ជាចេញពីប្រធានតំបន់ទៅ។ សៈ ប្រធានតំបន់ ឈ្មោះអី? ឆៈ គាត់ឈ្មោះ តាអាន។ សៈ សម្រាប់លោកផ្ទាល់ លោកមានវត្តមានផ្ទាល់នៅពេលដែល តាអាន បញ្ជាឲ្យសម្លាប់អ្នកទោសទាំងនោះទេ? ឆៈ ខ្ញុំនៅផ្ទាល់ដែរ ពេលតាអាន បញ្ជាយោធា ឲ្យទៅប្រាប់សន្តិសុខ។ [...] សៈ តើ តាអាន ដែលទៅការិយាល័យមន្ទីរសន្តិសុខនោះទេ? ឆៈ ទៅ។ សៈ តើលោកទៅជាមួយគាត់ទេ? ឆៈ ខ្ញុំទៅ។ សៈ តើ តាអាន ទៅធ្វើអី ទៅកន្លែងនោះដើម្បីអី? ឆៈ គាត់ចង់ដឹងថា បញ្ជាទៅធ្វើអស់ ឬមិនអស់ គាត់ចង់ដឹងតែប៉ុណ្ណឹង។"]។

[192] ឯកសារ **D219/120** កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ យុត, ឆ.១៤, ២៧ ["នៅពេលដែលខ្ញុំផ្ទេរការងារឲ្យ ស៊ី ជាអនុប្រធានខ្ញុំហើយ ខ្ញុំមិនចាប់អារម្មណ៍នឹងតាមដានទៅមើលថា ជនជាតិចាមទាំងនោះត្រូវយកទៅសម្លាប់នៅកន្លែងណាមួយនៅទួលបេង

ច. ការជួបប្រជុំរបស់ អោ អាន ជាមួយ ប្រាក់ យុត ដើម្បី "សម្រេចលើវាសនា" របស់អ្នកទោសម្នាក់[193] ហើយនឹង

ឆ. ការពិតដែល អោ អាន ខ្លួនឯងផ្ទាល់បានអមដំណើរឡានកាំមីញ៉ុងដឹកអ្នកទោសពេញមួយគ្រឿងមកពីភូមិភាគបូព៌ា ដែលក្រោយមកពួកគេត្រូវបានយកទៅសម្លាប់ចោល[194]។

---

នោះទេ។ ស៊ី គ្រាន់តែរាយការណ៍ប្រាប់មកខ្ញុំថាបានអនុវត្តបញ្ចារួចរាល់ហើយ។ ចំណែកខ្ញុំក៏បានរាយការណ៍បន្តទៅថ្នាក់តំបន់ថាការងារនោះបានអនុវត្តរួចរាល់ហើយ។ [...] នៅក្នុងរបាយការណ៍ដែលខ្ញុំបានផ្ញើរទៅ តាអាន គឺមានរៀបរាប់អំពីចំនួន ឈ្មោះ និងមូលហេតុនៃការចាប់ខ្លួន ដាក់ឃុំឃាំង ដោះលែង និងការសម្លាប់"]។ ឯកសារ **D219/855** កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ចេន, ឆ.៥៨-៥៩ ["ស៖ លោកដឹងទេថា តើ តាអាន ឬក៏ តាអួន គាត់មានបានទទួលរាយការណ៍ពីខាងមន្ទីរសន្តិសុខទាំងអស់ហ្នឹងប្រាប់អំពីថា ឥឡូវនៅមន្ទីរសន្តិសុខដំណើរការដល់នេះ សម្លាប់មនុស្សស្អីៗចេះហើយ? ឆ.៥៨៖ ខ្ញុំអ្នកទៅទទួល គាត់បញ្ជាថា កូនឯងទៅ "គ" ទៅយកឯកសារ ហើយខ្ញុំយកជូន គាត់ (សាក្សីថា "គាត់" សំដៅលើ តាអាន)។ គាត់ហៅថា នីរសារឯងទៅសន្តិសុខ "គ" ហើយជិះម៉ូតូទៅនឹងគេទៅ ហើយក្រដាសហ្នឹង គេដាក់ស្រោមជិតឈឹង។ ស៖ តើលោកដឹងថា សំបុត្រហ្នឹងមានពត៏មានអីខ្លះទេ? ឆ.៥៩៖ គ្រាន់តែដឹងថា ពត៏មានពីសន្តិសុខហ្នឹង ពត៏មានអីខ្ញុំមិនដឹងទេ ប៉ុន្តែវាគ្មានរឿងអីទេ តាអាន និយាយ គឺរឿងរបាយការណ៍អ្នកស្លាប់ហើយ។ ខ្ញុំនៅជាមួយគាត់ នៅក្បែរគាត់ កំពុងហូបបាយ គាត់ថា មនុស្សប៉ុន្មានត្រូវគេយកទៅរៀនសូត្ររួចហើយ មិនបានប៉ុន្មានទៀតទេ សម្រេចផែនការយើងហើយ"]។

[193] ឯកសារ **D219/120** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត, ឆ.៣១ ["ប៉ុន្តែពេលខ្លះ គាត់[តាអាន]មកនិយាយពីបញ្ហាជាក់លាក់អំពីឈ្មោះអ្នកដែលគេបានកំណត់អត្តសញ្ញាណចាប់ខ្លួន ដោយមកពិភាក្សាគ្នាជាមួយខ្ញុំ ដើម្បីសម្រេចអំពីជោគវាសនារបស់អ្នកទាំងនោះ"]។

[194] ឯកសារ **D219/226** កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា, ឆ.២៤ ["បន្ទាប់ពីការបោសសម្អាតពួកបូព៌ានៅខែមេសា ឆ្នាំ១៩៧៨ ខ្ញុំបានឃើញ សមមិត្ត ម៉យ ដែលជាដៃស្តាំរបស់តាអាន អ្នកទទួលខុសត្រូវខាងចាប់ចង ជិះម៉ូតូនៅពីមុខឡានពីរគ្រឿង ដែលឡានទី១គឺ ឡានហ្ស៊ីពអាឌី ដែលតាអាន ជិះនៅក្នុងនោះ និងឡានទី២ គឺឡានកាត់ៗចិន ដែលមានអ្នកទោសភូមិភាគបូព៌ាប្រហែល ២០នាក់ នៅក្នុងនោះ"]។ ឯកសារ **D219/498** កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា, ឆ.១៤-១៦ ["ខ្ញុំចាំថា ពេលខ្ញុំដើរទៅហូបបបរនៅភូមិពង្រ ខ្ញុំឃើញ ឈ្មោះ ម៉យ ជិះម៉ូតូពីមុខ ឡានហ្ស៊ីពរបស់តាអាន គឺឡានហ្ស៊ីព អា-២ និងឡានមួយទៀតគឺ ឡានកាត់ចិន (៤x៤) ដឹកអ្នកទោសដែលជាកម្មាភិបាលបូព៌ា។ ប្រហែលជាមានម៉ូតូ មួយគ្រឿងទៀត នៅពីក្រោយឡានកាត់កាត់ចិននោះ។ កាលនោះ ផ្លូវនោះពុំមានក្រាលកៅស៊ូ ដូចឥឡូវទេ វាជាផ្លូវដីធម្មតា។ ខ្ញុំបានឃើញអ្នកទោសនៅក្នុងឡានកាត់កាត់ចិននោះតិចជាង ២០នាក់ ហើយពួកគេគឺជា កម្មាភិបាលស្លិតក្នុងឯកសណ្ឋានពណ៌ខ្មៅថ្មីៗ ហើយដៃរបស់ពួកគេជាប់ចំណង។ [...] ស៖ តើ តាអាន ជិះឡានហ្ស៊ីព ជាមួយអ្នកណា? ឆ.១៥៖ មានអ្នកបើកឡានម្នាក់ និងអង្គរក្សមួយចំនួនជិះឡាន ហ្ស៊ីពអា-២ ជាមួយតាអាន។ នៅពីក្រោយឡានហ្ស៊ីពរបស់តាអានមានឡានកាត់កាត់ចិនដែលដឹកអ្នកទោសតិចជាង ២០នាក់ ដែលអ្នកទោសទាំងនោះ គឺជាកម្មាភិបាលភូមិភាគបូព៌ា។ ស៖ ចុះលោកមានចំណាំអ្នកទោសទាំងនោះទេ? ឆ.១៦៖ អត់ទេ គ្រាន់តែដឹងថា ជាកម្មាភិបាលបូព៌ា ហើយប្អូនថ្លៃប្រុសខ្ញុំបានឃើញគេសម្លាប់ កម្មាភិបាលបូព៌ា។ ប្អូនថ្លៃរបស់ខ្ញុំគឺប្តីរបស់ ពេញ ចន្ថា។ គាត់បានឃើញគេបណ្តើរកម្មាភិបាលបូព៌ាទាំងនោះ ជាជួរយកទៅសម្លាប់នៅវត្តរកាគយ ក្នុងស្រុកកងមាស"]។

72. ជាមួយនឹងភ័ស្តុតាងស៊ីសង្វាក់គ្នាដ៏ច្រើនសន្ធឹកសន្ធាប់នេះ ការសន្និដ្ឋានរបស់ដីកាលើកលែងការចោទប្រកាន់ថា មានភ័ស្តុតាងតិចតួចប៉ុណ្ណោះអំពី អោ អាន ក្នុងការបញ្ជាឱ្យសម្លាប់មនុស្ស គឺពិតជាមិនសមហេតុផលទេ។

## ២. មានភស្តុតាងរឹងមាំដែលថា អោ អាន បានទៅដល់ភូមិភាគកណ្តាល នៅដើមឆ្នាំ១៩៧៧ និង បានធ្វើជាលេខាតំបន់៤១ អស់រយៈពេលជិតពីរឆ្នាំ

73. ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញដោយខុសឆ្គងថា អោ អាន ត្រូវបានបញ្ជូនទៅកាន់ភូមិភាគកណ្តាលនៅពាក់កណ្តាលឆ្នាំ១៩៧៧ នៅពេល "ការបោសសម្អាតក្នុងភូមិភាគកណ្តាល [...] ស្ទើរតែចប់ទាំងស្រុងរួចរាល់ហើយ"[195]។ ដីកាក៏បានរកឃើញផងដែរថា អោ អាន បានបម្រើការងារជាលេខាតំបន់៤១ "ប្រមាណជាងមួយឆ្នាំ"[196]។ ការរកឃើញទាំងនេះបាននាំឱ្យមានសេចក្តីសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា អោ អាន បានបម្រើជាលេខា "ក្នុងរយៈពេលខ្លី" ដូច្នេះ មិននៅក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនានានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ[197]។

74. ដីកាសម្រេចលើកលែងចោទប្រកាន់ប្រហែលជាធ្វើការសន្និដ្ឋាននេះទាក់ទងនឹងពេលវេលានៃការមកដល់របស់ អោ អាន ដោយផ្អែកជាចម្បងនៅលើផ្នែកដែលមិនពេញលេញមួយនៃ "ប្រវត្តិរូប" ដែលឃើញមាននៅក្នុងទស្សនាវដ្តីរបស់ DC-Cam លេខប្រចាំខែមីនា ឆ្នាំ២០០២ ទស្សនាវដ្តី *ស្វែងរកការពិត* ដែលនៅក្នុងនោះ កែ ពក បាននិយាយថា៖

> ដល់ខែ ៦/៧៧ ចប់ការចាប់ ១វគ្គដំបូងហើយ។ ពេលនោះ នៅសល់តែខ្ញុំ។ ពេលនោះធ្វើការពិនិត្យនៅភូមិភាគកណ្តាល អស់ ក/ប។ ខាងលើក៏សំរេចយក ក/ប ពិនិរតីមកដាក់។ ខាងលើហៅ ក/ប ពីនិរតីមក២០០នាក់ជាង មាន កង ចាប ជាបុគ្គលទី១ធ្វើការនៅពហុកីឡាដ្ឋាន។ ពេលនោះ ខាងលើ ច/ត សរុប +តំបន់៣៥ ភូមិភាគ

---

[195] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៤៩៤, ៥០៨។

[196] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៥១០។

[197] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៥៥៣-៥៥៤។

កណ្តាលទៅជាភូមិភាគឧត្តរថ្មី មានខ្ញុំជាលេខា - កង ចាប អនុលេខា - តាអាន ជាសមាជិក[198]។

75. ដូចដែលបានឃើញ កែ ពក មិនបាននិយាយដោយមានន័យច្បាស់លាស់ទេថា អោ អាន បានមកដល់ភូមិភាគកណ្តាលនៅពេលណា។ ផ្ទុយទៅវិញ គាត់គ្រាន់តែបាននិយាយថា ការចាប់ខ្លួនកម្មាភិបាលភូមិភាគកណ្តាលមួយវគ្គដំបូងបានចប់សព្វគ្រប់នៅខែមិថុនា ឆ្នាំ១៩៧៧ ហើយថា អាជ្ញាធរមជ្ឈិមបក្សបានបំពេញកន្លែងទំនេរដោយដាក់កម្មាភិបាលមកពីភូមិភាគនិរតី។ ដីកាសម្រេចលើកលែងចោទប្រកាន់សន្និដ្ឋានថា កែ ពក ចង់មានន័យថា មិនមានកម្មាភិបាលនិរតីណាបានមកដល់ទេ រហូតដល់ក្រោយការចាប់ខ្លួន "លើកដំបូង" ត្រូវបានចប់ ក៏ប៉ុន្តែកថាខណ្ឌនេះមានន័យមិនច្បាស់លាស់ និងអាចយល់បាននោះទេ ដោយសារតែការលើកឡើងថា កន្លែងទំនេរត្រូវបានបំពេញនៅក្នុងអំឡុងពេលបោសសម្អាត មិនថា នៅក្រោយពេលចាប់ខ្លួនកម្មាភិបាលចុងក្រោយត្រូវបានចប់សព្វគ្រប់ប៉ុណ្ណោះ។ នៅក្នុងស្វ័យជីវប្រវត្តិរបស់គាត់ កែ ពក បានព្យាយាមធ្វើយុត្តិកម្មសកម្មភាពរបស់គាត់ផ្ទាល់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយការលើកទៅកាលបរិច្ឆេទមួយនៃការមកដល់របស់កម្មាភិបាលមកពីភូមិភាគនិរតី មិនមែនជាចំណុចសំខាន់នៅក្នុងការរៀបរាប់នោះទេ។

76. បន្ទាប់មក ដីកាសម្រេចលើកលែងចោទប្រកាន់ព្យាយាមគាំទ្រដល់ការអះអាងដែលថា កម្មាភិបាលនិរតីបានមកដល់ភូមិភាគកណ្តាលនៅខែមិថុនា ឆ្នាំ១៩៧៧ ដោយបានលើកឡើងថា ភស្តុតាងរបស់ កែ ពក ត្រូវគ្នាទៅនឹងសេចក្តីថ្លែងរបស់សាក្សីជាច្រើន[199]។ យ៉ាងណាក៏ដោយ សេចក្តីថ្លែងជាច្រើនដែលត្រូវបានដកស្រង់ដើម្បីគាំទ្រ មិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ពីខែណា នៅក្នុង ឆ្នាំ១៩៧៧ ពេលដែលកម្មាភិបាលបានមកដល់[200] មិនបានគាំទ្រដល់ការអះអាងថានៅពាក់ កណ្តាល

[198] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៤៩៥។ ឯកសារ **D1.3.16.1** ប្រវត្តិរូបរបស់ កែ ពក ពីឆ្នាំ ១៩៤៩-១៩៨៥, EN 00089713-14។ សូមកត់សម្គាល់ថា ការបកប្រែជាភាសាអង់គ្លេសនៅក្នុងសំណុំរឿង ខុសគ្នាបន្តិចបន្តួចពីសំណៅជាភាសាអង់គ្លេសផ្លូវការ ដែលអាចរកបាននៅតាម http://www.d.dccam.org/Projects/ Magazines/Previous %20Englis/Issue27.pdf។

[199] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២០២, ២០៣, កំណត់សម្គាល់ជើងទំព័រលេខ ៥៧៦, ៥៧៧។

[200] ឯកសារ **D117/34** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ នី, ឆ.១ [ក្នុងឆ្នាំ១៩៧៧ ពេជ្រ ជឹម បានឲ្យខ្ញុំទៅភូមិភាគ កណ្តាលជាមួយគាត់។ ក្នុងពេលធ្វើដំណើរទៅភូមិភាគកណ្តាល យើងបានធ្វើដំណើរជាមួយមនុស្សជាច្រើនតាមក្បួនរថយន្ត]។ ឯកសារ

ឆ្នាំ១៩៧៧[201] ឬចេញមកពីសាក្សីនានាដែលបានថ្លែងថា ពួកគាត់ចាំមិនបានច្បាស់លាស់ទេថា ពេលណាកម្មាភិបាលទាំងនោះបានមកដល់នោះ ដោយពួកគេគ្រាន់តែស្មានពីពេលវេលានោះតែប៉ុណ្ណោះ[202]។

**D6.1.690** កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម, ឆ.៩ [សាក្សីទៅធ្វើជាប្រធានចម្ការកៅស៊ូចម្ការអណ្តូង នៅកំពង់ចាម នៅឆ្នាំ១៩៧៧។ គាត់បានយកមនុស្ស ៤០នាក់ ដែលមកពីនិរតីទៅជាមួយគាត់] (*ប៉ុន្តែសូមអាន* ភស្តុតាងដែលបានលើកឡើងនៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ ២០៤ ខាងក្រោមនេះដែលគាត់បានរំលឹកយ៉ាងទៀងទាត់ថា គាត់បានចាកចេញទៅភូមិភាគកណ្តាលនៅ ខែកុម្ភៈ ឆ្នាំ១៩៧៧)។ ឯកសារ **D117/27** កំណត់ហេតុស្តាប់ចម្លើយ ឌី រ៉ូន, ឆ.១ [“ខ្ញុំធ្វើការនៅផ្នែកកាត់ដេរដល់ឆ្នាំ១៩៧៧ នៅពេលដែល ប្រាក់ យុត ត្រូវបានផ្ទេរទៅធ្វើការនៅភូមិភាគកណ្តាល។ គាត់ក៏យកខ្ញុំទៅជាមួយដែរ។ ខ្ញុំមិនអាចចាំបានច្បាស់ទេ តែកាលនោះគឺនៅក្នុងឆ្នាំ១៩៧៧”]។ ឯកសារ **D117/50** កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម ប៊ុន, ឆ.៥-៧ [សាក្សីរូបនេះត្រូវបានបញ្ជូនទៅតំបន់៤១ នៅរដូវប្រាំង ឆ្នាំ១៩៧៧]។ ឯកសារ **D191.2** បទសម្ភាសន៍ អោ អាន របស់ DC-Cam, EN 01025311, 20 [បានទៅកំពង់ចាម នៅរដូវប្រាំង ឆ្នាំ១៩៧៧]។

[201] ឯកសារ **D117/42** កំណត់ហេតុស្តាប់ចម្លើយ ខឹម នារី, ឆ.៤ [“ខ្ញុំចាំថា ពួកនិរតីមកដល់ក្នុងឆ្នាំ១៩៧៧ ក្រោយពេលដែលមានដំណឹងថា គេចាប់ សោ ភឹម [...]”] (*សូមកត់សម្គាល់ថា* សោ ភឹម មិនត្រូវបានចាប់ខ្លួននោះទេ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៨។ *សូមអាន ឧទាហរណ៍* សំណុំរឿងលេខ ០០២-**E313** សាលក្រមលើសំណុំរឿងលេខ០០២/០១, កំណត់សម្គាល់ជើងទំព័រលេខ ៦៩៣)។ ឯកសារ **D6.1.423** កំណត់ហេតុស្តាប់ចម្លើយ ហេង នា, EN 00275915-16 [ពិភាក្សាអំពីមនុស្សនៅភូមិភាគនិរតី មកភូមិកំណើតរបស់គាត់នៅស្វាយរៀង, មិនមែននៅភូមិភាគកណ្តាលទេ, នៅពាក់កណ្តាលឆ្នាំ១៩៧៧]។ ឯកសារ **D78** កំណត់ហេតុស្តាប់ចម្លើយ ជីន ស៊ីណាល់, ឆ.៩ [អាន បានមកមើលកងចល័តរបស់សាក្សីរូបនេះនៅរដូវប្រាំង ឆ្នាំ១៩៧៨ ប៉ុន្តែសាក្សីរូបនេះមិនបានដឹងទេថា អាន ធ្វើគណៈតំបន់នោះតាំងពីពេលណាទេ]។

[202] ឯកសារ **D219/232** កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ឈុនសេង, ឆ.៥ [“សៈ តើលោកចាំទេថា តើកម្មាភិបាលមកពីភូមិភាគនិរតីមកជំនួសកម្មាភិបាលនៅភូមិឃុំស្រុកនេះ នៅឆ្នាំណាដែរ? ឆ.៥៖ ខ្ញុំអត់ចាំថាតើពេលណាកម្មាភិបាលភូមិភាគនិរតីមកទេ។ តែខ្ញុំចាំថាចាប់ពីឆ្នាំ១៩៧៧ ដល់ ឆ្នាំ១៩៧៩ កម្មាភិបាលភូមិភាគនិរតីបានមកជំនួសកម្មាភិបាលមូលដ្ឋាននៅថ្នាក់ឃុំ និងថ្នាក់ស្រុកទាំងអស់”]។ ឯកសារ **D219/26** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ នី, ឆ.១០ [“ខ្ញុំមិនចាំច្បាស់ថា ឆ្នាំណាទេ តែខ្ញុំគិតថាខ្ញុំទៅទីនោះក្នុងឆ្នាំ១៩៧៧”] (*បានលើកឡើងពីរដងនៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ ៥៧៦*)។ ឯកសារ **D6.1.733** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត, EN 00364075 [“ក្រោយមកតាអាន ក៏ត្រូវបានផ្លាស់មកភូមិភាគកណ្តាលដែរ ប្រហែលខែ៥ ឬខែ៦ ឆ្នាំ១៩៧៧ តែខ្ញុំមិនដឹងថាគាត់មកភូមិភាគកណ្តាលមុនខ្ញុំឬក្រោយខ្ញុំទេ”]។ ឯកសារ **D219/138** កំណត់ហេតុស្តាប់ចម្លើយ យូ វ៉ាន់, ឆ.៤៣ [“ខ្ញុំមិនចាំពេលវេលាជាក់លាក់ដែលពួកយើងមកដល់ទេ។ [...] ខ្ញុំប៉ាន់ស្មានថា បានមកនៅ និងធ្វើការក្នុងភូមិភាគកណ្តាលប្រហែល១ឆ្នាំមុនវៀតណាមចូលមកដល់”]។ ឯកសារ **D29** កំណត់ហេតុស្តាប់ចម្លើយ សួន កានិល *ហៅ* នាង, EN 00716227 [“ពួកគាត់ [ពួកតាអាន] ពេលនោះទើបតែមកពីតំបន់និរតី ប៉ុន្តែខ្ញុំមិនចាំច្បាស់ពីពេលវេលាទេ។ វាអាចនៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨”]។ ឯកសារ **D219/249** កំណត់ហេតុស្តាប់ចម្លើយ សួន កានិល *ហៅ* នាង, ឆ.១ [“ខ្ញុំមិនច្បាស់ទេ តែតាមខ្ញុំនៅចាំ កម្មាភិបាលភូមិភាគនិរតីបានទៅដល់ភូមិភាគកណ្តាលនៅម្តុំចុងឆ្នាំ១៩៧៧”]។ ឯកសារ **D219/870** កំណត់ហេតុស្តាប់ចម្លើយ រី ញ៉, ឆ.៦ [“បើឆ្នាំខ្ញុំអត់ចាំទេ បើសកម្មភាពខ្ញុំចាំ ពួកហ្នឹង [កម្មាភិបាលភូមិភាគនិរតី] មកប្រហែលចុង៧៧ ដើមឆ្នាំ៧៨”]។ ឯកសារ **D219/461** កំណត់ហេតុស្តាប់ចម្លើយ ប៉ែន ចុល, ឆ.១១ [ពួកកម្មាភិបាលភូមិភាគនិរតីបានមកជំនួសពួក

77. ផ្ទុយមកវិញ សេចក្តីថ្លែងដែលត្រូវបានដកស្រង់នោះភាគច្រើនគាំទ្រដល់ការសន្និដ្ឋានដែលថា កម្មាភិបាលនិរតី រួមទាំង អោ អាន ផង បានមកដល់ភូមិភាគកណ្តាលនៅឆ្នាំ១៩៧៦ ឬ ដើមឆ្នាំ១៩៧៧[203]។ គួរឲ្យកត់សម្គាល់បំផុតក្នុងចំណោមទាំងនេះនោះគឺសេចក្តីថ្លែងរបស់កម្មាភិបាល

---

អតីតកម្មាភិបាលនៅ "ប្រហែល" ជាពាក់កណ្តាលឆ្នាំ១៩៧៧]។ ករណីលើកលែងតែមួយ គឺឯកសារ **D117/43** កំណត់ហេតុស្តាប់ចម្លើយ ស្បោង យ៉ាន់, ឆ.៤ ["ពួកនិរតីមកជំនួសកម្មាភិបាលចាស់ៗ នៅក្នុងឆ្នាំ១៩៧៧ ប្រហែលខែ៥"]។

[203] ឯកសារ **D76** កំណត់ហេតុស្តាប់ចម្លើយ សេង ស្រ៊ុន, ឆ.៦ [អាន មកជំនួស ស្រេង នៅក្នុងខែកក្កដា ឬខែសីហា ឆ្នាំ១៩៧៦ នៅពេលដែល "ពួកកម្មាភិបាលនិរតី" បានមកដល់]។ ឯកសារ **D36** កំណត់ហេតុស្តាប់ចម្លើយ ជា ម៉ាលី, EN 00722231 [អាន បានកាន់កាប់តំបន់នៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧]។ ឯកសារ **D74** កំណត់ហេតុស្តាប់ចម្លើយ រ័ត្ន ពៅ, ឆ.២-៣ [ពួកនិរតីបានមកដល់ "ប្រហែលនៅចុងឆ្នាំ១៩៧៦ ដើមឆ្នាំ១៩៧៧" និងបានដកអ្នកភូមិភាគកណ្តាល]។ ឯកសារ **D117/31** កំណត់ហេតុស្តាប់ចម្លើយ យូ វ៉ាន់, ឆ.៤-៨ [មានមនុស្សប្រហែល ២០០នាក់ រួមទាំងសាក្សីរូបនេះ និង អោ អាន ផង ត្រូវបានបញ្ជូនទៅភូមិភាគកណ្តាលនៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧] (*បានលើកឡើងពីរដងនៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ ៥៧៦*)។ ឯកសារ **D117/32** កំណត់ហេតុស្តាប់ចម្លើយ ញឹម កុល *ហៅ* សាយ, ឆ.២ [ពួកកម្មាភិបាលនិរតីបានទៅដល់ស្រុកកំពង់សៀមនៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧] (*បានលើកឡើងពីរដងនៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ ៥៧៦*)។ ឯកសារ **D6.1.399** កំណត់ហេតុស្តាប់ចម្លើយ សេង ស្រ៊ុន, EN 00235515 [ពួកនិរតីមកកាន់កាប់ភូមិពាមជីកង (ស្រុកកងមាស) នៅពាក់កណ្តាលឆ្នាំ១៩៧៦]។ ឯកសារ **D219/606** កំណត់ហេតុស្តាប់ចម្លើយ ជា ខេងថៃ, ឆ.១៤ [ពួកនិរតីមកដល់ព្រៃទទឹងក្នុងឆ្នាំ១៩៧៦], ឆ.៣៥ [អាន មកធ្វើការនៅតំបន់៤១ ប្រហែលឆ្នាំ ១៩៧៦ មើលទៅ]។ ឯកសារ **D219/82** កំណត់ហេតុស្តាប់ចម្លើយ រៀល នាង, ឆ.៨, ១៣ [ពួកនិរតីមកដល់ឃុំអង្គរបាន ស្រុកកងមាស នៅចុងឆ្នាំ១៩៧៦ និងមកបន្ថែមទៀតនៅឆ្នាំ១៩៧៧]។ ឯកសារ **D219/712** កំណត់ហេតុស្តាប់ចម្លើយ សុក ប៊ាន់, [គណៈស្រុកកំពង់សៀមត្រូវបានដកចេញនៅឆ្នាំ១៩៧៥ ឬឆ្នាំ១៩៧៦ ហើយត្រូវបានជំនួសក្នុងឆ្នាំ១៩៧៦ ឬឆ្នាំ១៩៧៧ ដោយ យាយយុត និង តាស៊ុំ មកពីនិរតី]។ ឯកសារ **D118/259** កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម, ឆ.៣២ [សាក្សីរូបនេះត្រូវបានផ្លាស់ពីស្រុកត្រាំកក់ ទៅកំពង់ចាម នៅចុងឆ្នាំ១៩៧៦], ឆ.៤៩។ ឯកសារ **D107/7** កំណត់ហេតុស្តាប់ចម្លើយ ញឹម កុល *ហៅ* សាយ, EN 00787213 [យាយយុត បានទៅដល់ស្រុកកំពង់សៀមនៅរដូវប្រាំង ក្នុងខែមករា ឬ ខែកុម្ភៈ ឆ្នាំ១៩៧៧។ គាត់បានទៅក្នុងដំណាក់កាលទីពីរ នៅពេលដែលពួកគ្រប់គ្រងត្រូវបានផ្លាស់ឲ្យទៅគ្រប់គ្រងភាគ តំបន់ ស្រុក និង ឃុំ]។ ឯកសារ **D117/70** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត, ឆ.៦ ["ខ្ញុំត្រូវបានបញ្ជូនទៅភូមិភាគកណ្តាល ពីខេត្តកំពត ក្នុងខែមករា ឆ្នាំ១៩៧៧"] *ក៏ប៉ុន្តែសូមអាន* ឯកសារ **D6.1.730** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត, EN 00364081 ["ប្រហែលខែ៣ ឬ ខែ៤ ឆ្នាំ១៩៧៧ គេបានផ្លាស់ខ្ញុំចេញពីតំបន់៣៥ ទៅស្រុកកំពង់សៀម"]។ ឯកសារ **D219/405** កំណត់ហេតុស្តាប់ចម្លើយ ឈឹម ប៊ុនសេរី, ឆ.១៣ ["ពួកនិរតីចូលមកប្រហែលជានៅដើមឆ្នាំ១៩៧៧"], ឆ.២៩-៣០ [អោ អាន បាននិយាយប្រាប់ពួកកម្មករនៅពេលបើកការដ្ឋានទំនប់តំបន់ នៅដើមឆ្នាំ១៩៧៧]។ ឯកសារ **D219/731** កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ចេន, ឆ.១២ [អោ អាន បានមកដល់ "ប្រហែល ដើមឆ្នាំ ខែពីរ ខែបី ឆ្នាំ៧៧"]។ ឯកសារ **D219/171** កំណត់ហេតុស្តាប់ចម្លើយ ញឹម កុល *ហៅ* សាយ, ឆ.២ ["នៅពេលដែលកម្មាភិបាលនិរតីមកដល់ស្រុកកំពង់សៀម នៅក្នុងរដូវប្រាំង ចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧"]។ ឯកសារ **D219/284** កំណត់ហេតុស្តាប់ចម្លើយ ពៅ សារ៉ុម, ឆ.២៥-៣០ [ប្រាក់ យុត ត្រូវបានផ្លាស់ទៅកំពង់សៀម នៅខែមីនា ឬខែមេសា ឆ្នាំ១៩៧៧ ហើយត្រឡប់មកវិញ មក

ដែលធ្លាប់បានធ្វើដំណើរជាមួយនឹង អោ អាន នៅពេលដែលពួកគាត់ត្រូវបាន ផ្លាស់មកពីភូមិភាគនិរតី ឬធ្លាប់បានធ្វើការជាមួយនឹងគាត់នៅពេលដែលគាត់បានមកដល់។ ជាឧទាហរណ៍៖

ក. <u>ពេជ្រ ជឹម</u>៖ អតីតលេខាស្រុកត្រាំកក់។ ពេជ្រ ជឹម នៅចងចាំថាគាត់បានធ្វើដំណើរទៅកាន់ភូមិភាគកណ្ដាលជាមួយនឹង អោ អាន។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយចំនួនប្រាំដែលបានផ្ដល់ឲ្យនៅក្នុងរយៈពេលប្រមាណជាប្រាំមួយឆ្នាំ ពេជ្រ ជឹម បានកំណត់ពេលយ៉ាងទៀងទាត់នៃការផ្លាស់ពីភូមិភាគនិរតី ទៅភូមិភាគកណ្ដាល ថានៅខែកុម្ភៈ ឆ្នាំ ១៩៧៧។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយចំនួនពីរ គាត់បានកំណត់ពីថ្ងៃនៃការធ្វើដំណើរថានៅថ្ងៃទី១២ ទៅ ទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៧[204]។

---

យកប្អូនជីដូនមួយ (សាក្សីរូបនេះ) នៅខែកក្កដា]។ ឯកសារ **D117/56** កំណត់ហេតុស្ដាប់ចម្លើយ ជុំ វង្ស, ឆ.១៤ ["តាមខ្ញុំចាំតាអានចេញទៅកំពង់ចាម នៅម្ដុំខែមេសា ឬឧសភា ក្នុងឆ្នាំ១៩៧៧"]។

[204] ឯកសារ **D118/79** កំណត់ហេតុស្ដាប់ចម្លើយ ពេជ្រ ជឹម, ឆ.១ ["ខ្ញុំចេញមកភូមិភាគកណ្ដាលក្នុងខែកុម្ភៈ ឆ្នាំ ១៩៧៧"]។ ឯកសារ **D6.1.650** កំណត់ហេតុស្ដាប់ចម្លើយ ពេជ្រ ជឹម, EN 00379171 ["ប្រហែលជាខែ២ ឆ្នាំ១៩៧៧ គេដកខ្ញុំមកធ្វើជាប្រធានសហជីព [មុខតំណែងថ្មី] ចំការកៅស៊ូ នៅចំការអណ្ដូង នៃភូមិភាគកណ្ដាល"]។ ឯកសារ **D117/18** កំណត់ហេតុស្ដាប់ចម្លើយ ពេជ្រ ជឹម, ឆ.១ ["ខ្ញុំបានស្គាល់តាអានតាំងពីឆ្នាំ១៩៧៧ នៅពេលដែលគេបញ្ជូនខ្ញុំជាមួយ សែ ប្រាក់យុត តាអាន ផែន និងស៊ឹម ទៅភូមិភាគកណ្ដាល។ [...] នៅខែកុម្ភៈ ឆ្នាំ១៩៧៧ បក្សបានសំរេចបញ្ជូនពួកយើងដំបូងមកភ្នំពេញ គឺពេលនោះហើយដែលយើងបានជួប កែ ពក។ បន្ទាប់មក កែ ពក បាននាំយើងទៅខេត្តកំពង់ចាម ហើយបានរៀបចំអង្គប្រជុំ ធំមួយ"]។ ឯកសារ **D6.1.651** កំណត់ហេតុស្ដាប់ចម្លើយ ពេជ្រ ជឹម, EN 00379304, 06 ["ស៖ តើលោកត្រូវបានគេបញ្ជូនទៅភូមិភាគកណ្ដាលនៅថ្ងៃខែឆ្នាំណា? ឆ.៖ ខ្ញុំត្រូវបានគេផ្លាស់ទៅភូមិភាគកណ្ដាលនាខែ២ ឆ្នាំ១៩៧៧។ ស៖ តើលោកច្បាស់ទេ ថាលោកត្រូវបានផ្លាស់ទៅភូមិភាគកណ្ដាលនៅខែ២ ឆ្នាំ១៩៧៧? ឆ.៖ បាទ ខ្ញុំប្រាកដច្បាស់ហើយ។ [...] ខ្ញុំចាំថា ថ្ងៃ១២ ខែ២ ១៩៧៧ ខ្ញុំបានផ្លាស់ទៅភូមិភាគកណ្ដាល"]។ ឯកសារ **D219/702.1.99** ពេជ្រ ជឹម, ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ម៉ោង៖ 09.26.28-09.31.21 [រៀបរាប់ពីការចាកចេញពីភូមិភាគនិរតីនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៧, ដោយបានចំណាយពេលនៅថ្ងៃទី១៣ នៅភ្នំពេញ និងធ្វើដំណើរទៅកាន់ភូមិភាគកណ្ដាល នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៧ ៖ "**ស៖** [...] ខ្ញុំចង់សួរលោកថាតើមានហេតុផលណាខ្លះដែលលោកចាំថ្ងៃខែច្បាស់បែបនេះ គឺថ្ងៃ១២ ខែកុម្ភៈ? **ឆ៖** ថ្ងៃនោះចាំ ខ្ញុំធ្វើទំនប់ខ្ពបត្របែក អាហ្នឹងចុះមកអង្គតាសោមហើយតាកែវ។ ដល់អង្គតាសោម តាម៉ុក ជិះម៉ូតូមក "ទៅណាវើ ជឹម! ហីទៅតាកែវបន្តិច។ ហ៎ប្រាប់ហ្នឹងឲ្យហើយ" គាត់ថាអ៊ីចឹង។ "ទៅជើង" គាត់របៀបគាត់អ៊ីចឹង។ ជួបណាថាហ្នឹងៗ ថាទៅជើង ប៉ុន្តែបន្តិចទៀត សែ មកចាំជួបគ្នាតាកែវនោះ។ ចាំមួយសន្ទុះឡាន បងសែ មកឡើងជិះ បងសែ ទៅតាកែវនិយាយរឿងដកមកកំពង់ចាម។ ហ្នឹងថ្ងៃ១២ --។ [...] ថ្ងៃ១៣ មកមូលថ្ងៃ ដល់ភ្នំពេញយប់។ នៅ[ថ្ងៃទី]១៤ នៅភ្នំពេញមួយថ្ងៃទៀតបានជួប បងពក មកយក[ទៅកំពង់ចាម]។ ចាំអ៊ីចឹងៗគ្រាន់តែចាំ គឺមានថ្ងៃជាប់ៗគ្នាអ៊ីចឹង។ [ថ្ងៃទី]១២រៀបដំណើរ, [ថ្ងៃទី]១៣ចេញ[ដំណើរ], [ថ្ងៃទី]១៤ដល់ភ្នំពេញ"]។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយមួយបន្តទៀត ពេជ្រ ជឹម កំណត់អត្តសញ្ញាណថា កាលបរិច្ឆេទនៃការផ្លាស់គាត់ទៅកាន់ភូមិភាគកណ្ដាលថា នៅចុងឆ្នាំ១៩៧៦ ឬ នៅខែកុម្ភៈ ឆ្នាំ១៩៧៦៖ ឯកសារ **D118/259** កំណត់ហេតុស្ដាប់ចម្លើយ ពេជ្រ ជឹម, ឆ.៤៩,

ខ. <u>យូ វ៉ាន់</u>៖ យូ វ៉ាន់ ជាកម្មាភិបាលភូមិភាគនិរតី ដែលចងចាំថាគាត់ត្រូវបានផ្លាស់ឲ្យទៅភូមិភាគកណ្តាលនៅពេលជាមួយគ្នានឹង អោ អាន និង ប្រាក់ យុត ដោយបាននិយាយថា កម្មាភិបាលភូមិភាគនិរតីត្រូវបានផ្លាស់ឲ្យទៅភូមិភាគកណ្តាល នៅចុងឆ្នាំ១៩៧៦ ឬ ដើមឆ្នាំ១៩៧៧[205]។

គ. <u>ប្រាក់ យុត</u>៖ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយចំនួនពីរ និងកំណត់ហេតុរបស់ DC-Cam អតីតលេខាស្រុកកំពង់សៀម ប្រាក់ យុត (ដែលបានស្គាល់ អោ អាន ចាប់តាំងពីពេលដែលពួកគាត់បានធ្វើការជាមួយគ្នានៅភូមិភាគនិរតី[206]) បានផ្តល់កាលបរិច្ឆេទនៃ

---

១៦៨-១៧៣។ ថានៅខែកុម្ភៈ ឆ្នាំ១៩៧៦ គឺជាការភាន់ច្រឡំមួយដែលអង្គហេតុបានបង្ហាញថា ពេជ្រ ជឹម និយាយថា យាយចែម ត្រូវបានផ្លាស់ទៅភូមិភាគពាយ័ព្យ នៅពាក់កណ្តាលឆ្នាំ១៩៧៦ កន្លះឆ្នាំមុនពេលដែលគាត់ត្រូវបានផ្លាស់ទៅកំពង់ចាម (សូមអាន ឆ.៤៧-៤៩)។ *សូមកត់សម្គាល់* ថា ដីកាសម្រេចលើកលែងចោទប្រកាន់ ផាត់ចេញនូវការភាន់ច្រឡំ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងមិនបានពិចារណាចម្លើយដែលនៅសល់ខាងទាំងប៉ុន្មាន ឬ ចម្លើយផ្សេងៗទៀតរបស់គាត់ទាំងស្រុង ដែលបានធ្វើឲ្យច្បាស់លាស់ថា កាលបរិច្ឆេទខែកុម្ភៈ ឆ្នាំ១៩៧៦ ត្រូវបានផ្តល់ដោយខុសឆ្គង (*សូមអាន* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២០១)។

[205] ឯកសារ **D117/31** កំណត់ហេតុស្តាប់ចម្លើយ យូ វ៉ាន់, ឆ.៥-៦, ៨ ["ស៖ តើអ្នកស្រីចាំបានថា ការបញ្ជូន[ទៅភូមិភាគកណ្តាល]នោះធ្វើឡើងនៅពេលណា? ឆ.៖ វាកើតឡើងនៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ បន្ទាប់ពីច្រូតកាត់ហើយ។ ស៖ តើមានមនុស្សប៉ុន្មាននាក់ត្រូវបានបញ្ជូននៅពេលតែមួយជាមួយនឹងអ្នកស្រី? ឆ.៖ មានចំនួនប្រហែល២០០នាក់ ដែលត្រូវបានបញ្ជូនទៅភូមិភាគកណ្តាល។ [...] ស៖ តើមេៗទាំងនោះ ជាអ្នកណា? ឆ.៖ តា អាន ធ្វើដំណើរតាមឡានតូចមួយជាមួយមនុស្សរបស់គាត់។ តា ស៊ី និង ប្រាក់ យុត ធ្វើដំណើរតាមឡានតូចម្នាក់មួយ ជាមួយមនុស្សរបស់ពួកគាត់"]។ ឯកសារ **D219/138** កំណត់ហេតុស្តាប់ចម្លើយ យូ វ៉ាន់, ឆ.៣៦ ["មនុស្សប្រមាណ៣០០នាក់ត្រូវបានគេបញ្ជូនពីភូមិភាគនិរតី រួមមានខេត្តកំពត, តាកែវ និង កោះកុង ទៅកាន់ភូមិភាគកណ្តាល។ ពួកយើងបានស្នាក់នៅ១យប់នៅទីក្រុងភ្នំពេញ គឺនៅក្នុងបរិវេណនៃសាកលវិទ្យាល័យមួយដែលខ្ញុំមិនចាំឈ្មោះ។ ប្រាក់ យុត ជាមួយនឹងកម្មាភិបាល១០នាក់ទៀត បានទៅចូលរួមប្រជុំ គឺប្រជុំជាមួយ តាម៉ុក និង ខៀវ សំផន។ ខ្ញុំដឹងដោយសារ តាម៉ុក ជិះឡានមកទទួលអ្នកទាំងនោះទៅប្រជុំ ហើយអ្នកទាំងនោះបានវិលត្រឡប់មកវិញនៅយប់នោះដែរ"]។ ឯកសារ **D219/702.1.87** យូ វ៉ាន់, ប្រតិចារឹក ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦, ម៉ោង៖ 14.02.52-14.05.15 ["ស៖ លោកស្រីមានដឹងថាមានការប្រជុំណាមួយដែរទេ ពេលដែលលោកស្រីមកស្នាក់នៅភ្នំពេញហ្នឹង មិនចាំបាច់ទៅដល់ការប្រជុំដែលលោកស្រីបានចូលរួមទេ គ្រាន់តែឮថាមានប្រជុំដែរឬក៏អត់? ឆ.៖ មាន ប្រាក់ យុត, តាអាន និង តាម៉ុក, តាចាប មានទៅប្រជុំ ខ្ញុំនៅដេកនៅសាលារៀន។ ស៖ លោកស្រីដឹងថា អ្នកទាំង១ប៉ុន្មានអ្នកអម្បាញ់មិញនេះ ជួបជាមួយអ្នកណាដែរ? ឆ.៖ ខ្ញុំដឹងស្មានថា ទៅជួបនឹង ខៀវ សំផន តែម្តង"]។

[206] ឯកសារ **D117/71** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត, ឆ.១-៥, ១០។

ការផ្លាស់ប្ដូរគាត់ពីភូមិភាគនិរតី ទៅភូមិភាគកណ្ដាល ថានៅខែមករា ឆ្នាំ១៩៧៧[207]។ នៅក្នុងសក្ខីកម្មផ្ទាល់របស់គាត់នៅក្នុងសំណុំរឿង០០២/០២ គាត់បានផ្ដល់កាលបរិច្ឆេទថានៅចន្លោះខែកុម្ភៈ និង ខែមេសា ឆ្នាំ១៩៧៧[208]។ មួយរយៈពេលខ្លី បន្ទាប់ពីគាត់បានទៅដល់ភូមិភាគកណ្ដាល ប្រាក់ យុត បានចូលរួមប្រជុំនៅក្នុងកិច្ចប្រជុំចំនួនពីរ ដែលនៅក្នុងនោះ អោ អាន ក៏មានវត្តមានផងដែរ ជាការបញ្ជាក់ថា ពេលវេលានៃការទៅដល់របស់ពួកគាត់គឺកើតឡើងស្ទើរតែដំណាលគ្នា[209]។

ឃ. ញ៉ែម ចេន៖ និរសាររបស់ អោ អាន, ញ៉ែម ចេន, បានថ្លែងថា អោ អាន និង កម្មាភិបាលភូមិភាគនិរតីផ្សេងទៀត បានទៅដល់តំបន់៤១ នៅក្នុងខែកុម្ភៈ ឬ ខែមីនា ឆ្នាំ១៩៧៧[210]។

ង. ញឹម កុល៖ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយចំនួនបី ដែលបានផ្ដល់ឲ្យនៅក្នុងរយៈពេលប្រមាណជាបីឆ្នាំ សមាជិកគណៈឃុំក្រឡា ញឹម កុល បានថ្លែងយ៉ាងទៀងទាត់ថា

[207] ឯកសារ **D117/70** កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ យុត, ឆ.៦ ["ស៖ ពីមុនអ្នកស្រីបានបញ្ជាក់ថា អ្នកស្រីត្រូវបានបញ្ជូនទៅភូមិភាគកណ្ដាលក្នុងឆ្នាំ១៩៧៧ តើអ្នកស្រីចងចាំកាលបរិច្ឆេទច្បាស់លាស់បានទេ? ឆ.៖ ខ្ញុំសូមនិយាយការពិត ខ្ញុំត្រូវបានបញ្ជូនទៅភូមិភាគកណ្ដាល ពីខេត្តកំពត ក្នុងខែមករា ឆ្នាំ១៩៧៧"]។ ឯកសារ **D117/71** កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ យុត, ឆ.១២ ["ស៖ អ្នកស្រីបាននិយាយថាអ្នកស្រីត្រូវបានចាត់តាំងឲ្យទៅកំពង់ចាមនៅខែមករា ឆ្នាំ១៩៧៧ មែនទេ? ឆ.៖ ខ្ញុំចាំថាអ៊ីចឹងមែន"]។ ឯកសារ **D219/234.1.2** កិច្ចសម្ភាសន៍ ប្រាក់ យុត ដោយ DC-Cam, EN 01064270 ["ស៖ ខែប៉ុន្មានដែលអ៊ំផ្លាស់ទៅកំពង់ចាម? ឆ.៖ ខែ១ ឆ្នាំ៧៧"]។

[208] ឯកសារ **D179/1.2.5** ប្រាក់ យុត, ប្រតិចារឹក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២, ម៉ោង៖ 11.23.38-11.25.55 ["ស៖ ដូច្នេះបានន័យថា ថាគេផ្លាស់លោកស្រីទៅកំពង់សៀមហ្នឹងនៅចន្លោះខែកុម្ភៈ និងខែមេសា ឆ្នាំ១៩៧៧ តើត្រឹមត្រូវដែរទេ? ឆ.៖ ចាស ត្រឹមត្រូវហើយ"]។

[209] ឯកសារ **D117/70** កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ យុត, ឆ.១៤-២៦។ ឯកសារ **D117/71** កំណត់ហេតុស្ដាប់ ចម្លើយ ប្រាក់ យុត, ឆ.១៥-១៩។

[210] ឯកសារ **D219/731** កំណត់ហេតុស្ដាប់ចម្លើយ ញ៉ែម ចេន, ឆ.១២ ["ស៖ តាអានមកចុងឆ្នាំ៧៧ឬ? ឆ.៖ ប្រហែល ដើមឆ្នាំ ខែពីរ ខែបី ឆ្នាំ៧៧"]។

កម្មាភិបាលភូមិភាគនិរតី រួមទាំង ប្រាក់ យុត ផង បានទៅដល់ភូមិភាគកណ្តាលនៅចុងឆ្នាំ១៩៧៦ ឬ នៅខែមករា-កុម្ភៈ ឆ្នាំ១៩៧៧[211]។

ច. <u>ពេញ វ៉ា</u>៖ ពេញ វ៉ា ជាសមាជិកនៃអង្គភាពវាយនភណ្ឌតំបន់៤១ បានឃើញ អោ អាន និយាយនៅក្នុងការប្រជុំមួយនៅវត្តតាមះនៅខែមីនា ឆ្នាំ១៩៧៧[212]។ ពេញ វ៉ា ក៏បានថ្លែងផងដែរថា អោ អាន បានទៅដល់ប្រហែលជាមួយសប្តាហ៍ ក្រោយការបាត់ខ្លួនរបស់ តាំង, ដែលជាអ្នកធ្វើការមុន អោ អាន ក្នុងឋានៈជាលេខាតំបន់៤១[213]។ កំណត់ត្រា ស-២១ បង្ហាញថា តាំង បានចូលទៅក្នុងមន្ទីរ ស-២១ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧,[214] ដែលជាការលើកឡើងថា អោ អាន បានទៅដល់ក្នុងមួយរយៈពេលខ្លី ក្រោយកាលបរិច្ឆេទនោះ។ សេចក្តីបញ្ជាក់បន្ថែម ដែលស៊ីគ្នាទៅនឹងការប្រជុំនៅខែមីនា ឆ្នាំ១៩៧៧ គឺការនឹកឃើញរបស់ ពេញ វ៉ា ដែលថា ប្រធានមន្ទីរឧស្សាហកម្មតំបន់ ម៉េង ក៏មានវត្តមាននៅក្នុង

[211] ឯកសារ **D107/7** កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម កុល *ហៅ* សាយ, EN 00787213 ["ស៖ តើយាយយុតនោះជា អ្នកណា? ឆ.៖ យាយយុតគឺជាលេខាស្រុក១០១ដែលជាលេខកូដរបស់ស្រុកកំពង់សៀម។ គាត់មកពីភូមិភាគនិរតី ស្រុកឈូក។ គាត់មកដល់ក្នុងស្រុកនេះនៅក្នុងរដូវប្រាំងឆ្នាំ១៩៧៧ (ខែមករាឬកុម្ភៈ)"]។ ឯកសារ **D117/32** កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម កុល *ហៅ* សាយ, ឆ.២ ["ស៖ តើលោកនៅចាំបានទេ កម្មាភិបាលភូមិភាគនិរតីមកដល់ស្រុកកំពង់សៀមនៅក្នុងថ្ងៃខែឆ្នាំណា? ឆ.៖ បាទ ខ្ញុំចាំបានថាពួកគេបានមកដល់នៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧"]។ ឯកសារ **D219/171** កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម កុល *ហៅ* សាយ, ឆ.២ ["នៅពេលដែលកម្មាភិបាលនិរតីមកដល់ស្រុកកំពង់សៀម នៅក្នុងរដូវប្រាំង ចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧។ ពេលនោះ ខ្ញុំនៅកងចល័តក្នុងឃុំកោះរកា"]។

[212] ឯកសារ **D219/226** កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា, ឆ.៦ ["ខ្ញុំឃើញ តាអាន ដំបូងនៅពេល តាអាន ទៅដល់ក្នុង ខែមីនា ឆ្នាំ១៩៧៧។ គាត់នាមកោះហៅបុគ្គលិកថ្នាក់តំបន់ប្រហែល៣០០នាក់ឲ្យចូលរួមប្រជុំ នៅវត្តតាមះ នៅឃុំជ្រៃវៀន ហើយគាត់ប្រកាសប្រាប់ថា គាត់គឺជាប្រធានតំបន់៤១ថ្មី។ [...] ក្នុងការប្រជុំនោះ គាត់បានប្រកាសថា "ពួកអាមុន វ៉ៃ លន់ នល់ ជិះសេះ លន់ នល់""]។ ឯកសារ **D219/498** កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា, ឆ.៥-៦ ["ខ្ញុំទៅវត្តតាមះ ម្តងនៅពេលតាអានហៅទៅប្រជុំនៅទីនោះ។ [...] ខ្ញុំបានទៅចូលរួមប្រជុំនៅឯវត្តតាមះ ជាមួយមនុស្សដទៃទៀត ប្រហែល ៣០០នាក់"]។

[213] ឯកសារ **D219/226** កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា, ឆ.៤-៦ ["ស៖ តើ តាតាំង ត្រូវបានចាប់ខ្លួន មុន ឬក្រោយការមកដល់របស់ តាអាន? ឆ.៖ តាតាំង បាត់ខ្លួនមុនពេលដែលតាអាន ទៅដល់។ ស៖ តើ តាតាំង បាត់ខ្លួនរយៈពេលយូរប៉ុនណាដែរ ទើប តាអាន មកដល់ស្រុកព្រៃឈរ? ឆ.៖ ប្រហែល១អាទិត្យ។ ពេល អោម អាន មកដល់ គាត់ឡើងធ្វើជាលេខាតំបន់៤១។ [...] ស៖ តើលោកឃើញតាអាន លើកទី១ នៅក្នុងឆ្នាំណាដែរ? ឆ.៖ ខ្ញុំឃើញ តាអាន ដំបូងនៅពេល តាអាន ទៅដល់នៅក្នុងខែមីនា ឆ្នាំ១៩៧៧"]។

[214] ឯកសារ **D219/825.1.2** បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀងទី១០៥៨, EN 01222374 [ជុន ឈុំ *ហៅ* តាំង, លេខាតំបន់៣១ (លេខាតំបន់៤១), ភូមិភាគឧត្តរ, បានចូល ស-២១ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧, បានកំទេចនៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៧៧]។

ការប្រជុំនោះដែរ[215]។ ម៉េង ត្រូវបានចាប់ខ្លួន និងបានចូលទៅក្នុង ស-២១ នៅថ្ងៃទី១៩ ខែឧសភាឆ្នាំ១៩៧៧[216]។ ដូច្នេះ ការប្រជុំនោះមិនអាចកើតមានឡើងនៅក្រោយកាលបរិច្ឆេទនោះបានទេ។

78. ការយោងមិនច្បាស់លាស់តែមួយនៅក្នុងប្រវត្តិរូបរបស់ កែ ពក បានធ្វើឱ្យមានចម្ងល់តិចតួចទៅលើភស្តុតាងលម្អិត និងស៊ីសង្វាក់ ដែលសាក្សីទាំងនេះ និងសាក្សីផ្សេងៗទៀតបានផ្តល់ ដែលបានបង្ហាញថា ការទៅដល់របស់ អោ អាន គឺនៅពេលមុនខ្លាំងនៃខែមិថុនា ឆ្នាំ១៩៧៧។ លើសពីនេះទៀត "ប្រវត្តិរូប" របស់ កែ ពក ត្រូវបានធ្វើឡើងនៅក្នុងកាលៈទេសៈមិនច្បាស់លាស់ និងទំនងជាមិននៅក្រោមទម្រង់សម្បថណាមួយឡើយ ដោយនេះគឺជាកត្តានានាដែលទាក់ទិននៅក្នុងការវាយតម្លៃពីទម្ងន់ទាក់ទងគ្នាដែលបានផ្តល់ឱ្យទៅភស្តុតាង[217]។ ដោយពិចារណាលើភស្តុតាងទាំងអស់ ការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា អោ អាន មិនបានទៅដល់ភូមិភាគកណ្តាលទេ រហូតទល់នឹងខែមិថុនា ឆ្នាំ១៩៧៧ គឺមិនសមហេតុផលទាល់តែសោះ ជាពិសេសដោយគ្មានការពន្យល់ណាមួយថាតើហេតុអ្វីបានជាភស្តុតាងទាំងនេះត្រូវបានប្រើនោះ។

## ៣. ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ភាគច្រើន ឬ ទាំងអស់ ត្រូវបានប្រព្រឹត្តឡើងដោយមានការចូលរួមរបស់ អោ អាន នៅក្នុងអំឡុងពេលដែលគាត់បានធ្វើជាលេខាតំបន់៤១

79. នៅក្នុងការសន្និដ្ឋានដែលថា អោ អាន មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នោះ ដីកាសម្រេចលើកលែងចោទប្រកាន់បានពឹងផ្អែកយ៉ាងខ្លាំងលើអង្គហេតុដែលថា ការចូលរួមរបស់ អោ អាន នៅក្នុងឧក្រិដ្ឋកម្មផ្សេងៗដែលបានកើតឡើងនៅពេលដែល "ការបោសសម្អាតក្នុងភូមិភាគកណ្តាល ស្ទើរតែចប់ទាំងស្រុងរួចរាល់ហើយ"[218]។ ការសន្និដ្ឋាននេះ និង ការពឹងផ្អែករបស់ដីកាសម្រេចលើកលែងចោទប្រកាន់ទៅលើការសន្និដ្ឋាននេះ មានកំហុសមួយចំនួន។

---

[215] ឯកសារ **D219/226** កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា, ឆ.៣៣។ ឯកសារ **D219/498** កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា, ឆ.៦។

[216] ឯកសារ **D219/825.1.2** បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀងទី៤០៨៥, EN 01222486 [ជា ម៉េងថៃ *ហៅ* ម៉េង, ប្រធានឧស្សាហកម្មតំបន់៤១, ភូមិភាគឧត្តរ, បានចូល ស-២១ នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧៧]។

[217] *សូមអាន* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៤៨៥, ៤៨៩។

[218] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៥០៨, ៥៥៣។

80. ទីមួយ ដើម្បីឲ្យមានភាពច្បាស់លាស់ គួរកត់សម្គាល់ថា ដីកាសម្រេចលើកលែងចោទប្រកាន់ហាក់ដូចជាប្រើពាក្យថា "បោសសម្អាត" សម្រាប់គ្រប់ឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ មិនថាជនរងគ្រោះជាកម្មាភិបាល ប.ក.ក ឬជាប្រជាពលរដ្ឋនោះទេ។ ដីកាសម្រេចលើកលែងចោទប្រកាន់នេះដកស្រង់ និងហាក់ដូចជាយកនិយមន័យរបស់ ឌុច ចំពោះពាក្យថា "បោសសម្អាត" ដែលមានន័យថាជា "ដកសមាសភាពខ្មាំងចេញ ពីក្នុងជួរ ពីក្នុងកងទ័ព ពីក្នុងប្រជាជន ដើម្បីឲ្យជួរកងទ័ពឲ្យប្រជាជនស្អាត"[219]។ តាមនិយមន័យនេះ ពាក្យថា "បោសសម្អាត" អនុវត្តចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្ត មិនត្រឹមតែប្រឆាំងនឹងកម្មាភិបាល ប.ក.ក ប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ប្រឆាំងនឹងប្រជាជនទាំងអស់ដែលគេជឿថាជាខ្មាំង មិនថាមកពីសមាជិកភាពនៅក្នុងក្រុមជនសង្ស័យ (ដូចជា ប្រជានចាម និងប្រជាជនថ្មី) ឬដោយសារលក្ខណៈរបស់បុគ្គលនោះទេ។ ការដែលដីកាសម្រេចលើកលែងចោទប្រកាន់នោះប្រើប្រាស់និយមន័យទូលំទូលាយនៃពាក្យថា "បោសសម្អាត" នេះ ត្រូវបានបង្ហាញបន្ថែមទៀតដោយការសន្និដ្ឋានថា "គោលនយោបាយបោសសម្អាតត្រូវបានស្តែងឡើង តាមរយៈ សេចក្តីសម្រេច គណៈកម្មាធិការមជ្ឈិមបក្ស ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលពាក់ព័ន្ធសិទ្ធិសម្រេចកម្ទេច *ក្នុងជួរ និងក្រៅជួរ*"[220]។

81. នៅក្នុងការយល់ពីពាក្យថា "បោសសម្អាត" នេះ ការសន្និដ្ឋាននៃដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា អោ អាន បានចូលរួមនៅក្នុងឧក្រិដ្ឋកម្មតែនៅពេលដែល "ការបោសសម្អាតក្នុងភូមិភាគកណ្តាលស្ទើរតែចប់ទាំងស្រុងរួចរាល់ហើយ" ប៉ុណ្ណោះ ពិតជាមិនសមហេតុផលទេ។ សូម្បីតែចំពោះតារាងពេលវេលានៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ (*ជាអំណះអំណាង* សន្មតថា អោ អាន មិនបានទៅដល់ភូមិភាគកណ្តាលនោះទេ រហូតដល់ ខែមិថុនា ឆ្នាំ១៩៧៧) គាត់នៅតែមានវត្តមាននៅក្នុងភូមិភាគកណ្តាល និងបានចូលរួមនៅក្នុងឧក្រិដ្ឋកម្មនានានៅក្នុងអំឡុងពេលនៃការសម្លាប់យ៉ាងខ្លាំងបំផុត គឺនៅពេលមានការប្តូរការផ្តោតគោលដៅពីកម្មាភិបាល ប.ក.ក ទៅប្រជាពលរដ្ឋធម្មតា ហើយក្រោយមកទៅជនជាតិចាម។ ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ បានថែងយ៉ាងច្បាស់ពីការវិវត្តន៍នៃការបោសសម្អាតចាប់ពីប្រធានភូមិ និងប្រធានឃុំ ទៅប្រជាពលរដ្ឋធម្មតាដែលគេបានមើលឃើញថាជាកាគំរាមកំហែងដល់របបនេះ ទៅអំពើប្រល័យ

---

[219] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៥៦, *លើកឡើងពី* ឯកសារ **D6.1.1052** កំណត់ហេតុសួរចម្លើយ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច EN 00160725។

[220] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៥៩។

ពូជសាសន៍ដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិចាម[221]។ ជាពិសេស ប្រាក់ យុត បានលើកឡើងយ៉ាងច្បាស់ថា "យើងអនុវត្តបញ្ជាសម្លាប់ជនជាតិចាមទាំងអស់នោះ នៅពេលក្រោយដែលចាប់បានសមាសភាពផ្សេងៗរួចហើយ"[222] ហើយបញ្ជាក់ថា ការវាយប្រហារទៅលើជនជាតិចាមបានចាប់ផ្តើមនៅចុងឆ្នាំ១៩៧៧[223]។ ដីកាសម្រេចលើកលែងចោទប្រកាន់ផ្ទាល់បានទទួលស្គាល់ថា មាន "ជនជាតិចាមជាច្រើននាក់" ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខ វត្តអូរត្រកួន នៅក្នុងខែកញ្ញា និងតុលា ឆ្នាំ១៩៧៧[224] ហើយថា "ប្រជាជនចាម រួមទាំងកុមារផង" និងប្រជាជនភូមិភាគបូព៌ាត្រូវបានជាប់ឃុំឃាំង និងសម្លាប់ចោលនៅវត្តបាធាយ ក្នុងឆ្នាំ១៩៧៨[225]។

82. ជាក់ស្តែងជាងនេះទៀត ភស្តុតាងយ៉ាងច្រើនសន្ធឹកសន្ធាប់នៅក្នុងសំណុំរឿងបង្ហាញថា ឧក្រិដ្ឋកម្មនានានៅក្នុងភូមិភាគកណ្តាលត្រូវបានប្រព្រឹត្តឡើង នៅក្រោយពេលដែល អោ អាន បានទៅដល់ ពីព្រោះភស្តុតាងទាំងនេះបានបង្ហាញយ៉ាងច្បាស់ពីមុខងាររបស់ អោ អាន នៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ។ ភស្តុតាងរបស់ ប្រាក់ យុត យូ វ៉ាន់ ពេញ វ៉ា សាត ភាព តូច មាច សូ សារ៉េន ញ៉ែម ចិន ពុត គល់ និងអ្នកផ្សេងៗទៀត មិនបានភ្ជាប់ អោ អាន ទៅនឹងឧក្រិដ្ឋកម្មនានានៅក្នុងភូមិភាគកណ្តាល ដោយផ្អែកលើ *កាលបរិច្ឆេទ* នៃការកើតមានឧក្រិដ្ឋកម្មទាំងនោះ។ កាលបរិច្ឆេទនេះបានភ្ជាប់ អោ អាន ទៅនឹងឧក្រិដ្ឋកម្មនានានៅក្នុងភូមិភាគកណ្តាល ដោយរៀបរាប់ពីវិធីផ្សេងៗដែលគាត់ផ្ទាល់បានចេញបញ្ជា លើកទឹកចិត្ត សម្របសម្រួល បន្តតាមដាន និងចូលរួមនៅក្នុងឧក្រិដ្ឋកម្មទាំងនោះ។ ការញែកកាលបរិច្ឆេទដើម្បីកំណត់ពីការទទួលខុសត្រូវ គឺជាកិច្ចការមួយដែលមិនចាំបាច់ និងគ្មានអត្ថន័យទេ នៅពេលដែលភស្តុតាងបានយោងដោយផ្ទាល់ និងយ៉ាងច្បាស់ទៅសកម្មភាពនានារបស់ អោ អាន។ ភាពមិនច្បាស់លាស់នៃកាលបរិច្ឆេទ មិនធ្វើឱ្យមានភាពមន្ទិលអ្វីលើចំណុចថា ឧទាហរណ៍ ប្រាក់ យុត អាចនឹង ភាន់ច្រឡំនៅក្នុងការ

---

[221] ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១៧-៣៥, ៥៤-៧១។

[222] ឯកសារ **D219/120** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត, ឆ.២១ ["ស៖ តើបញ្ជាទាំងអស់នោះមានពាក់ព័ន្ធនឹងការចាប់ខ្លួនជនជាតិចាមយកទៅសម្លាប់ដែរឬទេ? ឆ.៖ ចាស, ពេលចេញបញ្ជា គឺនៅពេលតែមួយឱ្យកំទេច ក៏ប៉ុន្តែយើងអនុវត្តបញ្ជាសម្លាប់ជនជាតិចាមទាំងអស់នោះនៅពេលក្រោយដែលចាប់បានសមាសភាពផ្សេងៗរួចហើយ"]។

[223] ឯកសារ **D219/702.1.95** ប្រាក់ យុត, ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦, ម៉ោង៖ 09.14.17-09.17.03 ["ខ្ញុំសូមជម្រាបអំពីការបោសសម្អាតចាម។ នៅពាក់កណ្តាល ខ្ញុំចូលទៅ មិនទាន់បានធ្វើទេ នៅពាក់កណ្តាល -- នៅប្រហែលជាចុងឆ្នាំ"]។

[224] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៣០៥-៣០៧, ៣១០។

[225] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៣១៦-៣១៧, ៣២១។

កំណត់ អោ អាន ថាជាលេខាតំបន់៤១ ដែលបានចេញបញ្ជាឲ្យគាត់ព័ទ្ធចាប់ប្រធានភូមិ និងប្រធានឃុំ កំណត់អត្តសញ្ញាណ និងសម្លាប់ខ្មាំង ដែលត្រូវបានសង្ស័យថាបានបង្កប់ខ្លួននៅក្នុងចំណោមប្រជាជនទូទៅ និងសម្លាប់ជនជាតិចាមទាំងអស់នៅក្នុងស្រុករបស់គាត់។ ប្រាក់ យុត បានស្គាល់ អោ អាន យ៉ាងហោចណាស់ តាំងពីឆ្នាំ១៩៧៥។ អោ អាន បានចាត់តាំងឲ្យគាត់កាន់តំណែងជាលេខាស្រុកកំពង់សៀម ហើយឧក្រិដ្ឋកម្ម ទាំងអស់ដែលគាត់បានផ្តល់ភស្តុតាង បានកើតឡើងនៅក្នុងអំឡុងពេលដែលគាត់ធ្វើជាលេខាស្រុកកំពង់សៀម។

83. ផ្ទុយទៅនឹងភស្តុតាងផ្ទាល់ច្បាស់លាស់ពីការចូលរួមរបស់ អោ អាន នៅក្នុងឧក្រិដ្ឋកម្ម ភស្តុតាងដែលដីកាសម្រេចលើកលែងចោទប្រកាន់ពឹងផ្អែកលើដើម្បីសន្និដ្ឋានថា ការសម្លាប់ ភាគច្រើនត្រូវបានបញ្ឈប់នៅពេលដែល អោ អាន និងកម្មាភិបាលភូមិភាគនិរតីផ្សេងៗទៀតបានទៅដល់នោះគ្រាន់តែជាការស្មានដែលមិនមានមូលដ្ឋានប៉ុណ្ណោះ។ ដីកាសម្រេចលើកលែងចោទប្រកាន់អះអាងថា ការចាប់ខ្លួន និងការសម្លាប់នៅភូមិភាគបូព៌ា បានថយចុះ ក្រោយពេលដែល អោ អាន ទៅដល់ដោយឈរ ដោយផ្អែកលើចំណុចថា "សេចក្តីថ្លែងការណ៍របស់ ខៀវ សំផន [...] ទាក់ទិននឹងការលើកលែងទោស (ឈប់សម្លាប់) បានបង្ហាញយ៉ាងច្បាស់អំពីអត្ថិភាពនៃការបោសសម្អាតដែលមានកន្លងមក ហើយក៏អាចនិយាយបានថា អត្រានៃការចាប់ចង ឬ ការសម្លាប់ពិតជាបានចុះថមថយ នាពេល អោ អាន បានទៅដល់ភូមិភាគកណ្តាល"[226]។ ដីកាសម្រេចលើកលែងចោទប្រកាន់មិនមានការដកស្រង់ការលើកឡើងរបស់ ខៀវ សំផន នោះទេ ប៉ុន្តែ ដូចសេចក្តីថ្លែងការណ៍របស់កម្ពុជាប្រជាធិបតេយ្យជាច្រើនដែរ សេចក្តីថ្លែងការណ៍ទាំងនោះមិនដូចនឹងការពិតជាក់ស្តែងទេ។ ដូចបានរៀបរាប់យ៉ាងពិស្តារនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ ហើយសូម្បីតែនៅក្នុងការសន្និដ្ឋាននៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ខ្លួនឯងផ្ទាល់ មានការបង្ហាញច្បាស់ថា ការសម្លាប់មិនថយចុះនោះទេនៅក្នុងអំឡុងពេលនៃការទៅដល់របស់ អោ អាន។ ដោយសារតែភស្តុតាងផ្ទុយគ្នាជាច្រើនសន្ធឹកសន្ធាប់នៅក្នុងសំណុំរឿង ការពឹងផ្អែកលើសេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ដែលថា ការសម្លាប់បានថយចុះនោះ ពិតជាមិនសមហេតុផលទេ។

84. ដីកាសម្រេចលើកលែងចោទការប្រកាន់ក៏បានអះអាងដែរថា ការស្លាប់ទាំងឡាយដែលបានកើតឡើងនៅក្រោយពេលដែល អោ អាន បានទៅដល់ភូមិភាគកណ្តាល គឺបណ្តាលមកពីការខ្វះខាត

[226] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៥០៨។

ម្ហូបអាហារ ឬការថែទាំសុខភាព[227]។ ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានលើកពីភស្តុតាងចំពោះការលើកឡើងនេះទេ និងមិនបានភ្ជាប់ទំនាក់ទំនងជាមួយនឹងភស្តុតាងយ៉ាងច្រើនពាក់ព័ន្ធនឹងកម្មវិធីដ៏ធំនៃការសម្លាប់ដោយចេតនានៅក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ អោ អាន នៅតំបន់៤១ នោះទេ។ ខណៈដែលដែលមិនមានចម្ងល់អ្វីលើចំណុចថា អ្នកខ្លះ នៅក្នុងចំណោមអ្នកដែលបានស្លាប់នៅក្នុងអំឡុងពេលដែល អោ អាន បានត្រួតត្រាតំបន់៤១ បានស្លាប់ដោយសារតែកង្វះម្ហូបអាហារ ឬការថែទាំសុខភាព ការសន្និដ្ឋានថា ចំណុចនេះជាមូលហេតុនៃការស្លាប់នោះ ដែលអាចថាជាមូលហេតុតែមួយគត់ ឬមូលហេតុសំខាន់នៃការស្លាប់នោះ គឺពិតជាការស្មាន និងមិនសមហេតុផល នៅពេលដែលមានភស្តុតាងផ្ទុយពីនេះដ៏ច្រើនសន្ធឹកសន្ធាប់ដែលបង្ហាញឲ្យឃើញពីកម្មវិធីដ៏ធំមួយនៃការសម្លាប់ដោយចេតនានៅក្នុងតំបន់៤១ នៅក្នុងពេល អោ អាន គ្រប់គ្រងតំបន់នេះ។

85. ប្រសិនបើពាក្យថា "បោសម្អាត" ត្រូវបានគេយល់នៅក្នុងន័យចង្អៀតមួយ ដែលសំដៅតែទៅលើពួកកម្មាភិបាល ប.ក.ក នោះ ការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ យ៉ាងហោចណាស់នៅតែមិនត្រឹមត្រូវមួយផ្នែក។ ខណៈដែលមានភស្តុតាងដែលថា នៅមានពួកកម្មាភិបាលមួយចំនួននៅកម្រិតភូមិភាគ តំបន់ និង ស្រុក អាចត្រូវបានចាប់ខ្លួន នៅមុនពេល អោ អាន ប្រាក់ យុត និង យូ វ៉ាន់ ពិតជាបានទៅដល់ភូមិភាគកណ្តាល[228] ហើយប្រាក់ យុតបានលើកឡើងយ៉ាងច្បាស់ថា ការចាប់ខ្លួនកម្មាភិបាលថ្នាក់ក្រោមបានធ្វើឡើងបន្ទាប់ពីគាត់ និង អោ អាន ទៅដល់។ ជាពិសេស គាត់និយាយថា "តាអាន ដឹកនាំការចាប់ខ្លួន និងការជំនួសកម្មាភិបាល" នៃប្រធានឃុំ និងប្រធានភូមិនៅក្នុងស្រុករបស់គាត់[229]។ យូ វ៉ាន់ បានយល់ស្របទៀតថា មានការ

[227] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៥០៩។

[228] *សូមអានឧទាហរណ៍* ឯកសារ **D219/226** កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា, ឆ.៤-៦ ["សៈ តើ តាតាំង ត្រូវបាន ចាប់ខ្លួន មុន ឬក្រោយ ការមកដល់របស់ តាអាន? ឆ.៖ តាតាំង បាត់ខ្លួនមុនពេលដែលតាអាន ទៅដល់។ សៈ តើ តាតាំង បាត់ខ្លួនរយៈពេលយូរប៉ុន្មាន ដែរ ទើប តាអាន មកដល់ស្រុកព្រៃឈរ? ឆ.៖ ប្រហែល១អាទិត្យ។ ពេល អោម អាន មកដល់គាត់ឡើងធ្វើជាលេខាតំបន់៤១។ [...] សៈ តើលោកឃើញតាអាន លើកទី១ នៅក្នុងឆ្នាំណាដែរ? ឆ.៦៖ ខ្ញុំឃើញ តាអាន ដំបូងនៅពេល តាអាន ទៅដល់នៅក្នុងខែមីនា ឆ្នាំ១៩៧៧"]។

[229] ឯកសារ **D117/71** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត, ឆ.៤០ ["ខ្ញុំមិនបានចូលរួមនៅក្នុងការខ្លួនគណៈឃុំចាស់ទាំងនោះទេ។ តាអាន ដឹកនាំការចាប់ខ្លួន និងការជំនួសកម្មាភិបាលមកពីនិរតី។ ការចាប់ខ្លួន និងការជំនួសនោះត្រូវបានធ្វើឡើងដោយថ្នាក់តំបន់"]។ *សូមអានផងដែរ* ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កំណត់សម្គាល់ជើងទំព័រលេខ ៤៩-៥១។

ចូលរួមរបស់អ្នកទាំងពីរ គឺ អោ អាន និង ប្រាក់ យុត នៅក្នុងការបោសសម្អាតពួកប្រធានឃុំ និងប្រធានភូមិ[230]។ សូ សារ៉េន នៅចងចាំបានថា មានការចូលរួមរបស់ ប្រាក់ យុត នៅក្នុងការដកហូតប្រធានឃុំម្នាក់[231]។ ញឹម កុល និយាយថា "ក្រោយពី ប្រាក់ យុត មកដល់ស្រុកកំពង់សៀម" អតីតប្រធានឃុំនោះមិនត្រូវបានឃើញជាថ្មីនៅកន្លែងធ្វើការទេ[232]។

86. សំខាន់ជាងនេះទៀត ប្រសិនបើពាក្យ "បោសសម្អាត" ត្រូវបានគេសំដៅតែទៅលើពួកកម្មាភិបាល ប.ក.ក "អង្គហេតុ" ដែលថា ការបោសសម្អាតត្រូវបានបញ្ចប់ភាគច្រើននៅពេលដែល អោ អាន បានទៅដល់ភូមិភាគកណ្តាល (បើទោះជាថាពិតក្តី) នឹងមិនសំខាន់ខ្លាំងចំពោះការវាយតម្លៃពីភាពធ្ងន់ធ្ងរជារួមនៃឧក្រិដ្ឋកម្មរបស់ អោ អាន ប៉ុណ្ណោះនោះទេ (ដូច្នេះហើយ ចំពោះយុត្តាធិការបុគ្គល)។ ជាការពិតណាស់ថា ជនរងគ្រោះភាគច្រើនរាប់ពាន់នាក់ ឬរាប់ម៉ឺននាក់ នៅតំបន់៤១ ត្រូវបានគេមើលឃើញថាជា "ខ្មាំង" ក្នុងចំណោមប្រជាជនធម្មតា (រួមទាំងជនជាតិចាម) មិនត្រឹមតែជាពួកកម្មាភិបាលជាន់ខ្ពស់ ប.ក.ក ដែលត្រូវបានសង្ស័យថាជាមិនស្មោះត្រង់ទេ ព្រោះថាមិនមានកម្មាភិបាលគ្រប់គ្រាន់សម្រាប់ឲ្យពួកគេបង្កើតទៅជាផ្នែកមួយដ៏សំខាន់នៃក្រុមជនរងគ្រោះដ៏ធំមួយនោះទេ។ បើទោះជា អោ អាន មិនទទួលខុសត្រូវចំពោះការស្លាប់របស់កម្មាភិបាលណាម្នាក់ក៏ដោយ (ជាក់ស្តែង មិនមែនដូច្នេះឡើយ) ក៏គាត់នៅតែស្ថិតក្នុងចំណោម "អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនានានៅក្នុងកម្ពុជាប្រជាធិបតេយ្យដដែល[233]។

---

[230] ឯកសារ **D219/138** កំណត់ហេតុស្តាប់ចម្លើយ យូ វ៉ាន់, ឆ.៤៤-៤៩។ ឯកសារ **D219/702.1.87** យូ វ៉ាន់, ប្រតិចារឹក ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦, ម៉ោង៖ 14.06.37-14.08.41។ ឯកសារ **D219/702.1.94** យូ វ៉ាន់, ប្រតិចារឹក ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨, ម៉ោង៖ 10.00.34-10.02.00។

[231] ឯកសារ **D219/800** កំណត់ហេតុស្តាប់ចម្លើយ សូ សារ៉េន, ឆ.១៣-១៤។

[232] ឯកសារ **D107/7** កំណត់ហេតុស្តាប់ចម្លើយ ញឹម កុល *ហៅ* សាយ, EN 00787216។ ឯកសារ **D219/171** កំណត់ហេតុស្តាប់ចម្លើយ ញឹម កុល *ហៅ* សាយ, ឆ.១៤-១៥។

[233] ជាក់ស្តែង មិនមានការជំទាស់អ្វីទេដែលថា ការទទួលខុសត្រូវរបស់ អោ អាន ត្រូវបានកាត់បន្ថយពីព្រោះថា ជនរងគ្រោះរបស់គាត់មាន "សារៈសំខាន់" តិចជាងពួកកម្មាភិបាល ប.ក.ក។ ខណៈដែលអំណាចរបស់ជនរងគ្រោះដែលមានឋានៈខ្ពស់អាចជាការបង្ហាញពីកម្រិតខ្ពស់នៅក្នុង ប.ក.ក មិនមានមូលដ្ឋានចំពោះអំណះអំណាងដែលថា ជីវិតរបស់កម្មាភិបាល ប.ក.ក មានតម្លៃជាងជីវិតរបស់ប្រជាជនធម្មតា នៅពេលដែលគេវាយតម្លៃពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មសម្រាប់ គោលបំណងនៃការវិភាគលើប្រភេទនៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" នោះទេ។

## ៤. ផ្ទុយគ្នាទៅនឹងអ្វីដែលដីកាសម្រេចលើកលែងចោទប្រកាន់បង្ហាញ ភស្តុតាងបង្ហាញថា កែ ពក និង អោ អាន បានធ្វើសេចក្តីសម្រេចនានា ដោយមានការសហការគ្នា និងជាសមូហភាព

87. ដីកាសម្រេចលើកលែងចោទប្រកាន់ព្យាយាមបង្ហាញថា កែ ពក ក្នុងឋានៈជាមេដឹកនាំម្នាក់ដ៏សកម្ម និងមានអំណាច ដោយសារតែសិទ្ធិអំណាចធ្វើសេចក្តីសម្រេចចិត្តយ៉ាងច្រើន ហើយនឹង អោ អាន ក្នុងឋានៈជាកម្មាភិបាលម្នាក់ដែលមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចចិត្តមួយចំនួន ដែលមានភារកិច្ចចម្បងនៅក្នុងការអនុវត្តគោលនយោបាយដែល កែ ពក និងថ្នាក់លើរបស់គាត់នៅ ភ្នំពេញ បានសម្រេច[234]។ បញ្ហាសំខាន់មិនគ្រាន់តែតែជាបញ្ហាពាក់ព័ន្ធខាងផ្លូវច្បាប់ដែលមានកម្រិតទាក់ទងនឹងយុត្តាធិការបុគ្គលប៉ុណ្ណោះនោះទេ[235] ក៏មានការមិនមានភស្តុតាងដែលដីកាសម្រេច លើកលែងចោទប្រកាន់ពឹងផ្អែកលើផងដែរ។

88. កថាខណ្ឌ ១៥៩ នៃដីកាសម្រេចលើកលែងចោទប្រកាន់លើកឡើងអំពីសិទ្ធិអំណាចរបស់ កែ ពក ដូចតទៅៈ

> សាក្សីឈ្មោះ បាន សៀក អតីតអនុលេខាស្រុកចំការលើ និងជាអតីតលេខាស្រុកក្រូចឆ្មារ បានផ្តល់សក្ខីកម្មថា *"ភូមិភាគគ្រប់គ្រងដោយ កែ ពក ជាលេខា។* ***កែ ពក គឺជាប្រធានគណៈអចិន្ត្រៃយ៍របស់ភូមិភាគ ... តាមដែលខ្ញុំដឹង ការសម្រេចសំខាន់ៗដូចជា ការបោសសម្អាតជាដើម ត្រូវបានសម្រេចដោយគណៈអចិន្ត្រៃយ៍*** *"*[236]។

89. ចម្លើយនេះត្រូវបានដកស្រង់នៅក្នុងផ្នែកមួយនៃដីកាសម្រេចលើកលែងចោទប្រកាន់ ដោយកំណត់ការទទួលខុសត្រូវចម្បងក្នុងការបោសសម្អាតទៅលើគណៈអចិន្ត្រៃយ៍ភូមិភាគកណ្តាល និងអាជ្ញាធរមជ្ឈិម ហើយព្យាយាមកំណត់អត្តសញ្ញាណគណៈអចិន្ត្រៃយ៍ភូមិភាគ ថាមានតែ កែ ពក[237]។ ក៏ប៉ុន្តែ ការដកស្រង់ដែលត្រូវបានពឹងផ្អែកលើត្រូវបានកែប្រែតាមវិធីមួយដែលបានផ្លាស់ប្តូរ

---

[234] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៥៧-១៦២, ៤៩៤-៥២០, ៥៤៣-៥៥១។

[235] *សូមអាន* ផ្នែក IV.ខ, IV.គ, *នៅខាងលើ* ។

[236] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៥៩, *លើកឡើងពី* ឯកសារ **D107/15** កំណត់ហេតុស្តាប់ចម្លើយ បាន សៀក, EN 00841965 (សង្កត់ន័យបន្ថែមនៅក្នុងឯកសារដើម)។

[237] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៥៧-១៦២, ៥២០។

អត្ថន័យរបស់វា។ សម្រង់ទាំងស្រុងដែលបានមកពីកំណត់ហេតុស្តាប់ចម្លើយ របស់ បាន សៀក គឺដូចតទៅ៖

> ភូមិភាគគ្រប់គ្រងដោយ កែ ពក ជាលេខា។ កែ ពក គឺជាប្រធានគណៈអចិន្ត្រៃយ៍របស់ភូមិភាគ *ដែលមានគណៈតំបន់បីនាក់ គឺតាអាន (មកពីភូមិភាគនិរតី លេខាតំបន់៤១) ស៊ីម (មកពីភូមិភាគនិរតី លេខាតំបន់៤៣) អឿន (មនុស្សរបស់ភូមិភាគកណ្តាល លេខាតំបន់ ៤២) និង ប្រធានមន្ទីរភូមិភាគ។* តាមដែលខ្ញុំដឹង ការសម្រេចសំខាន់ៗដូចជាការបោសសម្អាតជាដើម ត្រូវបានសម្រេចដោយគណៈអចិន្ត្រៃយ៍ *នៅក្នុងការប្រជុំសម្ងាត់របស់គេ*[238]។

90. ជារួម ភស្តុតាងរបស់ បាន សៀក គឺថា គណៈអចិន្ត្រៃយ៍ភូមិភាគមានប្រាំនាក់ រួមទាំង អោ អាន ផង ដែលបានជួបគ្នាដើម្បីធ្វើសេចក្តីសម្រេចសំខាន់ៗជាមួយគ្នាពាក់ព័ន្ធនឹងការបោសសម្អាតនេះ។ ទោះបីជាវាអាចថាសមហេតុផលក្នុងការកំណត់ឋានៈខ្ពស់ និងសិទ្ធិអំណាចខ្ពស់ទៅ កែ ពក ផ្អែកលើមុខតំណែងខ្ពស់របស់គាត់ក៏ដោយ ក៏គ្មានការពិនិត្យត្រឹមត្រូវទៅលើភស្តុតាងនេះ ដែលមិនបានផ្តល់ អោ អាន នូវតួនាទីដ៏សំខាន់មួយនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចនេះដែរ។ នៅក្នុងកថាខណ្ឌនេះ ច្បាស់លាស់ថា បាន សៀក កំពុងពិភាក្សាពី កែ ពក និងគណៈអចិន្ត្រៃយ៍ភូមិភាគជាអង្គភាពដាច់ដោយឡែកពីគ្នា ដោយសារ កែ ពក មិនចាំបាច់ត្រូវការជួបជាមួយនរណាជាសម្ងាត់ដើម្បីធ្វើសេចក្តីសម្រេចទេ។ ការពឹងផ្អែករបស់ដីកាសម្រេចលើកលែងចោទប្រកាន់ទៅលើភស្តុតាងនេះដើម្បីដាក់ការទទួលខុសត្រូវរួមចំពោះការបោសសម្អាតនេះទៅលើ កែ ពក គឺពិតជាការមិនសមហេតុផលទេ។

91. បន្ទាប់មក ដីកាសម្រេចលើកលែងចោទប្រកាន់លើកឡើងពីសេចក្តីសម្រេចរបស់គណៈ អចិន្ត្រៃយ៍ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ទាក់ទងនឹងសិទ្ធិកម្ទេចក្នុងជួរ និងក្រៅជួរ[239]។ នៅក្នុងការលើកឡើងនេះ ដីកាសម្រេចលើកលែងចោទប្រកាន់បានសង្កត់ធ្ងន់ថា ការបោសសម្អាតនោះ

---

[238] ឯកសារ **D107/15** កំណត់ហេតុស្តាប់ចម្លើយ បាន សៀក, EN 00841965 (សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*)។

[239] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៥៩-១៦០។

"ត្រូវបានសម្រេចដោយគណៈអចិន្ត្រៃយ៍ភូមិភាគ"[240] ដែលសំដៅថា ជាមួយនឹងការដកស្រង់មិនពេញលេញនៅក្នុងកថាខណ្ឌខាងលើ សេចក្តីសម្រេចនេះបានផ្តល់សិទ្ធិអំណាចតែមួយគត់ឲ្យទៅ កែ ពក ក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងការបោសសម្អាត។ តាមពិតទៅ នៅពេលដែលចម្លើយរបស់ បាន សៀក ត្រូវបានមើលទាំងស្រុងនោះ មានការបង្ហាញថា សេចក្តីសម្រេចនេះបានប្រគល់ឲ្យទៅ អោ អាន ដោយសហការជាមួយនឹង កែ ពក និង សមាជិកបីនាក់ផ្សេងទៀតនៃគណៈអចិន្ត្រៃយ៍ភូមិភាគកណ្តាល នូវសិទ្ធិអំណាចក្នុងការកម្ទេច ក្នុងជួរ និង ក្រៅជួរ។

92. ស.ព.អ ក៏បានកត់សម្គាល់ផងដែរថា កំណត់ហេតុស្តាប់ចម្លើយរបស់ បាន សៀក ដែលដីកាសម្រេចលើកលែងចោទប្រកាន់បានពឹងផ្អែកលើចំណុចនេះ ត្រូវបានទទួលយកនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១២ នៅក្នុងពេលដែល ស.ច.ស.អ បម្រុង Laurent Kasper-Ansermet បានបំពេញភារកិច្ចជា ស.ច.ស អន្តរជាតិ[241]។ អ្នកស៊ើបអង្កេតដែលយកចម្លើយនេះបានធ្វើដូច្នេះ ដោយអនុលោមតាមដីកាចាត់ឲ្យស៊ើបសួរជំនួសមួយ ចុះកាលបរិច្ឆេទនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២ និងត្រូវបានចុះហត្ថលេខាដោយចៅក្រម Kasper-Ansermet[242]។ នេះមិនមែនជាឧទាហរណ៍តែមួយគត់ដែលដីកាសម្រេចលើកលែងចោទប្រកាន់ពឹងផ្អែកលើភស្តុតាងដែលត្រូវបានប្រមូលដោយចៅក្រម Kasper-Ansermet ៖ កំណត់ហេតុស្តាប់ចម្លើយរបស់ បាន សៀក ត្រូវបានដកស្រង់សរុប ២៥ ដង រួមទាំងសម្រាប់ចំណុចសំខាន់មួយទាក់ទងនឹងសិទ្ធិអំណាចរបស់ អោ អាន នៅតាមភូមិភាគ[243] ហើយភស្តុតាងដែលបានដាក់ចូលទៅក្នុងសំណុំរឿងនៅចន្លោះថ្ងៃទី១ ខែវិច្ឆិកា

---

[240] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៦០, *លើកឡើងពី* ឯកសារ **D1.3.19.1** សេចក្តី សំរេចរបស់គណៈមជ្ឈិម អំពី បញ្ហាផ្សេងៗមួយចំនួន, ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦, EN 00182809។

[241] ឯកសារ **D107/15** កំណត់ហេតុស្តាប់ចម្លើយ បាន សៀក, EN 00841963។

[242] ឯកសារ **D107/15** កំណត់ហេតុស្តាប់ចម្លើយ បាន សៀក, EN 00841963 [ដោយបានបញ្ជាក់ថា កំណត់ហេតុស្តាប់ចម្លើយត្រូវបានយកដោយអ្នកស៊ើបអង្កេត Christian Baudesson អនុលោមតាមដីកាចាត់ឲ្យស៊ើបសួរជំនួស ចុះកាលបរិច្ឆេទនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២]។ ឯកសារ **D107** ដីកាចាត់ឲ្យស៊ើបសួរជំនួស, ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២ [បានអនុញ្ញាតឲ្យលោក Christian Baudesson និងអ្នកផ្សេងៗទៀត ទៅបំពេញកិច្ចស៊ើបសួរ និងបានចុះហត្ថលេខាដោយ Laurent Kasper-Ansermet នៅក្នុងសមត្ថកិច្ចជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង]។

[243] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២២៧, *ដកស្រង់ពី* ឯកសារ **D107/15** កំណត់ហេតុស្តាប់ចម្លើយ បាន សៀក, EN 00841966 [ទាក់ទងនឹងបញ្ហាថាតើនរណាជាលេខាភូមិភាគ ខណៈដែល កែ ពក អវត្តមាន]។ *សូមអានផងដែរ* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កំណត់សម្គាល់ជើងទំព័រលេខ 370, 536, 560, 561, 562, 563, 565, 581, 651, 653, 655, 792, 793, 794, 795, 796, 797, 798, 799, 804, 812, 816, 1143, 1144, 1160 [កំណត់ហេតុស្តាប់ចម្លើយដែលបានលើកឡើងទាំងអស់នេះ បានមកពី បាន សៀក]។

ឆ្នាំ២០១១ និងថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១២ ត្រូវបានដកស្រង់យ៉ាងហោចណាស់ ១៧៧ ដង នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់[244]។

---

[244] *សូមកត់សម្គាល់ថា* ឯកសារយោងពីកំណត់សម្គាល់ជើងទំព័រទាំងអស់ដែលបានលើកឡើងនេះ មាននៅក្នុងកំណត់សម្គាល់ជើងទំព័រ ទាក់ទងនឹងឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់។ *សូមអាន* ឯកសារ **D106/5** កំណត់ហេតុស្តាប់ចម្លើយ ទុំ សឿន, ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ [៣ដង៖ កំណត់សម្គាល់ជើងទំព័រលេខ 208, 463, 464]។ ឯកសារ **D107/2** កំណត់ហេតុស្តាប់ចម្លើយ សាន់ សុន, ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ [៩ដង៖ កំណត់សម្គាល់ជើងទំព័រលេខ 1030, 1036, 1037, 1039, 1040, 1042, 1241, 1242, 1285]។ ឯកសារ **D107/3** កំណត់ហេតុស្តាប់ចម្លើយ កាក់ ស្រឿន, ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ (*កត់សម្គាល់ថា* ជួនកាល ដីកាសម្រេចលើកលែងចោទប្រកាន់លើកឡើងដោយខុសឆ្គងនូវកាលបរិច្ឆេទថាចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ទៅវិញ) [១២ដង៖ កំណត់សម្គាល់ជើងទំព័រលេខ 1026, 1029, 1030, 1032, 1034, 1035, 1036, 1037, 1038, 1042, 1146, 1250]។ ឯកសារ **D107/4** កំណត់ហេតុស្តាប់ចម្លើយ វង សុគន្ធ, ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ [១ដង៖ កំណត់សម្គាល់ជើងទំព័រលេខ 1250]។ ឯកសារ **D107/5** កំណត់ហេតុស្តាប់ចម្លើយ អ៊ិន គឹមអេង, ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ [១៨ដង៖ កំណត់សម្គាល់ជើងទំព័រលេខ 345, 364, 639, 694, 705, 708, 711, 714, 716, 805, 887, 891, 892, 898, 901, 1030, 1250, 1425]។ ឯកសារ **D107/6** កំណត់ហេតុស្តាប់ចម្លើយ ឆេង យឹន, ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ [៩ដង៖ កំណត់សម្គាល់ជើងទំព័រលេខ 722, 724, 771, 1250, 1256, 1258, 1259, 1269, 1285]។ ឯកសារ **D107/7** កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម កុល *ហៅ* សាយ, ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១២ [១៧ដង៖ កំណត់សម្គាល់ជើងទំព័រលេខ 576, 581, 690, 696 (ពីរដង), 711, 714, 724, 732, 761, 771, 1250, 1251, 1252, 1253, 1268, 1269]។ ឯកសារ **D107/8** កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម កុល *ហៅ* សាយ, ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ [៤ដង៖ កំណត់សម្គាល់ជើងទំព័រលេខ 1056, 1241, 1254, 1269]។ ឯកសារ **D107/9** កំណត់ហេតុស្តាប់ចម្លើយ មាន សាវុធ, ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១២ [១៣ដង៖ កំណត់សម្គាល់ជើងទំព័រលេខ 1138, 1139, 1141, 1143, 1144, 1145, 1146, 1149, 1158, 1159, 1166, 1169, 1170]។ ឯកសារ **D107/11** កំណត់ហេតុស្តាប់ចម្លើយ ខែក ញ៉ៅ, ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ [១២ដង៖ កំណត់សម្គាល់ជើងទំព័រលេខ 144, 1142, 1143, 1144, 1154, 1158, 1159, 1161, 1164, 1166, 1169, 1171]។ ឯកសារ **D107/12** កំណត់ហេតុស្តាប់ចម្លើយ គៀន ឡី *ហៅ* អ៊ុម, ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ [២ដង៖ កំណត់សម្គាល់ជើងទំព័រលេខ 1025, 1042]។ ឯកសារ **D107/13** កំណត់ហេតុស្តាប់ចម្លើយ ឡុង ស៊ុខែ, ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១២ [២០ដង៖ កំណត់សម្គាល់ជើងទំព័រលេខ 549, 554, 598, 798, 803, 804, 810, 1138, 1139, 1146, 1147, 1149, 1151, 1152, 1153, 1157, 1158, 1159, 1168, 1169]។ ឯកសារ **D107/14** កំណត់ហេតុស្តាប់ចម្លើយ ឈុន ឡា, ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ [៩ដង៖ កំណត់សម្គាល់ជើងទំព័រលេខ 1146, 1149, 1153, 1155, 1161, 1163, 1164, 1166, 1168]។ ឯកសារ **D107/15** កំណត់ហេតុស្តាប់ចម្លើយ បាន សៀក, ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១២ [២៥ដង៖ កំណត់សម្គាល់ជើងទំព័រលេខ 370, 536, 560, 561, 562, 563, 565, 581, 651, 653, 655, 792, 793, 794, 795, 796, 797, 798, 799, 804, 812, 816, 1143, 1144, 1160]។ ឯកសារ **D107/16** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង គោកព្រីង, ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ (*កត់សម្គាល់ថា* ដីកាសម្រេចលើកលែងចោទប្រកាន់លើកឡើងដោយខុសឆ្គងនូវកាលបរិច្ឆេទថា ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១២) [៩ដង៖ កំណត់សម្គាល់ជើងទំព័រលេខ 1025, 1027, 1028, 1029, 1030, 1036, 1037, 1040, 1041]។ ឯកសារ **D107/18** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ទួលតាផ្លុង, ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០១២ (*កត់សម្គាល់ថា* កាលបរិច្ឆេទដែលបានលើកឡើងថា

93. ស.ព.អ មិនជំទាស់ទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ដែលពឹងផ្អែកយ៉ាងខ្លាំងទៅលើភស្តុតាងដែលបានដាក់ចូលទៅក្នុងសំណុំរឿងនៅក្នុងរយៈពេលដែល ស.ច.ស.អ បម្រុង Kasper-Ansermet កាន់កាប់នោះទេ។ ច្បាប់ អ.វ.ត.ក ចែងពីសេចក្តីណែនាំយ៉ាងច្បាស់នៅក្នុងមាត្រា ២៦ ថា "ចៅក្រមស៊ើបអង្កេតបម្រុងត្រូវជំនួសចៅក្រមស៊ើបអង្កេតពេញសិទ្ធិ នៅពេលណាដែលចៅក្រមនេះអវត្តមាន ឬមានធុរៈ"[245] ដែលបានផ្តល់សិទ្ធិអំណាចយ៉ាងច្បាស់លាស់ឲ្យប្រើប្រាស់ភស្តុតាងនេះដែលត្រូវបានធ្វើឡើងនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់។

94. ស.ព.អ ក៏បានកត់សម្គាល់ផងដែរថា ខណៈដែលគាត់ក៏បានពឹងផ្អែកក្នុងកម្រិតមួយទៅលើភស្តុតាងដែលត្រូវបានប្រមូលដោយចៅក្រម Kasper-Ansermet នោះ អំណះអំណាងទាំងអស់ដែលមាននៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ នឹងមានសុពលភាព នៅពេលគ្មានភស្តុតាងនេះដោយកន្លងមកចំណុចនេះត្រូវបានជំទាស់។ ការពិនិត្យលើភស្តុតាងដែលមាននៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ បង្ហាញថា ផ្នែកមិនសំខាន់មួយផ្នែកនៃភស្តុតាងនោះ ត្រូវបានប្រមូលនៅក្នុងរយៈពេលចន្លោះពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១១ និងថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១២។ ភស្តុតាងនេះមិនមានកំណត់ពីការទទួលខុសត្រូវព្រហ្មទណ្ឌជារួមរបស់ អោ អាន នោះទេ។ ភាគច្រើននៃភស្តុតាងសំខាន់បំផុតនៅក្នុងរឿងក្តីនេះ ត្រូវបានប្រមូលនៅក្នុងរយៈពេលរបស់អ្នកស្នងចៅក្រម Kasper-Ansermet គ្រប់គ្រង ហើយសំណុំរឿងប្រឆាំងនឹង អោ អាន មានសុពលភាព ផ្អែកលើភស្តុតាងនេះតែឯង។

## ច. កំហុសអង្គច្បាប់ស្តីពីការខកខានមិនបានពិចារណាឲ្យបានគ្រប់គ្រាន់ពីផលប៉ះពាល់នៃអ្នកដឹកនាំរបស់ អោ អាន ដែលបានកំណត់ ក្នុងយុទ្ធនាការបូស័យពូជសាសន៍ថ្នាក់តំបន់

នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២ គឺខុស) [៥ដង៖ កំណត់សម្គាល់ជើងទំព័រលេខ 1099, 1105, 1108, 1112, 1117]។ ឯកសារ **D107/19.1** កំណត់ហេតុស្តាប់ចម្លើយ វង សុគន្ធ, ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ [៩ដង៖ កំណត់សម្គាល់ជើងទំព័រលេខ 602, 620, 743, 898 (ពីរដង), 1250, 1264, 1425 (ពីរដង)]។

[245] ច្បាប់ អ.វ.ត.ក, មាត្រា ២៦។ *សូមអាន* សំណុំរឿងលេខ០០៣-មតិរបស់ចៅក្រម Downing និង Chung នៃអង្គបុរេជំនុំជម្រះ ស្តីពីការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន៧២ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២។ ឯកសារ **D114** កំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ផ្ញើជូនភាគី ស្តីពីការមិនអាចដំណើរការបានដ៏ធ្ងន់ធ្ងរនៅ អ.វ.ត.ក ដែលរារាំងការបំពេញកិច្ចស៊ើបសួរឲ្យបានត្រឹមត្រូវ ក្នុងសំណុំរឿង០០៣ និង សំណុំរឿង ០០៤, ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២។

## ចំពោះការវាយតម្លៃថាតើ អោ អាន ស្ថិតនៅក្នុងចំណោមជននាំមុខឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ឬទេ

95. គុណវិបត្តិមួយក្នុងចំណោមគុណវិបត្តិសំខាន់នៃដីកាសម្រេចលើកលែងចោទប្រកាន់នោះគឺ ការខកខានមិនបានយកចិត្តទុកដាក់ចំពោះផលប៉ះពាល់នៃតួនាទីរបស់ អោ អាន នៅក្នុងអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងពួកជនជាតិចាម ចំពោះបញ្ហាយុត្តាធិការបុគ្គល។ ដូចដែលបានពិភាក្សានៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ តួនាទីរបស់ អោ អាន នៅក្នុងអំពើប្រល័យពូជសាសន៍ជនជាតិចាម ត្រូវបានកំណត់ និងច្បាស់។ ភស្តុតាងបង្ហាញថា អោ អាន បានបញ្ជាអ្នកនៅក្រោមបង្គាប់របស់គាត់ឲ្យកំណត់អត្តសញ្ញាណជនជាតិចាមនៅតាមកន្លែងនានាក្រោមការត្រួតពិនិត្យរបស់ពួកគេ ហើយបន្ទាប់មកសម្លាប់ពួកគេទាំងអស់[246]។ គាត់បានទទួលឲ្យមានរបាយការណ៍នានាពីអ្នកនៅក្រោមបង្គាប់របស់គាត់ ដូច្នេះគាត់អាចត្រួតពិនិត្យពីការវិវត្តនៃអំពើប្រល័យពូជសាសន៍[247] ហើយគាត់ផ្ទាល់បានចាត់វិធានការដើម្បីធានាឲ្យប្រាកដថា អំពើនេះត្រូវបានបំពេញតាមដែលអាចធ្វើទៅបាន បន្ទាប់ពីការសម្លាប់លើកដំបូងមក គាត់បានបញ្ជាឲ្យអ្នកនៅក្រោមបង្គាប់របស់គាត់ឲ្យធ្វើដំណើរទៅកាន់ភូមិនានា ដើម្បីឲ្យបានដឹងថាតើមានជនជាតិចាមខ្លះបាននៅរស់ដែរឬទេ[248]។ ចំណុចនេះប្រហែលជាភស្តុតាងដែលច្បាស់លាស់បំផុតពីចេតនាប្រល័យពូជសាសន៍ដែលអាចប្រមើលមើលបាន។ ការសន្និដ្ឋានផ្នែកអង្គហេតុនានានៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ខ្លួនឯងផ្ទាល់ ក៏បានគាំទ្រដល់សេចក្តីសន្និដ្ឋាននេះផងដែរ។ ដីកាសម្រេចលើកលែងចោទប្រកាន់ បានរកឃើញថាមានគោលនយោបាយមួយរបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងការបំផ្លាញជនជាតិចាម[249] ថា អោ អាន បានទទួលបញ្ជាឲ្យអនុវត្តគោលនយោបាយនេះ ពីថ្នាក់លើរបស់គាត់ និងបានទម្លាក់បញ្ជាទាំងនោះទៅអ្នកនៅក្រោមបង្គាប់របស់

[246] ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៥៤-៥៩។

[247] ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៦០។

[248] ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៦១-៦២។

[249] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៥១-១៥៦។

គាត់[250] និងថា គោលនយោបាយនោះ តាមពិតទៅត្រូវបានអនុវត្តនៅក្នុងកន្លែងនានាដែលនៅក្រោមការត្រួតពិនិត្យរបស់គាត់[251]។

96. អំពើប្រល័យពូជសាសន៍ត្រូវបានគេចាត់ទុកជាទូទៅថាជា ឧក្រិដ្ឋកម្មមួយធ្ងន់ធ្ងរបំផុត ដោយសារវាជាការវាយប្រហារមួយទៅលើគ្រួសារទាំងមូល ក៏ដូចជាពួកជនរងគ្រោះផ្ទាល់ខ្លួនដែរ[252]។ ការទទួលស្គាល់ដូច្នេះ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នទៅលើអនុសញ្ញាប្រល័យពូជសាសន៍ ឆ្នាំ ១៩៥០ ហើយឥឡូវនេះ ជាប្រទេសមួយក្នុងចំណោម ១៤៩ ប្រទេសដែលជា ភាគីនៃអនុសញ្ញានោះ។ អនុសញ្ញាប្រល័យពូជសាសន៍មានភាសាកំណត់ ដែលតម្រូវឲ្យមានការផ្តន្ទាទោសអំពើ

---

[250] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១០-៤១៨។ *សូមអានផងដែរ* សំណុំរឿង០០២-ឯកសារ **E1/529.1** ការប្រកាសសាលក្រមក្នុងសំណុំរឿង០០២/០២ ប្រតិចារឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ម៉ោង៖ 10.24.31-10.29.55។

[251] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៣០៦-៣០៧, ៣១០-៣១១, ៤១៣-៤១៥។

[252] បុព្វកថានៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ["អំពើប្រល័យពូជសាសន៍ គឺជាឧក្រិដ្ឋកម្មមួយនៅក្រោមច្បាប់ អន្តរជាតិដែលផ្ទុយទៅនឹងស្មារតី និងគោលបំណងនៃអង្គការសហប្រជាជាតិ ហើយត្រូវបានផ្តន្ទាទោសដោយប្រទេសដែលមានអរិយភាព [...] អំពើប្រល័យពូជសាសន៍បានធ្វើឲ្យប៉ះពាល់ដល់មនុស្សជាតិជាច្រើន [...] ក្នុងគោលបំណងដើម្បីធ្វើឲ្យ ប្រជាជនរួចផុតពីអំពើឃោរឃៅដែលគួរឲ្យស្អប់ខ្ពើម គេតម្រូវឲ្យមានកិច្ចសហប្រតិបត្តិការអន្តរជាតិមួយ"]។ សេចក្តី សម្រេចចិត្តរបស់មហាសន្និបាត អ.ស.ប លេខ៩៦(I), *ឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍*, ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៤៦, A/RES/96(I), ទំព័រ ១៨៨-១៨៩ ["អំពើប្រល័យពូជសាសន៍គឺជាការបដិសេធសិទ្ធិនៃអត្ថិភាពជាក្រុមមនុស្សទាំងមូល ដែលប៉ះពាល់ដល់មនសិការជាមនុស្សជាតិ បណ្តាលឲ្យមានការបាត់បង់ដ៏មហិមាដល់មនុស្សជាតិនៅក្នុងទម្រង់វប្បធម៌មួយ និងការចូល រួមចំណែកផ្សេងៗទៀតដែលបានតំណាងឲ្យដោយក្រុមមនុស្សទាំងនេះ ហើយផ្ទុយទៅនឹងច្បាប់សីលធម៌ និងស្មារតី និងគោលបំណងរបស់អង្គការសហប្រជាជាតិ។ [...] ការផ្តន្ទាទោសពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នេះ គឺជាបញ្ហាព្រួយបារម្ភអន្តរជាតិមួយ"]។ *រដ្ឋអាជ្ញា ទល់នឹង Krstić*, សំណុំរឿងលេខ IT-98-33-T, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០១ ("សាលក្រមរបស់ *Krstić*"), កថាខណ្ឌ ៥៥៣, ៧០០ ["ដូច្នេះ អនុសញ្ញានេះស្នើសុំការការពារ សិទ្ធិនៃការរស់រានមានជីវិតនៃក្រុមមនុស្សទាំងនោះ។ លក្ខណៈនេះធ្វើឲ្យអំពើប្រល័យពូជសាសន៍ទៅជាឧក្រិដ្ឋកម្មមួយដ៏ធ្ងន់ធ្ងរ ពិសេស ហើយខុសប្លែកពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរផ្សេងៗទៀត ជាពិសេសការផ្តន្ទាទោស កាលណាអ្នកប្រព្រឹត្តបទល្មើសធ្វើការជ្រើសរើសជនរងគ្រោះ ដោយសារតែសមាជិកភាពរបស់ពួកគេនៅក្នុងសហគមន៍ដោយឡែកមួយ ប៉ុន្តែមិនចាំបាច់ព្យាយាមបំផ្លាញសហគមន៍នោះទេ។ [...] យ៉ាងណាក៏ដោយ អាចថា អំពើប្រល័យពូជសាសន៍គឺជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុត ដោយសារតែលក្ខខណ្ឌតម្រូវនៃចេតនាក្នុងការបំផ្លាញរបស់វា ទាំងមូល ឬជាផ្នែក ជនជាតិណាមួយ ពន្ធុ ពូជសាសន៍ ឬក្រុមសាសនា។ នៅក្នុងន័យនេះ សូម្បីតែអំពើឧក្រិដ្ឋកម្មនានាដោយផ្ទាល់ ក៏ជាប់ទាក់ទងនឹងអំពើប្រល័យពូជសាសន៍ អាចមិនប្រែប្រួលពីអំពើទាំងឡាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋកម្មប្រឆាំងនឹងច្បាប់ និងទម្លាប់សង្គ្រាម បុគ្គលដែលត្រូវបានកាត់ឲ្យជាប់ទោស សមនឹងត្រូវបានទទួលការស្តីបន្ទោស ដោយសារតែចេតនាជាក់លាក់ របស់គាត់"]។

ប្រល័យពូជសាសន៍នេះ។ ជាឧទាហរណ៍ មាត្រា I ចែងថា "ភាគីនៃអនុសញ្ញា [...] ត្រូវចាត់ការការពារ និង *ផ្ដន្ទាទោស*" អំពើប្រល័យពូជសាសន៍។ មាត្រា IV ចែងថា "បុគ្គលដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ [...] *ត្រូវ* ទទួលការផ្ដន្ទាទោស"។ មាត្រា VI ចែងថា "បុគ្គលដែលត្រូវបានចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍ [...] *ត្រូវ* បានជំនុំជម្រះក្ដី ដោយតុលាការមានសមត្ថកិច្ចនៃរដ្ឋនៅក្នុងទឹកដីដែលអំពើនោះត្រូវបានប្រព្រឹត្ត"[253]។ លើសពីនេះទៀត តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICJ") បានសម្រេចថា អនុសញ្ញានេះតំណាងឱ្យ គោលការណ៍នានាដែលជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិទូទៅ[254]។

97. នៅក្នុងករណីរឿង *Bosnia និង Herzegovina ទល់នឹង Serbia និង Montenegro* តុលាការ ICJ បានសម្រេចថា ប្រទេស Serbia បានបំពានលើកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្ដន្ទាទោសអំពើប្រល័យពូជសាសន៍ ដោយការខកខានមិនបានចាប់ខ្លួនលោក Ratko Mladić និងបញ្ជូនគាត់ឱ្យទៅតុលាការ ICTY ដើម្បីកាត់សេចក្ដីពីបទប្រល័យពូជសាសន៍នៅ Srebrenica[255] ដែលនៅក្នុងនោះគេបានរកឃើញ (ដោយពឹងផ្អែកលើករណីយុត្តិសាស្ត្ររបស់ ICTY) ថា មានពួកបុរស និងពួកក្មេងៗមូស្លីមបូស្នី ប្រមាណ ៧.០០០នាក់ ត្រូវបានសម្លាប់[256]។ នៅក្នុងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ស.ច.ស.អ បានគណនាចំនួននៃជនរងគ្រោះដែលបានប៉ាន់ប្រមាណជាអប្បបរមាពីជនរងគ្រោះជនជាតិចាមដោយអំពើប្រល័យពូជសាសន៍ នៅ តំបន់៤១ គឺ ៧.៩១០នាក់[257]។ ចំនួនពិតប្រាកដទំនងជាមានច្រើនជាងនេះឆ្ងាយណាស់។ បន្ទាប់ពីការស្ទង់មតិនៅឃុំទ្រាន ក្នុងស្រុកកំពង់សៀម អ្នកស៊ើបអង្កេត ក.ស.ច.ស បានប៉ាន់ប្រមាណថា មានជន

[253] អនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍, មាត្រា I, IV, VI (សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*)។

[254] ការអនុវត្តអនុសញ្ញាស្ដីពីការការពារ និងការផ្ដន្ទាទោសចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (*Bosnia និង Herzegovina ទល់នឹង Serbia និង Montenegro*), សាលក្រម, របាយការណ៍ឆ្នាំ២០០៧ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (I.C.J.) ("សាលក្រមក្នុងករណី *Bosnia និង Herzegovina ទល់នឹង Serbia និង Montenegro*"), កថាខណ្ឌ ១៦១។

[255] សាលក្រមក្នុងករណី *Bosnia និង Herzegovina ទល់នឹង Serbia និង Montenegro*, កថាខណ្ឌ ៤៣៩-៤៥០។

[256] សាលក្រមក្នុងករណី *Bosnia និង Herzegovina ទល់នឹង Serbia និង Montenegro*, កថាខណ្ឌ ២៧៨-២៩៧ *ដោយលើកឡើងពី* សាលក្រមរបស់ *Krstić*, កថាខណ្ឌ ១។

[257] ឯកសារ **D360** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ ៦៤៧ [ជាអប្បបរមា មានចាម 1,027នាក់ ត្រូវបានសម្លាប់នៅស្រុកកំពង់សៀម]។ កថាខណ្ឌ ៦៥១ [ជាអប្បបរមា មានចាម 6,443នាក់ ត្រូវបានសម្លាប់នៅស្រុកកងមាស]។ កថាខណ្ឌ ៦៥៣ [ជាអប្បបរមា មានចាម 200នាក់ ត្រូវបានសម្លាប់នៅស្រុកជើងព្រៃ]។ កថាខណ្ឌ ៦៥៥ [ជាអប្បបរមា មានចាម 240នាក់ ត្រូវបានសម្លាប់នៅស្រុកបាធាយ]។

រងគ្រោះចាមចំនួន ១.៨០០ នាក់ ពីឃុំនោះតែមួយ ដែលជាឃុំមួយក្នុងចំណោម ១១ ឃុំ នៅស្រុកកំពង់សៀម[258]។ ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានផ្តល់ចំនួនជាក់លាក់នោះទេ ដោយថា ភាគច្រើននៃជនជាតិចាមនៅស្រុកកំពង់សៀម និង កងមាស ត្រូវបានសម្លាប់[259]។

98. ដូច្នេះ ជាភាគីមួយនៃអនុសញ្ញាប្រល័យពូជសាសន៍ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមានកាតព្វកិច្ចមួយនៅក្រោមច្បាប់អន្តរជាតិ ដែលខុសពីកាតព្វកិច្ចរបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក ក្នុងការនាំខ្លួន អោ អាន ទៅជំនុំជម្រះពីបទចោទប្រកាន់ទាំងនេះ។ ជាការសមហេតុផលក្នុងការសន្មតថា អ្នកតាក់តែងច្បាប់កម្ពុជា និងអ្នកចរចារបស់ អ.ស.ប បានដឹងឮពីកាតព្វកិច្ចអន្តរជាតិក្នុងការផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ នៅពេលដែលការចរចារវាង អ.ស.ប និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានប្រព្រឹត្តទៅ ហើយច្បាប់ អ.វ.ត.ក ត្រូវបានអនុម័ត។ ដូច្នេះ ភាគីទាំងពីរត្រូវតែមានចេតនាថា យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែលគ្របដណ្តប់ទៅដោយបុគ្គល "ដែលទទួលខុសត្រូវខ្ពស់ជាងគេបំផុត" ចំពោះឧក្រិដ្ឋកម្មនានានៃរបបកម្ពុជាប្រជាធិបតេយ្យ រួមមានមេដឹកនាំម្នាក់ដែលមានតួនាទីសំខាន់នៅក្នុងអំពើប្រល័យពូជសាសន៍ ដោយចេញបញ្ជាពីខ្លួនឯងផ្ទាល់ឲ្យសម្លាប់មនុស្សរាប់ពាន់នាក់ ដោយមានចេតនាបំផ្លិចបំផ្លាញសាសនា និងក្រុមជាតិពន្ធុមួយ។

99. ការខកខានមិនបានពិចារណាពីផលប៉ះពាល់នៃអំពើប្រល័យពូជសាសន៍ ពាក់ព័ន្ធទៅនឹងយុត្តាធិការបុគ្គលនេះ ត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងការប្រៀបធៀបនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ពីការទទួលខុសត្រូវរបស់ អោ អាន និងការទទួលខុសត្រូវរបស់ ឌុច។ ទោះបីជាលើកឡើងច្រើនអំពីការប្រៀបធៀប[260] និងពឹងផ្អែក លើវាយ៉ាងសំខាន់នៅក្នុងការសន្និដ្ឋានរបស់ខ្លួន ស្តីពីយុត្តាធិការបុគ្គល[261] ក៏ដីកាសម្រេចលើកលែងចោទប្រកាន់នេះ មិនទាំងពិចារណាពីតួនាទីដ៏សំខាន់របស់ អោ អាន នៅក្នុងអំពើប្រល័យពូជសាសន៍ (ដែល ឌុច ត្រូវបានចោទប្រកាន់) នៅក្នុង ការវាយតម្លៃពីកម្រិតនៃការទទួលខុសត្រូវរបស់ពួកគេ។

---

[258] ឯកសារ **D219/492** របាយការណ៍នៃសកម្មភាពនៃការស៊ើបអង្កេត, EN 01138987។

[259] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៣០៧, ៤១៤។

[260] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៥៤៣-៥៥១។

[261] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៥៥៣។

## V. សេចក្តីសន្និដ្ឋានទាក់ទងនឹងដីកាដំណោះស្រាយដែលផ្ទុយគ្នា

100. ដូចដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ ស.ព.អ យល់ឃើញច្បាស់ថា ត្រូវកែប្រែការសម្រេចទៅលើយុត្តាធិការបុគ្គលនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ និងបញ្ជូនសំណុំរឿងប្រឆាំងនឹង អោ អាន ទៅជំនុំជម្រះ ដោយផ្អែកលើដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ។ យ៉ាងណាក៏ដោយ ស.ព.អ ដឹងថា ដើម្បីធ្វើដូច្នេះបាន ត្រូវមានការគាំទ្រពីមតិភាគច្រើនលើសលប់របស់ចៅក្រម អ.ប.ជ ដើម្បីទទួលបានសេចក្តីសម្រេចមួយដែលជាប់កាតព្វកិច្ច[262]។ ស.ព.អ ក៏ដឹងផងដែរថា ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះអាចមានការប្តឹងឧទ្ធរណ៍ ដោយមានលក្ខខណ្ឌតម្រូវនៃមតិភាគច្រើនលើសលប់ដូចគ្នាដែរ។ ដូច្នេះ មានលទ្ធភាពច្រើនថា ទាំង ដីកាសម្រេចលើកលែងចោទប្រកាន់ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ នឹងមានបណ្តឹងឧទ្ធរណ៍ ក៏ប៉ុន្តែ អ.ប.ជ នឹងមិនទទួលបានមតិគាំទ្រជាឯកច្ឆ័ន្ទរួមដែលជាលក្ខខណ្ឌ ដើម្បីធ្វើការសម្រេចលើបញ្ហាទាំងនោះទេ[263]។

101. បើសិនជាស្ថានភាពនេះកើតឡើងមែននោះ បទប្បញ្ញត្តិដែលពាក់ព័ន្ធនៃវិធានផ្ទៃក្នុងកំណត់ថា សំណុំរឿងបន្តទៅជំនុំជម្រះដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ លទ្ធផលនេះស្របគ្នាជាមួយនឹងយុត្តិសាស្ត្ររបស់ អ.ជ.ត.ក និងគោលនយោបាយនៃកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក និងយុត្តិសាស្ត្រផ្សេងៗទៀតរបស់ អ.វ.ត.ក។

102. វិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង ចែងថា៖

> សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម ៤(បួន) រូបយ៉ាងតិច។ សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។ ប្រសិនបើសម្លេងភាគច្រើនដែល

---

[262] វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង។

[263] អោ អាន បានបញ្ជាក់ថា គាត់មានបំណងដាក់ញត្តិស្តីពីផលប៉ះពាល់នៃដីកាដំណោះស្រាយដែលផ្ទុយគ្នា ជាផ្នែកនៃបណ្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយ ស.ព.អ រំពឹងថានឹងដាក់អំណះអំណាងបន្ថែមលើចំណុចនេះនៅក្នុងចម្លើយតបទៅនឹងញត្តិរបស់ អោ អាន ស្តីពីបញ្ហានេះ។ យ៉ាងណាក៏ដោយ ស.ព.អ មានបំណងដាក់សេចក្តីសង្ខេបមួយនៃសេចក្តីសន្និដ្ឋានរបស់ខ្លួននៅលើចំណុចនេះនៅលើកំណត់ត្រានៅក្នុងដំណាក់កាលនេះ ដោយសារតែមានភាពមិនច្បាស់លាស់នៃកិច្ចដំណើរការនីតិវិធីចំណុចថាតើនៅពេលណាដែលបញ្ហានេះត្រូវបានដោះស្រាយយ៉ាងត្រឹមត្រូវ។

តម្រូវ មិនអាចរកបានទេ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្ររបស់អង្គបុរេជំនុំជម្រះ ត្រូវអនុវត្តដូចខាងក្រោម៖

ក- ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ ឬ ពាក្យសុំមោឃភាពដីកា ឬ កិច្ចស៊ើបសួរដែល មិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកា ឬ កិច្ចស៊ើបសួរនោះ ត្រូវតម្កល់ទុក ជាបានការ។

ខ- ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហ ចៅក្រមស៊ើបអង្កេត ប្រសិនបើមិនអាចរកសម្លេងភាគច្រើនដែលត្រូវបាននោះទេ អង្គបុរេជំនុំជម្រះ ត្រូវសម្រេចប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើ មូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។

103. វិធាន ១(២) នៃវិធានផ្ទៃក្នុង ចែងបន្ថែមទៀតថា "ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យ សហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេច ចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ ទោះបីដោយផ្ទាល់ ឬតាមរយៈ អ្នកតំណាង"។ ដូច្នេះវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង អនុវត្តចំពោះដីកាបញ្ជូនរឿងទៅជំនុំ ជម្រះ ដែលចេញដោយ ស.ច.ស តែម្នាក់ឯង ដូចនៅក្នុងករណីនេះ។

104. វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង បញ្ជាក់ច្បាស់ថា បើសិនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនបានបដិសេធដោយសម្លេងគាំទ្រលើសលប់នៃសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍នោះទេ សំណុំ រឿងប្រឆាំងនឹង អោ អាន ត្រូវបញ្ជូនទៅជំនុំជម្រះ។ បើទោះបីជា ពាក្យថា "ដីកា" នៅក្នុង វិធាន ៧៧(១៣)(ក) ត្រូវបានកំណត់ថារួមទាំងការសម្រេចលើកលែងចោទប្រកាន់ផងនោះ វិធាន ៧៧ (១៣)(ខ) *មានលក្ខណៈពិសេសខុសពីគេ (lex specialis)* ទាក់ទងនឹងដីកាបញ្ជូនរឿងទៅ ជំនុំជម្រះ ហេតុដូច្នេះ វិធាននេះមានអនុភាពខ្ពស់លើសពីការចែងទូទៅនៃវិធាន ៧៧(១៣)(ក)។ ស.ព.អ កត់សម្គាល់ថា "ដីកាសម្រេចលើកលែងចោទប្រកាន់" និង "ដីកាដំណោះស្រាយ" ដូច "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ដែរ ត្រូវបានកំណត់នៅក្នុងវិធានផ្ទៃក្នុង[264] ហើយប្រសិនបើអ្នក រៀបចំសេចក្តីព្រាងវិធានផ្ទៃក្នុងមានបំណងចង់ដោះស្រាយទៅលើផលប៉ះពាល់នៃការមិនអាចទទួ

[264] វិធានផ្ទៃក្នុង, សទ្ទានុក្រម, ទំព័រ ៨៣-៨៤។

លបានមតិគាំទ្រភាគច្រើនលើសលប់នៃ អ.ប.ជ ក្នុងការសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍មួយស្ដីពីដីកាសម្រេចលើកលែងចោទប្រកាន់ អ្នករៀបចំសេចក្ដីព្រាងទាំងនោះពិតជាបានចែងដូច្នេះហើយ។ បើទោះជាវិធាន ៧៧(១៣)(ក) ត្រូវបានកំណត់ថាមានន័យថា ដីកាសម្រេចលើកលែងចោទប្រកាន់ដែលត្រូវប្ដឹងឧទ្ធរណ៍ដោយមិនបានជោគជ័យ "ត្រូវតម្កល់ទុកជាបានការ" ជាកំណត់ត្រាមួយនៃការអនុវត្តឆន្ទានុសិទ្ធិឯករាជ្យរបស់ ស.ច.ស និងការសម្រេចមិនចូលរួមនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ វិធាន៧៧(១៣)(ខ) បញ្ជាក់ពីជម្រើសគោលនយោបាយដែលថា នៅក្នុងករណីមានដីកាដំណោះស្រាយដែលផ្ទុយគ្នា អង្គជំនុំជម្រះសាលាដំបូងត្រូវតែទទួលដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយសំណុំរឿងនេះត្រូវតែបន្តទៅជំនុំជម្រះ។

105. យុត្តិសាស្ត្ររបស់ អ.ជ.ត.ក បានបញ្ជាក់លើការបកស្រាយនេះ។ នៅក្នុងសាលដីកាលើ សំណុំរឿង ០០១ អ.ជ.ត.ក បានសម្រេចថាៈ

> ឧទាហរណ៍ ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមណាមួយមានកំហុសក្នុងការសម្រេចចេញ ឬក្នុងការស្នើឱ្យចេញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់ ដោយមូលហេតុថា ជនត្រូវចោទ គឺជា ឬមិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិនបើ អង្គបុរេជំនុំជម្រះមិនអាចទទួលបានសម្លេងគាំទ្រភាគច្រើនលើសលុបទៅលើផលវិបាកនៃសេណារីយ៉ូនេះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ"[265]។

106. ទោះបីជា អ.ជ.ត.ក បានប្រើឃ្លាថា "ការស៊ើបអង្កេតត្រូវបន្តទៅមុខ" ដោយសារឃ្លានេះត្រូវបានដកស្រង់ពីច្បាប់ អ.វ.ត.ក ក៏ដោយ ក៏ការបកស្រាយដ៏សមហេតុផលតែមួយគត់នៃឃ្លានេះគឺថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងត្រូវបន្តទៅជំនុំជម្រះ ដោយមិនមានន័យអ្វីផ្សេងទៀតដែលថា អ្វីៗអាច "បន្តទៅមុខ" នៅដំណាក់កាលដែល អ.ជ.ត.ក កំពុងពិភាក្សា (*គឺថា* នៅពេលដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់ ត្រូវបានចេញ)។ ដោយសារតែវិធានផ្ទៃក្នុងកំណត់ "ដំណាក់កាលជំនុំជម្រះ" ថាជា ការ "សំដៅទៅកាលបរិច្ឆេទ

---

[265] សំណុំរឿង០០១-**F28** សាលដីកា, ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២, កថាខណ្ឌ ៦៥ *លើកឡើងពី* ច្បាប់ អ.វ.ត.ក, មាត្រា ២៣*ថ្មី*។ កិច្ចព្រមព្រៀង អ.វ.ត.ក, មាត្រា ៧(៤)។ វិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង។

ដែលអង្គជំនុំជម្រះសាលាដំបូងទទួលសំណុំរឿង"[266] អ.ជ.ត.ក យល់ថា "ការស៊ើបអង្កេត" កំពុងបន្តរហូតដល់ពេលដែល អ.ប.ជ បំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមការតម្រូវនៃវិធាន ៧៧(១៣)(ខ)។

107. លទ្ធផលនេះក៏ស្របទៅនឹងស្មារតី និងរចនាសម្ព័ន្ធនៃកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុងដែរ។ ឯកសារទាំងអស់នេះប្រកាន់យកគោលការណ៍ដែលថា ស.ច.ស និង សហព្រះរាជអាជ្ញាអាចដំណើរការដោយឯករាជ្យក្នុងការជំរុញកិច្ចដំណើរការនីតិវិធី និងគោលនយោបាយជម្រើសដើម្បីឲ្យកិច្ចដំណើរការនីតិវិធីបន្តទៅមុខ ក្នុងករណីមានការខ្វែងយោបល់ដែលមិនត្រូវបានដោះស្រាយ[267]។ អ.ប.ជ បានប្រកាន់យកគោលការណ៍នេះជាញឹកញាប់[268]។

108. ជាចំណុចចុងក្រោយ នៅក្នុងស្ថានភាពបច្ចុប្បន្នដែលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់ នៅពេលតែមួយ ពី ស.ច.ស មាត្រា៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក បានផ្តល់ជាការណែនាំយ៉ាងច្បាស់លាស់ថាតើត្រូវធ្វើអ្វីទៀត បើសិនជា អ.ប.ជ មិនអាចទទួលបានមតិភាគច្រើនដែលចាំបាច់ដើម្បីសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍ទាំងពីរនេះ។ មាត្រានេះចែងថា នៅពេលដែល អ.ប.ជ មិនអាចដោះស្រាយការខ្វែងយោបល់គ្នារវាង ស.ច.ស

[266] វិធានផ្ទៃក្នុង, សទ្ទានុក្រម, ទំព័រ ៨៥។

[267] *សូមអាន* កិច្ចព្រមព្រៀង អ.វ.ត.ក, មាត្រា ៥(៤), ៦(៤), ៧(៤)។ ច្បាប់ អ.វ.ត.ក, មាត្រា ២០*ថ្មី*, ២៣*ថ្មី*។ វិធាន ៧១, ៧២, ៧៧(១៣) នៃវិធានផ្ទៃក្នុង។

[268] *សូមអានឧទាហរណ៍* ឯកសារ **D1/1.3** ការពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៧១នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩, កថាខណ្ឌ១៦, ២៦, ៤៥។ សំណុំរឿង០០២-**D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ២៧៤-២៧៦។ ឯកសារ **A122/6.1/3** សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រីឲ្យមកបង្ហាញខ្លួនជាលើកដំបូង, ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤, កថាខណ្ឌ១៤។ សំណុំរឿង០០៣-**D117/1/1/2** [កោសលុប] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើ របស់ជនសង្ស័យទាក់ទងនឹងដីកាកោះ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់, ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៤, កថាខណ្ឌ១៦។ ឯកសារ **D212/1/2/2** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ជំទាស់ទៅនឹងការបំភ្លឺរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីសុពលភាពនៃដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់, ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៤, កថាខណ្ឌ៧ ។ ឯកសារ **D208/1/1/2** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងដីកាសម្រេចបដិសេធសំណើរបស់គាត់ ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣, ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ២០១៥, កថាខណ្ឌ១១។

ឬ សហព្រះរាជអាជ្ញា នោះ "ការស៊ើបសួរ ឬការចោទប្រកាន់ ត្រូវដំណើរការទៅមុខ"[269]។ មិនថានរណាម្នាក់យល់ថា ការបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ថាជាផ្នែកមួយនៃកិច្ចស៊ើបសួរ ឬជាផ្នែកនៃការចោទប្រកាន់នោះទេ មានការបញ្ជាក់ច្បាស់ថា ប្រសិនបើ អ.ប.ជ មិនអាចទទួលបានមតិគាំទ្រភាគច្រើនដែលចាំបាច់ ដើម្បីសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍លើដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ត្រូវទទួលសំណុំរឿង និងបន្តទៅជំនុំជម្រះ។

## VI. សេចក្តីសន្និដ្ឋាន

109. ដូចបានកំណត់នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ អោ អាន បានបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់ជនរងគ្រោះរាប់ពាន់ ឬរាប់ម៉ឺននាក់ នៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់គាត់[270]។ គាត់បានរៀបចំ និងដឹកនាំយុទ្ធនាការនៃការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម នៅទូទាំងតំបន់៤១[271]។ គាត់គ្រប់គ្រងលើបណ្តាញមន្ទីរសន្តិសុខក្នុងតំបន់៤១ ដែលនៅទីនោះ អ្នកទោសត្រូវបានគេធ្វើទារុណកម្មយ៉ាងឃោរឃៅមុននឹងសម្លាប់ចោល ហើយគាត់បានសម្របសម្រួលការដឹកជញ្ជូនជនរងគ្រោះទាំងនេះយ៉ាងច្រើនសន្ធឹកសន្ធាប់នៅទូទាំងតំបន់នេះ ដើម្បីធានាឲ្យបាននូវការប្រព្រឹត្តិយ៉ាងរលូននៃការបោសសម្អាតនៅតំបន់ ៤១ នេះ[272]។ គាត់បានបន្ទុះបង្អាប់ និងចំអកឲ្យអ្នកដែលគាត់មានផែនការសម្លាប់ ហើយគាត់បានធ្វើយុត្តិកម្ម និងញុះញង់ឲ្យមាន

[269] កិច្ចព្រមព្រៀង អ.វ.ត.ក, មាត្រា៧(៤)។ ចំណុចនេះក៏ឆ្លុះបញ្ចាំងពីការយល់ដឹងរបស់មនុស្សម្នាក់ក្នុងចំណោមអ្នកចរចាសំខាន់ៗរបស់ អ.ស.ប ស្តីពីកិច្ចព្រមព្រៀង អ.វ.ត.ក គឺលោក David Scheffer ដែលបានថ្លែងថា នៅក្រោមវិធានស្តីពីមតិភាគច្រើនលើសលប់ "វិធីតែមួយគត់ក្នុងការបញ្ចប់ការចោទប្រកាន់ ឬការស៊ើបសួរ គឺប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចដោយទទួលបានមតិភាគច្រើនលើសលប់តាមរយៈការបោះឆ្នោត ថាត្រូវតែចប់"។ *សូមអាន* លោក David Scheffer, "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា", *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*, បោះពុម្ពលើកទីបី, វ៉ុលុម III, ឆ្នាំ២០០៨, ទំព័រ ២៤៦។

[270] ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១៧-៣៥, ៤៧-៥០, ៥៤-៥៩, ៦៧៧។

[271] ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៥៤-៦២, ៦៧៧។

[272] ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៣៦-៥៣, ៦៧៧, ផ្នែក VI.ក. មន្ទីរសន្តិសុខវត្ត តាមះ, ផ្នែក VI.ខ. មន្ទីរសន្តិសុខ គ (មិត្ត សុប), ផ្នែក VI.គ. ទីតាំងសម្លាប់មនុស្សភ្នំប្រុស, ផ្នែក VI.ឃ. មន្ទីរសន្តិសុខទួលបេង និងវត្តអង្គញដី, ផ្នែក VI.ង. ទីតាំងសម្លាប់មនុស្សគោកព្រីង, ផ្នែក VI.ច. មន្ទីរសន្តិសុខវត្តបាធាយ, ផ្នែក VI.ជ. មន្ទីរសន្តិសុខវត្តអូរត្រកួន។

ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់គាត់ដោយហៅជនរងគ្រោះថាជាពួកក្បត់[273] ។ គាត់ក៏បានបង្ខំអ្នកដែលនៅក្រោមបង្គាប់គាត់ឲ្យរៀបការជាមួយគូស្រករដែល ប.ក.ក ជ្រើសរើសឲ្យ និងឲ្យរួមភេទជាមួយគ្នា បន្ទាប់ពីពួកគេរៀបអាពាហ៍ពិពាហ៍រួច ដោយមិនមានការយល់ព្រមពិតប្រាកដពីពួកគេទាំងពីរនាក់ផង[274]។

110. គ្មានភស្តុតាងបង្ហាញថា អោ អាន ធ្លាប់មានវិប្បដិសារីចំពោះសកម្មភាពរបស់ខ្លួន ឬធ្លាប់មានអារម្មណ៍ថាមិនត្រឹមត្រូវ ចំពោះផលប្រយោជន៍ដែលគាត់បានទទួលពីឆន្ទៈ និងការចូលរួមយ៉ាងសកម្មរបស់គាត់នៅក្នុងយុទ្ធនាការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងតំបន់ ៤១ នេះឡើយ។ ផ្ទុយទៅវិញ គាត់នៅតែស្មោះស្ម័គ្រចំពោះ ប.ក.ក ទោះបីជានៅក្រោយពេលដែលរបបកម្ពុជាប្រជាធិបតេយ្យបានបញ្ចប់ហើយក៏ដោយ ដោយគាត់បានបន្តរស់នៅក្នុងតំបន់ដែលខ្មែរក្រហមត្រួតត្រា បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យនេះ[275]។ នៅក្នុងឆ្នាំ២០១១ នៅពេលគេសួរគាត់អំពីកម្ពុជាប្រជាធិបតេយ្យ គាត់បានឆ្លើយថា គាត់ "ពេញចិត្តពេញថ្លើម [ចំពោះកម្ពុជាប្រជាធិបតេយ្យ]" ដោយសារមេដឹកនាំរបស់របបនេះបាន "ការពារ ហើយខំកសាងប្រទេស ហើយស្តារប្រទេសឡើងវិញ"[276]។

111. ការកាត់បន្ថយការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ អោ អាន នៅក្នុងដីកាលើកលែងការចោទប្រកាន់ផ្អែកទៅលើការវិភាគផ្នែកច្បាប់ដែលមានកំហុសទៅលើអានុភាពនៃការបញ្ជារបស់ថ្នាក់លើ ក្នុងការកំណត់ថាតើ បុគ្គលនេះស្ថិតក្នុងប្រភេទនៃជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មរបស់កម្ពុជាប្រជាធិបតេយ្យ និងផ្អែកលើការសន្និដ្ឋានផ្នែកអង្គហេតុដែលមិនសមហេតុផល អំពីការចូលរួមរបស់ អោ អាន ដ៏សំខាន់ យ៉ាងយកចិត្តទុកដាក់ និងដោយគ្មានវិប្បដិសារីនៅក្នុងយុទ្ធនាការប្រព្រឹត្តឧក្រិដ្ឋដ៏សាហាវយង់ឃ្នង ដែលបានធ្វើឲ្យប្រជាជនកម្ពុជារាប់ម៉ឺននាក់ក្លាយជាជនរងគ្រោះនោះ។

---

273 ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១៧, ៦៧៧។

274 ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៧៣, ៦៧៧ (xxxi-xxxv), ផ្នែក VI.ញ. – អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទ។

275 **D191.2** បទសម្ភាសន៍ អោ អាន ជាមួយ DC-Cam, EN 01025331-35។

276 **D191.2** បទសម្ភាសន៍ អោ អាន ជាមួយ DC-Cam, EN 01025335។

## VII. សំណើអំពីដំណោះស្រាយ

112. ដូចបានរៀបរាប់ខាងលើ ស.ព.អ ស្នើដោយគោរពឲ្យអង្គបុរេជម្រះបដិសេធសេចក្តីសន្និដ្ឋាន មិនត្រឹមត្រូវនៅក្នុងដីកាលើកលែងចោទប្រកាន់ ដែលថា អោ អាន មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ហើយសន្និដ្ឋានថា អោ អាន គឺជាជនម្នាក់នៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មសម័យកាលកម្ពុជាប្រជាធិបតេយ្យ និងបញ្ជូន អោ អាន ទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |